ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ពិធីបុណ្យភ្ជុំបិណ្ឌ
- ទស្សនវិស័យរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២១៣ ខែកញ្ញា ឆ្នាំ២០១៧

# ស្វែងរកការពិត

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ២១៣ ខែកញ្ញា ឆ្នាំ២០១៧

## មាតិកា

◆ ពិធីបុណ្យភ្ជុំបិណ្ឌ ..................................................................................១

### ផ្នែកឯកសារ

◆ កុយ សំ ប្រធានពាណិជ្ជកម្ម តំបន់១ អ្នកទោសនៅមន្ទីរស-២១ .........៤

◆ វ៉ន បេត ហៅ គូ អនុលេខាតំបន់៣ ភូមិភាគពាយ័ព្យ .....................១០

◆ យុវនារីបដិវត្តន៍យើង ប្ដេជ្ញាខិតខំកសាងខ្លួនឲ្យបានល្អតាមគោលជំហរបដិវត្តន៍របស់បក្សយើង ដើម្បីបន្តវេនបដិវត្តន៍ឲ្យក្រហមឆ្អិនឆ្អៅជារៀងរហូត .......២២

### ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ

◆ អង្ករមួយគ្រាប់អាចឲ្យមនុស្សម្នាក់ស្លាប់ ឬរស់បាន ..........................២៧

◆ ភូមិអំពិលទឹកបន្ទាប់ពីរដ្ឋប្រហារ ...................................................២៨

◆ ការសម្របខ្លួន ជួយឲ្យយើងរស់រានមានជីវិត .................................៣១

◆ អោម មុត ៈ កងនារីស្រែអំបិល ................................................៣៦

◆ គ្រូបុរាំបុរាណដែលរស់ពីរបបខ្មែរក្រហម .......................................៣៨

◆ មិត្តភក្តិដែលខ្ញុំមិនអាចបំភ្លេចបាននៅក្នុងរបបខ្មែរក្រហម ....................៤១

### ផ្នែកច្បាប់

◆ សហព្រះរាជអាជ្ញា បន្តផ្ញើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ បញ្ចប់កិច្ចពិភាក្សាដេញដោល ..........................................................................................៤៥

◆ សេចក្ដីថ្លែងការណ៍របស់ការិយាល័យសហព្រះរាជអាជ្ញា ស្ដីពីសំណុំរឿង ០០៤/២ ..................................................................................៥២

### វេទិកាពិភាក្សាសាធារណៈ

◆ ទស្សនវិស័យរបស់គម្រោងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ..................៥៧

### ទំព័រស្រាវជ្រាវរកគ្រួសារ

◆ ព្រាត់ឪពុកដោយសារគ្មានថ្នាំព្យាបាល ...........................................៦០



ពិធីបុណ្យកាន់បិណ្ឌថ្ងៃទី១ ត្រូវនឹងថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧ នៅវត្តលង្កា ក្រុងភ្នំពេញ

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ*** ៈ ស្ងួស សកល, ម៉ែន ពិចិត្រ, វណ្ណ វីរៈបុត្រ, ឃាង សេងហឿន, រ៉ូនិត អារី, ម៉ារីសា ការូថើស, លី សុខឃាង ***អ្នកនិពន្ធនិងស្រាវជ្រាវ*** ៈ ទាវ សារៈមុនិន្ទ និង ឆេង វើង ***អ្នកបកប្រែ*** ៈ លន់ ច័ន្ទសុចិត្រា និង អ៊ុំប កញ្ញា ***និពន្ធនាយកទូទៅ*** ៈ ឆាំង យុ ***ជំនួយការនិពន្ធនាយក*** ៈ សោម ប៊ុនថន ***ក្រាហ្វិកកុំព្យូទ័រ*** ៈ សោម ប៊ុនថន ***គ្រប់គ្រងការចែកផ្សាយ*** ៈ សន ល័ក្ខ **Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org**

# ពិធីបុណ្យភ្ជុំបិណ្ឌ

ខ្ញុំបាទសូមយកឱកាសក្នុងពិធីបុណ្យភ្ជុំបិណ្ឌនេះ ដើម្បីសម្ដែងការគោរពដល់ប្រជាជនកម្ពុជាប្រមាណ២លាននាក់ ដែលបានស្លាប់បាត់បង់ជីវិតក្រោមរបបខ្មែរក្រហម ។ ទោះបីជាប្រទេសយើងបានបាត់បង់ជីវិតមនុស្សយ៉ាងច្រើន និងគ្មានពាក្យ ឬ ទង្វើអ្វីមួយអាចជួយយើងឲ្យរួចផុតពីភាពភ័យរន្ធត់នៃប្រវត្តិសាស្ត្រនេះបានយ៉ាងណាក៏ដោយ ក៏យើងចាំបាច់ត្រូវតែបង្កើនស្មារតីក្នុងការបង្កើត និងចែករំលែកភាពជាមនុស្ស ដើម្បីឆ្ពោះទៅមុខ ។ ជាមួយនឹងភាពអមនុស្សធម៌ យើងទាំងអស់គ្នាមានភាពរឹងមាំក្នុងការកសាងជីវិតសម្រាប់ខ្លួនឯង សហគមន៍ និងប្រទេសជាតិទាំងមូល ។

ការកសាងជីវិតថ្មី មិនអាចចាប់ផ្ដើមដោយការមិនអើពើអំពីអតីតកាលបានឡើយ ។ ដោយចំណាយពេលវេលាក្នុងការរៀនសូត្រពីអតីតកាល តាមរយៈសាច់រឿងរបស់អ្នករស់រានមានជីវិត និងការស្រាវជ្រាវ យើងអាចចាប់ផ្ដើមស្វែងយល់ពីរបៀបនៃការតភ្ជាប់ទំនាក់ទំនងរវាងខ្លួនយើងជាមួយនឹងជីដូនជីតា និងរបៀបនៃការគោរពការចងចាំរបស់ដូនតាយើង ។ តាមរយៈការអប់រំ យើងអាចសម្ដែងនូវការគោរពដល់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ ហើយបង្កើតជាទម្រង់យុត្តិធម៌មួយដែលមិនត្រូវបានបំភ្លេចចោលដោយពេលវេលា ។ ខ្ញុំបាទសង្ឃឹមថា យើងធ្វើឲ្យការប្ដេជ្ញាចិត្តរបស់យើងក្នុងការចងចាំពីអតីតកាល និងការតស៊ូពុះពាររបស់ជីដូនជីតាយើង នឹងធានាថា ប្រជាជនកម្ពុជាទាំងអស់មានជំហររឹងមាំ សម្រាប់សង្គមដ៏ល្អប្រសើរមួយ ។

**ឆាំង យុ**



រូបទីមួយរាប់ពីខាងស្ដាំ ៖ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងបងស្រី ចូលរួមពិធីបុណ្យកាន់បិណ្ឌថ្ងៃទី១ ត្រូវនឹងថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧ នៅវត្តលង្កា ក្រុងភ្នំពេញ ។

# កុយ សំ ប្រធានពាណិជ្ជកម្ម តំបន់១

***ដកស្រង់ចេញពីឯកសារលេខ D៤១២៩២***

*កុយ សំ អាយុ៣៧ឆ្នាំ (គិតត្រឹមឆ្នាំ១៩៧៧) កើតនៅភូមិជ្រុងក្រសាំង ឃុំបន្ទាយមាស ស្រុកទូកមាស ខេត្តកំពត មាននាទីជាប្រធានពាណិជ្ជកម្មតំបន់១ ភូមិភាគពាយ័ព្យ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សំ ត្រូវបានអង្គការចាប់ខ្លួនពីបទសមគំនិតជាមួយបក្ខពួកធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ ។ សំ ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៧៧ និងបានបញ្ជូនមកឃុំឃាំងនៅមន្ទីរស-២១ ដើម្បីសួរចម្លើយ ។ នៅក្នុងចម្លើយសារភាពដែលសរសេរដោយដៃ មានចំនួន៤០ទំព័រ សំ បានរៀបរាប់ពីប្រវត្តិ និងសកម្មភាពដែលខ្លួនរួមជាមួយបក្ខពួក បានធ្វើកន្លងមកដើម្បីប្រឆាំងនឹងអង្គការបដិវត្តន៍ ។ យើងមិនដឹងថា ចម្លើយសារភាពនេះ ពិតប្រាកដយ៉ាងណានោះទេ ។ ខាងក្រោម ជាសកម្មភាពដែលបានដកស្រង់ចេញពីចម្លើយសារភាពរបស់ កុយ សំ ៖*

*នៅឆ្នាំ១៩៥៨ សំ បានក្លាយជាក្មេងកំព្រាដោយឪពុកម្តាយបានស្លាប់ដោយសារជំងឺ ។ ពេលនោះ សំ បានទៅរស់នៅជាមួយបងស្រីឈ្មោះ អ៊ិន នៅភូមិជ្រុងក្រសាំង ដោយប្រកបរបរធ្វើស្រែ និងស៊ីឈ្នួលជាន់ក្បឿងឲ្យអ្នកភូមិម្នាក់ឈ្មោះ យន់ ។ នៅឆ្នាំ១៩៦០ បងស្រីបានបញ្ជូនសំ ឲ្យទៅបួសនៅវត្តអង្គជ្រៃ ក្នុងឃុំបន្ទាយមាស បានមួយវស្សា ។ ឆ្នាំ១៩៦១ សំ បានសឹកពីបួស ហើយប្រកបរបររកស៊ីអូសទឹកលក់នៅផ្សារមោង ។ មួយឆ្នាំក្រោយមក សំ បានទាក់ទងស្គាល់ ហើយបានរស់នៅជាមួយឈ្មោះ ទន់ នៅភូមិឬស្សីក្រាំង ឃុំព្រៃត្រឡាច ស្រុកមោងឫស្សី ខេត្តបាត់ដំបង ដោយពេល នោះប្រកបរបររកស៊ីកាប់ឈើលក់ ។ ឆ្នាំ១៩៦៣ ទន់ក៏បានរៀបការប្រពន្ធឲ្យ សំ ជាមួយនឹងក្មួយស្រីរបស់គាត់ឈ្មោះ ម៉ុម សៀក ។ បន្ទាប់មក សំ ក៏បានមករស់នៅជាមួយនឹងឪពុកម្តាយក្មេកនៅភូមិឫស្សីក្រាំង ហើយប្រកបរបររកស៊ីធ្វើស្រែផង និងកាប់ឈើលក់ផង ។ នៅឆ្នាំ១៩៦៧ ឈ្មោះ ពួច ជាមេកងជីវពលនៅភូមិឫស្សីក្រាំង បានមកកត់ឈ្មោះ សំ ឲ្យចូលហាត់ជីវពលដោយខ្លួនជាអ្នកបង្ហាត់ផ្ទាល់ដែលពេលនោះ កងជីវពលមានសមាជិក*



*ទិដ្ឋភាពនៅក្នុងបន្ទប់ឃុំឃាំងអ្នកទោស នៅមន្ទីរសន្តិសុខស-២១ ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ឆ្នាំ១៩៧៩ ។ (រូបថត៖ ទួលស្លែង)*

ចំនួនមួយរយនាក់ ។ ពេលហាត់រៀនក្បួនជីវពល ពួច បានអប់រំកងជីវពលទាំងអស់ឲ្យខិតខំហាត់រៀនឲ្យមែនទែន ដើម្បីយាមការពារភូមិកុំឲ្យខ្មែរក្រហមចូលអុកឡុកបាន ។ ក្រោយពីហាត់រៀនចប់ ពួច និងប៉ូលីសបីនាក់ទៀត បានចុះមកដឹកនាំកងជីវពល ឲ្យឡើងទៅយាមចាំចាប់ខ្មែរក្រហមនៅ ជើងភ្នំកំពង់ខ្វាងអស់រយៈពេលមួយអាទិត្យ តែចាប់ខ្មែរក្រហមមិនបាន ក៏នាំគ្នាត្រឡប់មកភូមិវិញ ។ ឆ្នាំ១៩៦៨-៦៩ សំ មានជំងឺជាប់ មិនបានធ្វើសកម្មភាពអ្វីទេ ។

ក្រោយរដ្ឋប្រហារខែមីនា ឆ្នាំ១៩៧០ ពួច បានឃោសនាអប់រំប្រជាជន និងកងជីវពលទាំងអស់នៅក្នុងភូមិឫស្សីក្រាំងឲ្យរត់ចូលព្រៃ ។ ពីរថ្ងៃក្រោយមក អង្គការបានចាត់តាំងឈ្មោះ ឈិន អតីតគ្រូបង្រៀននៅសាលាគន្ធា ឃុំតាលោ ស្រុកបាកាន ឲ្យធ្វើជាគណៈឃុំឫស្សីក្រាំង ហើយបានដឹកនាំប្រជាជនឲ្យមករស់នៅក្នុងភូមិវិញ ។ ពេលនោះ សំ, លន, ឡាយ, ហ៊ាល, ថោង, ឌឿ, សឿន និង សែត បានទៅនៅជាមួយ ឈិន ជាប់រហូតមក ។ ក្នុងអំឡុងពេលនៅជាមួយ ឈិនៗ តែងតែអប់រំឲ្យខិតខំធ្វើការ គាត់នឹងកត់ឈ្មោះឲ្យទៅសម្តេចឪ ។ ឈិន បាននិយាយថា ចម្បាំងនៅក្នុងស្រុកយើង ប្រហែលជាបីខែទៀតចប់ហើយ ហើយយើងនឹងបានទៅទទួលសម្តេចឪមកវិញ ។

ឆ្នាំ១៩៧១ ប្រហែលជានៅក្នុងខែមីនា ឈិន បានហៅ សំ, លន, ឡាយ, ហ៊ាល, ថោង, ឌឿ, សឿន និង សែត ទៅចូលរួមប្រជុំនៅមន្ទីរអប់រំក្នុងភូមិខ្វាវ ឃុំឫស្សីក្រាំង ។ ពេលនោះ ឈិន បានចាត់តាំង សំ, ឡាយ និង លន ជាគណៈភូមិឫស្សីក្រាំង, ឌឿន និង សឿន ជាគណៈឈ្លបឃុំឫស្សីក្រាំង, ហ៊ាល និង ថោង ជាជំនួយការសេដ្ឋកិច្ចឃុំឫស្សីក្រាំង, និង សែត ជាអ្នកមើលការខុសត្រូវចម្ការក្រូចក្នុងឃុំដំណាក់កន្ទេង ស្រុកបាកាន ។ ក្រោយពីបានចាត់តាំងហើយ ឈិន បានណែនាំឲ្យខិតខំធ្វើការ ហើយមួយខែត្រូវមកប្រជុំម្តង រួចហើយក៏ចុះតាមមុខសញ្ញារៀងៗខ្លួន ។

រំលងបានមួយខែ ឈិន ក៏បានហៅអ្នកទាំងប្រាំបីខាងលើមកប្រជុំម្តងទៀតនៅកន្លែងដដែល ។ ពេលនោះ ឈិន បានសួរថា តើការធ្វើបដិវត្តន៍នេះមានការលំបាកឬក៏ស្រួល? សមាជិកក៏បានប្រាប់ថា មានការលំបាកពីរឿងស្បៀង និងការរត់លួនពេលខ្មាំងធ្វើសកម្មភាព ។ ឈិន បានបន្តថា យើងសព្វថ្ងៃមើលឃើញការលំបាកនេះ វាធំជាងការលំបាកក្នុងជំនាន់ឥស្សរៈទៅទៀត ដូច្នេះតទៅមុខ យើងកាន់តែមានការលំបាកជាងនេះ ។ បើយើងមិនពុះពារ តស៊ូប្រឆាំងវិញទេ យើងមុខតែលំបាកហើយ ។ ពេលនោះ សំ ក៏យល់ស្របតាមការអប់រំរបស់ ឈិន ដោយមានទស្សនៈយល់ឃើញថា បើសិនជាធ្វើការប្រឆាំងនឹងបដិវត្តន៍បានជ័យជម្នះខ្លួននិងមានតួនាទី មានតំណែងធំៗ មានបុណ្យស័ក្តិពាក់ មានប្រាក់ខែនឹងមិនលំបាកទេ ។ ចុងបញ្ចប់នៃការប្រជុំ ឈិន បានដាក់ផែនការឲ្យសមាជិកអនុវត្តគឺ ៖

១) ឃោសនា អប់រំកសាងកម្លាំងបង្កប់នៅតាមភូមិ ដើម្បីឲ្យកម្លាំងទាំងនេះ ជួយធ្វើសកម្មភាពបំផុសប្រជាជន កុំឲ្យមានជំនឿទៅលើបដិវត្តន៍ ។

២) ពេលកសាងកម្លាំងបានហើយ ត្រូវបំផុសកម្លាំងដែលកសាងបាន ឲ្យដឹកនាំសេដ្ឋកិច្ចពីតំបន់រំដោះ យកទៅលក់នៅតំបន់ខ្មាំង ដើម្បីធ្វើឲ្យតំបន់រំដោះមានការខ្វះខាតខាងសេដ្ឋកិច្ច ប្រជាជនក៏លែងមានជំនឿលើបដិវត្តន៍ ។ ទន្ទឹមនឹងនេះ ត្រូវទាក់ទងជាមួយខ្មាំងឲ្យខ្មាំងចុះមកធ្វើសកម្មភាពនៅក្នុងដីរំដោះ ។

ចប់ការប្រជុំ ទាំងអស់គ្នាក៏បានចុះទៅធ្វើការតាមមុខសញ្ញារបស់ខ្លួនវិញ ។ ចំណែក សំ បានទៅទាក់ទងជាមួយឈ្មោះ ឯម ប្រធានសហករណ៍ភូមិចាហួយ ដែលខ្លួនធ្លាប់ស្គាល់ និងរាប់អានគ្នាយ៉ាងជិតស្និទ្ធកាលពីសង្គមចាស់ ។ តាមរយៈនេះ សំ បានលើកពីគម្រោងចង់បញ្ចេញសេដ្ឋកិច្ច (គ្រឿងឧបភោគ បរិភោគ) ទៅលក់នៅតំបន់ខ្មាំង ។ ពេលនោះ ឯម ក៏បានប្រាប់មក សំ វិញថា ខ្លួនស្គាល់ចាមម្នាក់ឈ្មោះ ជីស្លេះ ជាទាហានពាក់ស័ក្តិ៤ នៅភូមិជ្រាវ ឃុំប្រាបសែន ស្រុកមោង អាចទាក់ទងជាមួយដើម្បីបើកផ្លូវនាំយកសេដ្ឋកិច្ចទៅទីនោះបាន ។ ចំណែក ឡាយ កសាងកម្លាំងបានម្នាក់ឈ្មោះ ភន គណៈសហករណ៍កែវស្អាត រីឯ ឈិន ក៏បានកសាងកម្លាំងបានម្នាក់ដែរឈ្មោះ យ៉ុល ជាប្រធានភូមិទួលអំពិល ។

បន្ទាប់ពីយកផែនការទៅអនុវត្តបានមួយរយៈកន្លងមក ឈិន ក៏បានហៅបក្ខពួកទាំងប្រាំបីនាក់មកប្រជុំម្តងទៀត ។ ក្រោយពីស្តាប់សេចក្តីរាយការណ៍របស់សមាជិកក្រុមរួចហើយ ឈិន ក៏បានណែនាំក្រុមរបស់ខ្លួនបន្ថែមឲ្យខិតខំពង្រីកកម្លាំង ហើយកម្លាំងដែលកសាងបានទាំងប៉ុន្មានឲ្យចេញទៅទាក់ទងខ្មាំងឲ្យជាប់ដើម្បីឲ្យ

ខ្លាំងចូលមកធ្វើសកម្មភាពអុកឡុកកៀរប្រជាជននៅក្នុងតំបន់រំដោះ ។ ការណ៍ដែលធ្វើបែបនេះ គឺដើម្បីឲ្យប្រជាជនអស់ជំនឿមកលើបដិវត្តន៍ ។ ឈិន បានបន្តថា ទន្ទឹមនេះ យើងក៏ត្រូវវាយបដិវត្តន៍ពីខាងក្នុង គឺវាយផ្នែកនយោបាយ បំផុសបំផុលឲ្យប្រជាជនមើលឃើញបដិវត្តន៍ខ្សោយ ។ យើងនៅមានឈ្មោះ វ៉ាញ បច្ចុប្បន្នជាគណៈតំបន់១ (ត្រូវបានអង្គការចាប់ខ្លួនហើយ) ជាមេ សេ.អ៊ី.អា ធំ អាចដឹកនាំធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍បាន ឲ្យតែយើងខិតខំកសាងកម្លាំង ។ ពេលឮថាមានឈ្មោះ វ៉ាញ នៅដឹកនាំពីលើ បានធ្វើឲ្យ សំ កាន់តែមានជំនឿជឿជាក់ថែមមួយកម្រិតទៀត ។

ឆ្នាំ១៩៧២ ឈិន បានចាត់តាំង សំ ឲ្យធ្វើជាប្រធានពាណិជ្ជកម្មឃុំបុស្សីក្រាំង ហើយលក់សម្ភារនៅភូមិពេជចង្វារ ។ ការលក់ដូរនេះ អង្គការបានកំណត់ឲ្យលក់យកចំណេញតែ១៥ភាគរយទេ តែ ឈិន បានបញ្ជាឲ្យលក់យកចំណេញដល់ទៅ៥០ភាគរយ ។ មិនតែប៉ុណ្ណោះ ឈិន បានដាក់ផែនការឲ្យ សំ ដើរបំផុសប្រាប់ប្រជាជនថា អង្គការលក់អ្វីៗក៏ថ្លៃដែរ ចំណែកលុយចំណេញ៣៥ភាគរយ ត្រូវកាត់យកទៅឲ្យ វ៉ាញ សន្សំទុកដើម្បីទិញស្រូវ អំបិល ត្រៀមទុកវាយបដិវត្តន៍ ។ រយៈពេលពីរខែក្រោយមក សំ កសាងកម្លាំងបានម្នាក់ឈ្មោះ យ៉ែម ដែល យ៉ែម នេះខស្សាហ៍ចេញចូលនៅកន្លែងពាណិជ្ជកម្មលក់ដូរ ។ បន្ទាប់មកទៀត សំ បានបន្តអប់រំឈ្មោះ សុខ និង ឈ្មោះ យន ដែលជាសមាជិកនៅលក់ដូរជាមួយគ្នាឲ្យចូលមកខាងក្រុមរបស់ខ្លួនបានទៀត ។ នៅចុងឆ្នាំ១៩៧២ សំ រួមជាមួយសមាជិកចំនួន១៣នាក់ទៀត បានមកប្រជុំ និងធ្វើសេចក្តីរាយការណ៍ ដោយមាន ឈិន ជាប្រធានអង្គប្រជុំ ។ ពេលនោះ សំ បានរាយការណ៍ថា ខ្លួនបានអប់រំកម្លាំងបានពីរនាក់បន្ថែមមានឈ្មោះ សុខ និង យន ។ រីឯ ភន បានរាយការណ៍ថា ខ្លួន និង យ៉ុល បានយកគោក្របីទៅលក់ឲ្យ ចឹកវ៉ា បានមួយចំនួន ហើយបានឲ្យ ចឹកវ៉ា ទៅទាក់ទងទាហាននៅស្វាយដូនកែវចុះមកកៀរប្រជាជន និងចាប់យកគោក្របីរបស់ប្រជាជនទៅជាមួយអស់មួយចំនួន ។ ចំណែក ឯម និង យ៉ែម បានរាយការណ៍ថា ខ្លួនបានហៅទាហានឲ្យទៅកៀរប្រជាជន នៅភូមិពេជចង្វារយកទៅជាមួយអស់ជិត៤០គ្រួសារ ហើយក្រោយមកទៀត បានបំផុសប្រជាជនដែលរស់នៅកន្លែងនោះ ឲ្យរត់ចោលភូមិបានពីរដងដោយកុហកថា ពួកទាហានចុះមក ។ ក្រោយពីស្តាប់សេចក្តីរាយការណ៍ចប់ហើយ ឈិន បានធ្វើការអប់រំសមាជិកទាំងអស់ឲ្យមើលឃើញពីភាពជោគជ័យរបស់ក្រុមខ្លួន ហើយថា បដិវត្តន៍មិនខ្លាំងទេ ។ ដូច្នេះ ទាំងអស់គ្នាត្រូវត្រៀមខ្លួនឲ្យហើយក្នុងការធ្វើសង្គ្រាមជាមួយបដិវត្តន៍ ។ មួយឆ្នាំ ឬពីរឆ្នាំឈ្នះបដិវត្តន៍ក៏ធ្វើ បួនឆ្នាំទៅដប់ឆ្នាំឈ្នះក៏ធ្វើ គឺធ្វើយ៉ាងណាកុំឲ្យកុម្មុយនីស្តឈ្នះ ត្រូវឲ្យមូលធនឈ្នះវិញ ទើបយើងសម្បូរសប្បាយ ហើយត្រូវខិតខំពង្រីកសកម្មភាពឲ្យបានខ្លាំងក្លាបន្តទៀត ។

នៅឆ្នាំ១៩៧៣ សំ បានឲ្យ ឯម និង យ៉ែម ទៅទាក់ទងជាមួយ ស័ក្តិ៤ ជីស្លេះ ដើម្បីឲ្យទាហានចុះមកកៀរប្រជាជន និងចាប់យកគោក្របីនៅតាមភូមិជាបន្តបន្ទាប់ ។ ជាក់ស្តែង ទាហានចុះមកកៀរប្រជាជននៅភូមិពេជចង្វារម្តងៗអស់ពីបួនទៅដប់គ្រួសារ ចុះទៅកៀរប្រជាជននៅភូមិសំរោងមេទ្រាលស្ទើរអស់មួយភូមិ នៅសល់ប្រហែលបួនប្រាំគ្រួសារប៉ុណ្ណោះដែលរត់រួច ។ ក្រោយមកអង្គការក៏បានជម្លៀសប្រជាជនឲ្យចេញពីភូមិពេជចង្វារ ភូមិកែវស្អាត ភូមិទួលអំពិល ឲ្យឡើងទៅនៅខាងត្បូងភូមិបុស្សីក្រាំងវិញ ចំណែក សំ ក៏បានទៅធ្វើកន្លែងលក់ដូរនៅភូមិបុស្សីក្រាំងដែរ ។ បន្ទាប់មក នៅចុងឆ្នាំ១៩៧៣ ឈិន ក៏បានរៀបចំប្រជាជនដែលបានជម្លៀសមកភូមិបុស្សីក្រាំងទាំងប៉ុន្មាន ចែកចេញជាបីសហករណ៍ ហើយក្នុងមួយសហករណ៍មានប្រជាជនចំនួន១០០គ្រួសារ ។ ពេលនោះ ប្រជាជនទាំងអស់គឺតម្រូវឲ្យហូបរួម ហើយទ្រព្យសម្បត្តិឯកជនទាំងប៉ុន្មាន ក៏ត្រូវប្រមូលយកមកដាក់រួមដែរ ធ្វើបែបនេះដើម្បីឲ្យប្រជាជនអស់ជំនឿលើបដិវត្តន៍ ។ ចំណែកខ្សែចាត់តាំងរបស់ ឈិន ក៏ចេះតែឃោសនា អប់រំប្រជាជនទាំងនោះ កុំឲ្យមានជំនឿលើបដិវត្តន៍ និងធ្វើឲ្យកើតមានជាទំនាស់ក្នុងសហករណ៍ជាហូរហែ ។ ក្រោយមកសហករណ៍នេះ ក៏បានរង្គោះរង្គើរ ប្រជាជនចេះតែនាំគ្នារត់ចេញ លុះនៅពាក់កណ្តាលឆ្នាំ១៩៧៤ ឈិន ក៏បានរំសាយសហករណ៍នោះចោលវិញ ។ ចំណែក សំ, ឯម និង យ៉ែម បានឲ្យទាហាននៅបន្ទាយជ្រាវ ដែលមាន ជីស្លេះ ជាមេកើយ ឡើងមកធ្វើសកម្មភាពកៀរប្រជាជន ចាប់យកគោក្របីប្រជាជននៅខាងលិចភូមិបុស្សីក្រាំង ភូមិព្រៃផ្គាប ។ គ្រានោះដែរ មានទាហានពីរនាក់ បានខូចសីលធម៌ជាមួយនារីនៅចុងភូមិខ្វាវ ។ ពេលនោះកងឈ្លបក៏ចាប់បានទាហានទាំងពីរនាក់រួមជាមួយនារីពីរនាក់ទៀត

យកទៅសម្លាប់ចោលទាំងអស់នៅក្នុងថ្ងៃនោះទៅ ។ នេះជាសកម្មភាពដែលកើតមានឡើងនៅក្នុងឃុំបុស្សឹក្រាំងក្នុងឆ្នាំ១៩៧៤ ។

ខែកញ្ញា ឆ្នាំ១៩៧៤ អង្គការបានចាត់តាំង សំ ឲ្យទៅធ្វើការនៅពាណិជ្ជកម្មតំបន់២ ផ្នែកខាងដោះដូរសម្ភារ ដែលមានឈ្មោះ វ៉ាញ គណៈតំបន់២ ជាអ្នកក្តាប់ផ្នែកពាណិជ្ជកម្ម ។ នៅទីនោះបានប្រហែលប្រាំថ្ងៃ វ៉ាញ បានហៅសមាជិកពាណិជ្ជកម្មតំបន់២ ឲ្យចូលរួមប្រជុំ ។ ការប្រជុំនេះ វ៉ាញ បានណែនាំលើកជាទិសដូចតទៅ៖

១) សំ និង ណែម ត្រូវបានចាត់ឲ្យនៅកន្លែងដោះដូរសម្ភារ គឺបើប្រជាជនមានថ្នាំជក់ ហើយចង់ដូរយកអំបិល គឺថ្នាំជក់មួយគីឡូក្រាម អាចដូរយកអំបិលបានពីរខាំ មាន់រស់ទម្ងន់បីគីឡូក្រាម អាចដូរយកអំបិលបានតែមួយខាំកន្ទះទេ តែបើប្រជាជនអត់មានរបស់មកដោះដូរទេ ហើយចង់ទិញអំបិល គឺលក់ឲ្យតែមួយខាំទេ ។ រីឯការដោះដូរក្រណាត់វិញ វ៉ាញ បានលើកឡើងថា ក្រណាត់១០ម៉ែត្រ ឲ្យដូរជាមួយគោធំមួយក្បាលដែលគោនោះអាចប្រើការបាន ជ្រូកមួយទម្ងន់១០០គីឡូក្រាម ដូរយកក្រណាត់បានចំនួន៥ម៉ែត្រ ។ បើដូរជាមួយស្រូវវិញ គឺស្រូវចំនួនបីតៅ ដូរក្រណាត់បានមួយម៉ែត្រ តែបើយកស្រូវដូរជាមួយស្ករត្នោតគឺ ស្រូវមួយតៅ អាចដូរស្ករត្នោតបានមួយគីឡូកន្ទះ ។

២) ម៉ន ត្រូវបានចាត់ឲ្យដើរទិញស្រូវឲ្យបានច្រើន ។ ស្រូវមួយចំនួនត្រូវកិនជាអង្ករបញ្ជូនទៅឲ្យខាងកងទ័ព ឯមួយចំនួនធំត្រូវលាក់ទុកធ្វើជាស្បៀង ត្រៀមសម្រាប់វាយបដិវត្តន៍ ។

៣) សុន ត្រូវបានចាត់ឲ្យដឹករបស់របរដែលដូរបានពីប្រជាជនដូចជាគោ ជ្រូក មាន់ទា ដឹកយកទៅខាងនិរតី ហើយឲ្យដឹកអំបិល ក្រណាត់នីឡុងចូលមកតំបន់២វិញ ។ វ៉ាញ ក៏បានបញ្ជាក់ដែរថា អំបិលត្រូវធ្វើយ៉ាងម៉េចដឹកយកមកឲ្យបានច្រើន មួយចំនួនតូចសម្រាប់លក់ និងដោះដូរចែកប្រជាជន ហើយសល់មួយចំនួនធំត្រូវលាក់ទុក ចំណែកក្រណាត់នីឡុងត្រូវយកមកធ្វើអង្រឹងត្រៀមទុកដែរ ។

៤) ហ៊ិន ត្រូវបានចាត់ឲ្យទៅទិញក្រណាត់នីឡុងនៅខាងកំពង់ចាម សម្រាប់យកមកធ្វើជាអង្រឹងត្រៀមទុក ។

៥) យ៉េង ត្រូវបានចាត់ឲ្យទាក់ទងទិញរបស់របរពីតំបន់ខ្មាំងយកមកទុកធ្វើការដោះដូរ ។

៦) ទូន ត្រូវបានចាត់ឲ្យនៅមើលការខុសត្រូវរៀបចំអីវ៉ាន់ចេញចូល ។

ក្រោយពេលប្រជុំចប់ សមាជិកទាំងអស់ក៏នាំគ្នាចុះទៅតាមមុខសញ្ញារបស់ខ្លួនវិញ ។ ដោយឡែក សំ និង ណែម បានអនុវត្តតាមផែនការដែល វ៉ាញ បានដាក់ចុះជាបន្តបន្ទាប់ ។ ពេលនោះឃើញថា ប្រជាជនមានការខ្វះខាតអំបិល និងខ្វះក្រណាត់កាត់ខោអាវស្លៀកពាក់ស្ទើរតែគ្រប់គ្នា ព្រោះមិនមានរបស់របរអ្វីយកមកដោះដូរ ។ ទន្ទឹមនេះ បក្ខពួករបស់ សំ ក៏បានដើរឃោសនា អប់រំប្រជាជនដោយបាននិយាយថា «ធ្វើម៉េចបដិវត្តន៍វាលំបាកអីចឹង ហើយ ចេះតែទ្រាំៗសិនទៅ ព្រោះយើងដឹកអំបិលមិនទាន់ដោយសារខ្មាំងចេះតែធ្វើសកម្មភាពរារាំង» ។ ពេលនោះប្រជាជនក៏មិនហ៊ានមាត់កអីដែរ សុខចិត្តនាំគ្នាហូបសាប រីឯអំបិលនៅពាណិជ្ជកម្មតំបន់២ ក៏ចេះតែនៅសល់ជាបន្តបន្ទាប់ ។

ប្រហែលជាក្នុងខែកុម្ភៈ ឬក៏ខែមីនា ឆ្នាំ១៩៧៥ ក្រោយពីរំដោះស្រុកមោងបានហើយ វ៉ាញ ក៏បានចាត់តាំង សំ និង ជ័យ ហៅសម្បត្តិ ឲ្យទៅធ្វើឃ្លាំងសម្រាប់លាក់អំបិលមួយនៅភូមិកូនក្អែក ខាងត្បូងផ្សារមោង ដើម្បីត្រៀមទុក ។ ពេលនោះ សំ និង ជ័យ បានដឹកអំបិលចំនួនបីតោន និងស្ករត្នោតចំនួន១៥កាន ពីពាណិជ្ជកម្មតំបន់២ យកទៅលាក់ទុកនៅទីនោះ ។ ក្រោយរំដោះទូទាំងប្រទេស បានប្រហែលបួនប្រាំថ្ងៃ វ៉ាញ ក៏បានប្រមូលបក្ខពួករបស់ខ្លួនទាំងអស់មកប្រជុំឲ្យរាយការណ៍ពីស្រូវ អំបិល ក្រណាត់ និងសម្ភារផ្សេងៗទៀតដែលបានលាក់ទុក ។ ពេលនោះ ម៉ន ក៏បានរាយការណ៍ថា ស្រូវនៅសល់១០.០០០បាវ ទុកនៅក្នុងឃ្លាំងថ្កុកជង្ហោ ឃុំបាក់ចិញ្ចៀន ស្រុកបាកាន តំបន់២ ។ ទូន បានរាយការណ៍ថា អំបិលនៅសល់រួមទាំងអស់ប្រហែល៥០តោន ស្ករត្នោតប្រហែល៣០កាន ក្រណាត់នៅសល់មួយចំនួននៅពាណិជ្ជកម្មតំបន់២ ។ ពេលនោះ វ៉ាញ បាននិយាយថា សម្ភារទាំងអស់នេះ ទុកនៅទីនេះសិនចុះ ចាំចាត់វិធានការទៅថ្ងៃមុខទៀត ហើយបានចាត់ឲ្យ ម៉ន ដឹកនាំដើរប្រមែប្រមូលសម្ភារជ័យកណ្តូនៅក្នុងផ្សារបាត់ដំបងយកមកទុក ។ ចំណែកខ្លួន បាននាំឈ្មោះ យ៉េង, យាន និង កុន ទៅទាក់ទងជាមួយសៀមនៅអូរជ្រៅដើម្បីទិញអីវ៉ាន់ ។ ពេលចេញពីប្រជុំ

វ៉ាញ បាននាំ យ៉េង និង យាន ចេញទៅបាត់ ចំណែក សំ និង ម៉ន ក៏បាននាំគ្នាដើរប្រមូលជ័យភណ្ឌនៅក្នុងផ្សារបាត់ដំបងយកមកទុកដាក់ដែរ ។ ការប្រមូលសម្ភារជ័យភណ្ឌនេះ ធ្វើបានប្រហែល៧-៨ថ្ងៃ ពេលនោះ វ៉ាញ ក៏បានត្រឡប់មកវិញ តែអត់ឃើញ យ៉េង និង យាន មកជាមួយគ្នាទេ ។ ពេលមកដល់ភ្លាម វ៉ាញ ក៏បានហៅសមាជិកមួយចំនួនមាន សំ, ណែម, ម៉ន, ហ៊ួរ, ជ័យ ហៅ សម្បត្តិ, ហ៊ិន, សុន និង ទួន ប្រជុំនៅសាលា អ៊ាប យុត ។ ការប្រជុំនេះ វ៉ាញ បានលើកឡើងថា កាលពីនៅក្នុងសង្គ្រាម យើងបានលើកផែនការថា ឲ្យតែបដិវត្តន៍ឈ្នះ យើងនឹងវាយបកមកលើបដិវត្តន៍វិញភ្លាម តែពេលនេះ យើងមិនទាន់វាយបានទេ ព្រោះយើងទាក់ទងខ្មែរមិនជាប់ ហើយប្រជាជនកំពុងរត់ទៅសៀម សភាពការណ៍កំពុងច្របូកច្របល់ ម្យ៉ាងយើងជាប់រើសម្ភារជ័យភណ្ឌផង ។ ដូច្នេះ ជាទិសរបស់យើងក្នុងការវាយដណ្តើមយករដ្ឋអំណាចពីបដិវត្តន៍ គឺត្រូវលើកយកទៅធ្វើនៅឆ្នាំ១៩៧៦វិញ ព្រោះនៅពេលនោះ សៀមក៏ជួយយើងដែរ ហើយវាយតែ២៤ម៉ោង គឺយើងអាចរំដោះបានរហូតដល់ក្រុងបាត់ដំបងទៀតផង ។ វ៉ាញ បានបន្តដាក់ផែនការមួយទៀត គឺឲ្យបំផ្លាញសម្ភារជ័យភណ្ឌ ។ ការប្រមូលសម្ភារជ័យភណ្ឌនេះ គឺបើឃើញទូ ទោះបីមានបុគ្គានរបស់អ្វីនៅខាងក្នុងក៏ដោយ ត្រូវពុះបំបែកចោល ឯសម្ភារផ្សេងៗមាន ចាន ឆ្នាំង ក្រណាត់ ខោអាវ ត្រូវយកមកដាក់គរចោលឲ្យនៅកណ្តាលវាល ហាលភ្លៀង ហាលថ្ងៃ ធ្វើយ៉ាងម៉េចប្រមូលឲ្យអស់ពីក្នុងផ្សារ ។ ចំណែកមាសប្រាក់ ត្រូវប្រមូលយកមកឲ្យ ម៉ន លាក់ទុកឲ្យបាត់ រីឯ ប្រហុក ផ្អក ត្រីងៀត និងគ្រឿងចម្លាក់ល្អៗ ត្រូវយកទៅឲ្យឈ្មោះ យ៉េង នៅអូរជ្រៅលក់ឲ្យសៀម ឯការដឹកជញ្ជូនសម្ភារទៀតសោត ទោះជាមានភ្លៀងក្តី អត់ភ្លៀងក្តី មិនបាច់យកក្រណាត់កៅស៊ូគ្របពីលើទេ ហើយត្រូវយកទៅចាក់ធារនៅអូរជ្រៅ របស់ណាដែលខូចត្រូវបោះចោលតែម្តង នេះជាវិធីបំផ្លិចបំផ្លាញសម្ភារអង្គការ ដែល វ៉ាញ បានណែនាំឲ្យអនុវត្ត ។ ចេញពីប្រជុំទាំងអស់គ្នាបានទៅតាមមុខសញ្ញា ហើយបានអនុវត្តតាមផែនការដែល វ៉ាញ បានដាក់ចុះ ។ រយៈពេលនោះឃើញថា សម្ភារជ័យភណ្ឌមានការខូចខាតជាច្រើន តុ ទូ កញ្ចក់ បង្អួចផ្ទះ បានពុះបំបែក និងវាយបំបែក ។ ក្រណាត់ ខោអាវ ដែលយកទៅចាក់គរកណ្តាលវាល មានការខូចខាតអស់ជាច្រើន នៅមុខសញ្ញារបស់ សំ និង ហ៊ួរ វិញ ក៏មានការខូចខាតច្រើនដែរ ដូចជាប្រហុក ត្រីងៀត ផ្អក គឺត្រូវទឹកភ្លៀង ស្អុយរលួយ ហើយយកទៅបោះចោលអស់ជាច្រើន ។ ចំណែកអំបិល និងប្រេងម៉ាស៊ូតដែលទិញពីសៀមយកមកប្រើប្រាស់ ក៏មានការបំផ្លិចបំផ្លាញធ្វើឲ្យខូចខាតអស់មួយចំនួនដែរ អំបិលមួយបាវមានទម្ងន់៥០គីឡូក្រាម ត្រូវទឹកភ្លៀងរលាយអស់ នៅសល់តែ២០ ឬ៣០គីឡូក្រាមតែប៉ុណ្ណោះ ។ ឯប្រេងម៉ាស៊ូតវិញ បានចាក់ទឹកចូលធ្វើឲ្យប្រេងខូចគុណភាពប្រើការលែងកើត ។

ឆ្នាំ១៩៧៦ ប្រហែលជាខែមីនា អង្គការបានចាត់តាំង វ៉ាញ ឲ្យទៅធ្វើជាលេខាតំបន់១ ពេលនោះ វ៉ាញ ក៏បានយក សំ ទៅនៅជាមួយ និងបានចាត់តាំងឲ្យធ្វើជាប្រធានពាណិជ្ជកម្មតំបន់១ ។ នៅខែមេសា វ៉ាញ បានហៅ សំ ឲ្យទៅចូលរួមប្រជុំនៅលើភ្នំធិបតី ជាកន្លែងស្នាក់នៅរបស់ វ៉ាញ ដែលនៅពេលនោះមានសមាជិកចំនួន១១នាក់ ។ ចំពោះខ្លឹមសារនៃការប្រជុំលើកនេះ វ៉ាញ គ្រាន់តែចង់ធ្វើការណែនាំឲ្យសមាជិកទាំងអស់បានស្គាល់គ្នាជាខ្មែរសង្កាត់ ងាយនឹងទាក់ទងគ្នាពេលធ្វើសកម្មភាព និងបានដាក់ផែនការឲ្យកសាងកម្លាំងថែមទៀតប៉ុណ្ណោះ ។ ពេលត្រឡប់មកដល់កន្លែងវិញ សំ បានលើកពីការប្រជុំនេះ ប្រាប់ដល់ ភុន ទាំងផែនការ ទាំងខ្សែចាត់តាំងរបស់ វ៉ាញ ។

មួយខែក្រោយមក សំ និង ភុន អប់រំកម្លាំងបានបីនាក់មានឈ្មោះ ចាប ប្រធានឡានពាណិជ្ជកម្មតំបន់១, ជេត ជំនួយការទូទៅក្នុងពាណិជ្ជកម្មតំបន់១ និង សុវ៉ាន់ អនុប្រធានរោងម៉ាស៊ីនស្រូវឃុំឈើទាល ស្រុកសង្កែ ។ មូលហេតុដែលអាចអប់រំអ្នកទាំងបីបាន គឺដោយសារអ្នកទាំងបីមានប្រវត្តិមិនសូវល្អ សេរីខាងដើរដឹកស៊ី និងខូចសីលធម៌ជាមួយនារី ហើយត្រូវបានអង្គការដកចេញពីអង្គភាព និងទើបតែវិលត្រឡប់មកអង្គភាពវិញក្រោយថ្ងៃរំដោះ ។ បន្ទាប់មក សំ និង ភុន ក៏បានរាយការណ៍ប្រាប់ឲ្យ វ៉ាញ បានដឹងពីការណ៍ដែលខ្លួនអប់រំអ្នកទាំងបីបាន ។ ពេលនោះ វ៉ាញ បានណែនាំ សំ និង ភុន ឲ្យបន្តខិតខំកសាងកម្លាំងថែមទៀត ហើយពេលក្រោយខ្លួននឹងចុះមកជួយអប់រំអ្នកទាំងបីបន្ថែម ឲ្យអ្នកទាំងបីបានយល់កាន់តែច្បាស់ពីការចុះធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ ។ មួយខែក្រោយមក វ៉ាញ បានចុះមកជួប សំ និង ភុន នៅពាណិជ្ជកម្ម

តំបន់១ (នៅផ្សារបាត់ដំបង) និងបានពិភាក្សាគ្នាដោយពេលនោះ សំ បានហៅ ចាប, ផេត និង សុវ៉ាន់ ឲ្យមកជួបជាមួយ រ៉ាញ ដោយផ្ទាល់ ។ បន្ទាប់ពីបានជួបជុំគ្នាហើយ រ៉ាញ ក៏បានផ្តើមធ្វើការអប់រំដោយបាននិយាយថា យើងធ្វើបដិវត្តន៍ខំតស៊ូពីណាពីណើមក គឺយើងចង់បានភាពសម្បូរសប្បាយ គ្មាននរណាចង់បានការលំបាកវេទនាដូចសព្វថ្ងៃនេះទេ ។ យើងត្រូវតស៊ូម្តងទៀត ទើបយើងសម្បូរសប្បាយមានប្រាក់ខែប្រាក់ថ្ងៃដូចពីមុនអ៊ីចឹង ។ យើងចង់ធ្វើអី ក៏បាន ស្រេចតែចិត្ត ។ ក្រោយពីធ្វើការអប់រំរួចមក រ៉ាញ បានដាក់ផែនការឲ្យ សំ, ភុន, ចាប និង ផេត ឲ្យចុះប្រមូលស្រូវតាមសហករណ៍ឲ្យអស់ ។ ស្រូវមួយចំនួនត្រូវកិនយកអង្ករដើម្បីផ្តល់ទៅឲ្យខាងសមរភូមិមុខដែលកំពុងទប់ស្កឹងសង្កែ មួយចំនួនទុកនៅក្នុងឃ្លាំងធម្មតា ហើយមួយចំនួនទៀតដឹកទៅឲ្យ វឿន លាក់ទុកនៅភ្នំធិបតី ។ ចំណែក សុវ៉ាន់ ឲ្យនៅចាំរោងម៉ាស៊ីនស្រូវដដែល ។ ក្រោយពីបានទទួលផែនការពី រ៉ាញ មក សំ និងបក្ខពួកបួននាក់ទៀត បានចុះទៅប្រមូលស្រូវនៅតាមសហករណ៍រហូតដល់ខែកុម្ភៈ ឆ្នាំ១៩៧៧ ទើបឈប់ ។ ពេលប្រមូលស្រូវបានមក បានយកទៅទុកដាក់នៅឃ្លាំងតំបន់១ និងយកទៅឲ្យ វឿន លាក់ទុកនៅភ្នំធិបតីចំនួន៥០០០ បាវ និងអង្ករ ៣០០០បាវ ។ ដោយឡែកក្នុងការប្រមូលផលស្រូវ និងដឹកជញ្ជូនឡានចំនួនបីគ្រឿងត្រូវខូចម៉ាស៊ីន ប្រើការលែងកើត ។

ចុងខែកុម្ភៈ ឆ្នាំ១៩៧៧ រ៉ាញ បានហៅបក្ខពួកមកប្រជុំម្តងទៀតនៅភូមិឈើទាល ឃុំឈើទាល ស្រុកសង្កែ ដែលមានអ្នកចូលរួមចំនួន១៥នាក់ ។ បន្ទាប់ពីបានស្តាប់សេចក្តីរាយការណ៍របស់សមាជិកម្នាក់ៗដែលបានរាយការណ៍ពាក់ព័ន្ធនឹងការដើរប្រមូលស្រូវតាមសហករណ៍រួចមក រ៉ាញ បាននិយាយថា ផែនការវាយបដិវត្តន៍នៅឆ្នាំ១៩៧៦ យើងមិនបានធ្វើទេ ព្រោះបណ្តាលមកពីដាច់ខ្សែទាក់ទងគ្នា ដូច្នេះនៅឆ្នាំ១៩៧៧នេះ យើងត្រូវខំពង្រីកកម្លាំងថែមទៀតឲ្យបានច្រើន ចំណែកស្បៀង ក៏ត្រូវលាក់ឲ្យបានច្រើនដែរ មានស្រូវ អង្ករ ជាដើម ដើម្បីត្រៀមទុក ព្រោះជាទិសដៅរបស់យើង គឺត្រូវវាយបដិវត្តន៍នៅឆ្នាំ១៩៧៧នេះ ។ រ៉ាញ បានចាត់ឲ្យ សំ, ភុន, ចាប និង ផេត ឲ្យដើរប្រមូលអង្ករដែលនៅសល់ក្នុងសហករណ៍តំបន់១ ដែលប្រជាជនកិនទុកហូបកាលពីខែច្រូត ពេលប្រមូលរួចហើយ ត្រូវយកអង្ករដដែលនេះ មកចែកតាមសហករណ៍វិញ ដោយធ្វើការបែងចែកវាល់ជាកំប៉ុង គឺកម្លាំងទីមួយ រ៉ាញ ឲ្យហូបពីរកំប៉ុងកន្លះក្នុងមួយថ្ងៃ កម្លាំងទីពីរ ឲ្យហូបគ្នាដប់នាក់ ប្រាំបីកំប៉ុងសម្រាប់មួយពេល និងកម្លាំងទីបី ឲ្យហូបគ្នាដប់នាក់ ប្រាំមួយកំប៉ុងសម្រាប់មួយពេល ។ ចេញពីប្រជុំ សំ និងបក្ខពួក បានចុះអនុវត្តតាមផែនការ ដោយដើរប្រមូលអង្ករដែលនៅសល់តាមសហករណ៍ទាំងអស់នៅក្នុងតំបន់១ ហើយយកមកចែកតាមសហករណ៍វិញ ដោយអនុវត្តតាមផែនការខាងលើ ។ ក្នុងរយៈកាលនោះឃើញថា ប្រជាជនហូបមិនគ្រប់គ្រាន់ ហើយក៏បាននាំគ្នាយកដំឡូងមកហូបបន្ថែម ។ ប្រជាជនខ្លះក៏បានរត់ចេញពីសហករណ៍ ទៅកន្លែងផ្សេងទៀត តែត្រូវអង្គការចាប់បាន ពេលយកសួរនាំទៅគាត់បានប្រាប់តែពីរឿងខ្វះបាយហូបទើបរត់ចេញពីទីនេះ ។ ក្រោយដឹងពីហេតុការណ៍ហើយ អង្គការបានជួយជាស្រូវដល់តំបន់១ចំនួន១១០០០បាវ សម្រាប់ចែកដល់ប្រជាជនដែលខ្វះខាត ។ ពេលនោះ រ៉ាញ បានចាត់ឲ្យ សំ និងបក្ខពួកបួននាក់ទៀតដឹកស្រូវដែលជាជំនួយរបស់អង្គការតែ៦០០០បាវទេ មកចែកឲ្យប្រជាជន ចំណែកស្រូវ៥០០០បាវផ្សេងទៀត រ៉ាញ ឲ្យយកទៅលាក់ទុកនៅរោងម៉ាស៊ីនស្រូវស្រុកមោងឫស្សី ។

ប្រហែលជាចុងខែឧសភា ឆ្នាំ១៩៧៧ អង្គការបានដកយករ៉ាញ ទៅបាត់ ។ បន្ទាប់មក អង្គការក៏ចាប់ស្រាវជ្រាវរកមូលហេតុដែលសហករណ៍ខ្វះស្រូវ និងប្រជាជនខ្វះបាយហូប ។ ពេលនោះអង្គការបានហៅគណៈស្រុកទាំងអស់ក្នុងតំបន់១ ព្រមទាំង សំ ផងមកសាកសួរពីបញ្ហាខាងលើនេះ ។ ដោយឡែក ចំពោះ សំ អង្គការបានសួរនាំពីស្រូវដែលជាជំនួយរបស់អង្គការចំនួន១១០០០បាវ ថាយកទៅទីណាបានជាប្រជាជនហូបបានតែបីបួនថ្ងៃអស់ ។ ពេលនោះ សំ ក៏បានរាយការណ៍ជូនអង្គការតាមដំណើរដែល រ៉ាញ បានចាត់តាំងខ្លួនឲ្យធ្វើកិច្ចការនេះ ។ រួចពីនោះមក អង្គការបានឲ្យ សំ ទៅដឹកស្រូវដែលបានយកទៅលាក់ទុកនៅរោងម៉ាស៊ីនស្រូវស្រុកមោងទាំង៥០០០បាវនោះ យកមកចែកឲ្យប្រជាជនវិញ ។ នៅដើមខែកក្កដា ឆ្នាំ១៩៧៧ អង្គការក៏បានដក សំ ឲ្យទៅនៅក្នុងសហករណ៍បាយតាភុំ ក្នុងស្រុកសង្កែ ។ លុះដល់ថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៧៧ អង្គការក៏បានចាប់ខ្លួន សំ បញ្ជូនមកដាក់នៅមន្ទីរឃុំឃាំងតែម្តង ។ **ឆេង ទ៉េង**

# ការិយាល័យព័ត៌មានសាធារណៈ

*«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។*

*មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។*

*តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។*

*ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អ៊ុន សុដាវី តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthsodavy.u@dccam.org ។*





















# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
















*រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង ១០ ៖ ០០ ព្រឹក*

*ទីតាំង៖ អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖ អ៊ូច មករា ទូរសព្ទលេខ ៖ ០២៣ ២១១ ៨៧៥ អ៊ីម៉ែល ៖ truthmakara@dccam.org*

# វ៉ន ចេត ហៅ គូ អនុលេខាតំបន់៣ ភូមិភាគពាយ័ព្យ ជាប់ឃុំឃាំងនៅមន្ទីរស-២១

***ដកស្រង់ចេញពីឯកសារលេខ D៤១២៨៨***

*វ៉ន ចេត ហៅ គូ មានអាយុ៤៨ឆ្នាំ (គិតត្រឹមឆ្នាំ១៩៧៧) កើតនៅភូមិមលិុច ឃុំដីសាង ស្រុកប៉ៃលិន ខេត្តបាត់ដំបង ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មុនពេលចាប់ខ្លួន គូ ជាអនុលេខាតំបន់៣ ភាគពាយ័ព្យ ។ គូ ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ពីបទធ្វើសកម្មភាពជាមួយបក្ខពួកប្រឆាំងនឹងបដិវត្តន៍ ។ គូ ត្រូវបានបញ្ជូនមកឃុំឃាំងនៅមន្ទីរស-២១ នាថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ១៩៧៧ ក្រោយពេលចាប់ខ្លួនបានប្រហែលជាជិតមួយខែ ។ ក្នុងសេចក្តីកំណត់ហេតុនៃចម្លើយសារភាពរបស់ គូ មានចំនួន១៨ទំព័រ បែកចេញជាពីផ្នែក ។ ឯផ្នែកទី១ ជាសេចក្តីកំណត់ហេតុអំពីសភាពការណ៍ខ្សែក្បត់ដែលធ្វើការទាក់ទងជាមួយសៀម ដែលធ្វើដោយអ្នកសួរចម្លើយឈ្មោះ ស្រ៊ុម និងឈ្មោះ ហម ធ្វើរួចរាល់នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ មានចំនួន៩ទំព័រ ។ ផ្នែកទី២ សង្ខេបចេញពីចម្លើយសារភាពដោយអ្នកសួរចម្លើយឈ្មោះ ស្រ៊ុម ធ្វើចប់នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧៨ មានចំនួន ៩ទំព័រដូចគ្នា ។ ខាងក្រោមនេះ គឺជាសេចក្តីដកស្រង់ចេញពីចម្លើយសារភាពដែល គូ បានរៀបរាប់ពីសកម្មភាពរបស់ខ្លួនជាមួយបក្ខពួកក្បត់បក្ស៖*

*ពីតូចរហូតដល់មានអាយុ១៦ឆ្នាំ គូ រស់នៅជាមួយឪពុកម្តាយប្រកបរបរធ្វើស្រែ ។ នៅឆ្នាំ១៩៤៧ ពេលមានអាយុ១៧ឆ្នាំ គូ បានចូលធ្វើខ្មែរឥស្សរៈ រហូតដល់ឆ្នាំ១៩៥៤ នៅពេលដែលខ្មែរបានឯករាជ្យ គូ បានត្រឡប់មករស់នៅផ្ទះរបស់ខ្លួនវិញ ហើយប្រកបរបររកស៊ីកាប់ឈើហ៊ុបឲ្យមេឃុំដីសាងឈ្មោះ ណាក់ ។ ឆ្នាំ ១៩៥៨ គូ បានចូលធ្វើគិញឲ្យមេឃុំណាក់ នៅឃុំដីសាង ។ ក្រោយពីចូលធ្វើគិញឲ្យមេឃុំណាក់រួចមក គូ បានធ្វើការទាក់ទងជាមួយខ្សែរបស់មេឃុំណាក់មានឈ្មោះ តាជង់, ធួន, ស៊ីវ, ស៊ុ, ឈុត, នុត និងរិត រហូតដល់ឆ្នាំ១៩៥៩ ។*

*នៅឆ្នាំ១៩៦០ មេឃុំណាក់ និង ធួន បានទាំ គូ ទៅបញ្ចូលជាសមាជិក សេ.អ៊ី.អា នៅបន្ទាយត្រែង ដោយមានស័ក្តិ៣ ម៉ម លន់ ជាអ្នកទទួលស្គាល់ ។ ការបញ្ចូលនេះមានរៀបចំពិធីគោរពទង់ជាតិអាមេរិក ហើយភារកិច្ចដែលសមាជិក សេ.អ៊ី.អា ត្រូវធ្វើ គឺកសាងកម្លាំង សេ.អ៊ី.អា បន្ត និងឃោសនា បំផុសប្រជាជនមិនឲ្យគាំទ្របដិវត្តន៍ខ្មែរក្រហម ។ ក្រោយពីបានចូលជាសមាជិក សេ.អ៊ី.អា រួចមក ស័ក្តិ៣ ម៉ម លន់ បានខទ្មេសនាម គូ ឲ្យទៅទាក់ទងខ្សែរយៈបន្តមានឈ្មោះ ឌុល, ឈួន, លក, យ៉េង ។ ជាសកម្មភាពនៅពេលនោះ គូ, ឌុល និង ឈួន កសាងកម្លាំងបាន បួននាក់ ។*



*ស្ថិតិជនរងដែលត្រូវបានសម្លាប់នៅបឹងជើងឯក*

*ពីឆ្នាំ១៩៦១ ដល់ឆ្នាំ១៩៦៣ គូ បានបន្តទាក់ទងខ្សែរយៈចាស់ដដែល ដើម្បីធ្វើការតាមដានសកម្មភាពរបស់បដិវត្តន៍នៅក្នុងឃុំដីសាង ។ ក្រៅពីនេះ គូ បានចុះឡើងប្រជុំទទួល*

ផែនការញឹកញាប់ ដើម្បីរារាំងចលនាបដិវត្តន៍ពីស័ក្តិ៣ ម៉ន លន់ ហើយបានកសាងកម្លាំងថ្មីបានចំនួន៤នាក់ទៀត ។

ឆ្នាំ១៩៦៤ ស័ក្តិ៣ ម៉ម លន់ បានហៅ គូ និងបក្ខពួកមួយចំនួនឲ្យទៅជួបនៅបន្ទាយក្រែង ហើយបានចាត់តាំង គូ និង ហៀវ ឲ្យទៅទាក់ទងខ្មែរបដិវត្តន៍ ដើម្បីចូលបង្កប់ខ្លួននៅក្នុងជួរបដិវត្តន៍ ។ ដល់ឆ្នាំ១៩៦៥ គូ ត្រូវជាប់ជាមួយចលនាតស៊ូបដិវត្តន៍ជាមួយកម្មាភិបាលស្រុកឈ្មោះ សាយ តែការទាក់ទងជាមួយខ្មែរចាស់គឺ គូ នៅទាក់ទងជាធម្មតា ដើម្បីក្តាប់សភាពការណ៍របស់ខ្មែរក្រហម សំខាន់គឺរកវិធីកម្ទេចបដិវត្តន៍មិនឲ្យមានការរីកចម្រើន ។ សកម្មភាពរបស់ គូ ក្នុងឆ្នាំ១៩៦៥-១៩៦៦ នេះ គឺក្រៅពីការជួបជាមួយស័ក្តិ៣ ម៉ម លន់ និងមេឃុំណាក់ដើម្បីរាយការណ៍ គូ កសាងកម្លាំងថ្មីបានចំនួនបីនាក់ទៀត ។ បន្ទាប់មក គូ បានដឹងអំពីផែនការរបស់អង្គការដែលបានបំផុសប្រជាជនឲ្យរត់ចូលព្រៃទៅនៅភ្នំតូច ព្រោះ គូ មាននាទីជាមេឃុំនៅក្នុងជួរបដិវត្តន៍ តាមរយៈ សាយ ជាអ្នកចាត់តាំង ។ ហេតុនេះ គូ និង ហៀវ ក៏បានទៅជួបមេឃុំណាក់ និងស័ក្តិ៣ ម៉ម លន់ ដើម្បីផ្តល់ដំណឹង និងរៀបចំផែនការទប់ទល់ ដោយធ្វើការបំផុសប្រជាជនកុំឲ្យរត់ចូលព្រៃ និងត្រូវស៊ើបឲ្យដឹងផ្លូវសម្ងាត់របស់កម្មាភិបាលបដិវត្តន៍ចេញចូល ដើម្បីយកទាហានមកត្រៀមស្ទាក់ចាំចាប់ ។ តាមរយៈមេឃុំណាក់ គូ បានស្គាល់ សុង (អង្គការចាប់ហើយ) នៅឆ្នាំ១៩៦៦ និងឈ្មោះ ចាន់ ជាអនុលេខាចម្ការកប្បាស ភ្នំយ៉ាងប៉ាង ហើយបានបន្តការទាក់ទងគ្នានៅក្នុងខ្សែជាប់រហូត មក ។

ឆ្នាំ១៩៦៧ ក្នុងខែឧសភា មុនពេលដល់ថ្ងៃកំណត់ផែនការបាតុកម្មបីថ្ងៃ គូ និង ហៀវ បានទៅរាយការណ៍ឲ្យមេឃុំណាក់ និងស័ក្តិ៣ ម៉ម លន់ បានដឹងពីទិសដៅនៃការធ្វើបាតុកម្មនេះ ។ បន្ទាប់មក អ្នកទាំងពីរក៏បានទទួលផែនការពីស័ក្តិ៣ ម៉ម លន់ យកមកអនុវត្តដើម្បីរារាំងបាតុកម្មនេះ ដោយឲ្យពង្រាយកម្លាំង ដើម្បីបំបែកប្រជាជនមិនឲ្យនៅជុំគ្នា ។ តែបើនៅតែទប់មិនឈ្នះ ត្រូវបន្លំខ្លួនចូលក្នុងហ្វូងជាមួយប្រជាជន ហើយបំផុសប្រជាជនពីក្នុងព្រៃមកវិញ ។ ជាក់ស្តែង ពេលដែលប្រជាជនរត់ចូលព្រៃ គូ និងបក្ខពួកក៏ចូលជាមួយប្រជាជនដែរ ។ ស្របពេលដែលកំពុងអត់ស្បៀងផង គូ និងបក្ខពួកបានចលនាប្រជាជនឲ្យនាំគ្នាវិលត្រឡប់មកផ្ទះវិញអស់ ចំណែក គូ នៅធ្វើជាមេឃុំដដែល ។

ឆ្នាំ១៩៦៨ គូ និង ហៀវ បានទៅរាយការណ៍ឲ្យមេឃុំណាក់ និងស័ក្តិ៣ ម៉ម លន់ បានដឹងពីផែនការដែលបក្សឲ្យដុតស្ពាន និងស្ទាក់ចាំបាញ់ទាហានមកជួយ ពេលបក្សជម្លៀសប្រជាជនចូលព្រៃ ។ ក្រោយមក ប្រជាជនបាននាំគ្នារត់ចូលព្រៃម្តងទៀត ពេលនោះ គូ និងកម្លាំង សេ.អ៊ី.អា ផ្សេងទៀត ក៏ចូលមកក្នុងព្រៃនេះដែរ ។ បន្ទាប់មក នៅពេលដែលប្រជាជនអត់ស្បៀង គូ និងបក្ខពួកបានបំផុសប្រជាជនឲ្យរត់ទៅផ្ទះវិញ ហើយនៅពេលដែលប្រជាជនត្រឡប់មកវិញអស់ គូ បានចាត់ឲ្យ និត, ម៉េង, វើង, ឆ្អឹម និង ចើក ត្រឡប់មកក្រោយតាមប្រជាជនដែរ ដោយឲ្យមកភ្ជាប់ខ្សែរយៈជាមួយមេឃុំណាក់ រីឯខ្លួន, វិត និង ហៀវ នៅបង្កប់ខ្លួនក្នុងជួរបដិវត្តន៍ដដែល ។ ក្រោយមក គូ បានមកភ្ជាប់ខ្សែរយៈជាមួយ សាន នៅព្រៃកាញ្ចូង ហើយបានទទួលភារកិច្ចជាអ្នកយកក្ដួចមកឧបត្ថម្ភតាមការដ្ឋានទាំងអស់នៅភ្នំកាញ្ចូង ។ ក្រោយពីភ្ជាប់ខ្សែរយៈជាមួយ សានៗ បានណែនាំឲ្យស្គាល់ខ្សែមួយចំនួនទៀត និងបានរៀបចំផែនការគឺៈ ១) បំផ្លាញពេលវេលាធ្វើក្ដួច ដើម្បីឲ្យខ្វះខាតស្បៀង ២) បំផ្លាញស្រូវ មិនចែកជូនប្រជាជន ធ្វើឲ្យប្រជាជនរត់ចោលបដិវត្តន៍ ៣) ស្បៀងដែលរកបានហើយ ត្រូវពន្យាពេលឲ្យរលួយខូចអស់ និង ៤) ពង្រីកកម្លាំង ។ ឆ្លៀតក្នុងឱកាសនេះដែរ គូ កសាងកម្លាំងបានម្នាក់ឈ្មោះ ជុន អនុលេខាស្រុកអំពិល តំបន់៣ ។

ខែមីនា ឆ្នាំ១៩៧០ ក្រោយរដ្ឋប្រហារ សាន បានហៅ គូ, ហ៊ាង និង វិត មកប្រជុំដើម្បីស្រាវជ្រាវរកកម្លាំងចាស់ដែលចូលខ្លួនបង្កប់ក្នុងជួរបដិវត្តន៍ កសាងកម្លាំងថែមទៀត និងបំផុសប្រជាជនឲ្យអស់ជំនឿលើបដិវត្តន៍ ។ លុះដល់ខែកក្កដា អង្គការបានរៀបចំសមាសភាពថ្នាក់ដឹកនាំស្រុកប៉ៃលិន ដែលមានៈ ១) ហ៊ាង លេខា (ឆ្នាំ១៩៧៦ លេខាតំបន់៤ ចាប់ហើយ) ២) គូ អនុលេខា ៣) យិន សមាជិក ៤) កាង សមាជិក ។ បន្ទាប់មក សាន បានហៅបក្ខពួកទាំងអស់មកប្រជុំ ហើយបានខ្ទេសនាមឲ្យស្គាល់គ្នា ហើយបានណែនាំឲ្យអនុវត្តផែនការចាស់ជាបន្តទៀត ។ លុះដល់ចុងឆ្នាំ១៩៧០ គូ បានចុះទៅធ្វើការនៅឃុំជីសាង ហើយបានប្រមូលខ្សែរយៈចាស់ៗរបស់ខ្លួនមកចាត់តាំងបង្កប់តាមផែនការ ។

ឆ្នាំ១៩៧១ គូ, សាន, ហ៊ាង និង ឃិត បានរៀបចំផែនការបញ្ចូលខ្មែរចាត់តាំងឲ្យបង្កប់ខ្លួនក្នុងជួរយោធា និងកសាងកម្លាំងថ្មីបានចំនួនបីនាក់ ។ ក្រៅពីនេះ បក្ខពួករបស់ គូ បានធ្វើសកម្មភាពជម្លៀសប្រជាជន១០០គ្រួសារចេញទៅតំបន់ខ្មាំងកាន់កាប់វិញ ។ លុះដល់ចុងឆ្នាំ១៩៧១ អង្គការបានចាត់តាំង គូ និង សាន ឲ្យទៅរៀនសូត្រនយោបាយ ។ ក្នុងរយៈពេលសម្រាករៀននយោបាយ សាន បានហៅខ្មែរក្បត់ដែលមករៀនឲ្យបានជួបគ្នា ហើយបានខ្ទេសនាមឲ្យស្គាល់គ្នា និងបានណែនាំឲ្យកសាងកម្លាំងក្បត់ និងបំផ្លាញកម្លាំងរបស់បដិវត្តន៍ ។ មួយឆ្នាំក្រោយមក ក្រោយពីត្រឡប់មកពីរៀននយោបាយវិញ គូ បានមកទាក់ទងឈ្មោះ ណុប អនុលេខាតំបន់១ រៀបចំផែនការបំផុសប្រជាជនឲ្យរត់ទៅសៀម ។ ជាក់ស្តែង ក្រោយពីបំផុស ប្រជាជននៅម្តុំភូមិស៊ុន បានរត់ទៅសៀមអស់ចំនួន៣០០គ្រួសារ ដោយបានចាត់តាំងឈ្មោះ យ៉ក ជាអ្នកនាំប្រជាជនរត់ទៅ ។ ក្រៅពីនេះ បានទាក់ទង ណុប្ប លុយ និង ស៊ីកុន ធ្វើសកម្មភាពកសាងកម្លាំងថ្មីបានចំនួនពីរនាក់ ។

នៅឆ្នាំ១៩៧៣ គូ បានប្រគល់ខ្មែររបស់ខ្លួននៅស្រុកសំឡូត និង ប៉ៃលិន ឲ្យទៅឈ្មោះ ណុប គ្រប់គ្រងវិញ ព្រោះខ្លួនត្រូវទៅនៅតំបន់៣ ។ ក្នុងពេលផ្លាស់មកនៅតំបន់៣ គូ បានទទួលនាទីជាអនុលេខាតំបន់ ចំណែក អឿន ទទួលនាទីជាសមាជិកតំបន់ ។ នៅពេលនោះខ្មែរក្បត់ទាំងអស់ មានឈ្មោះ សាយ និង សានជាអ្នកដឹកនាំ ។ នៅខែឧសភា សាយ បានហៅខ្មែររយៈទាំងអស់មកប្រជុំ ដោយបានណែនាំឲ្យស្គាល់គ្នា ហើយបានដាក់ផែនការឲ្យពង្រីកកម្លាំង ដើម្បីរារាំងចលនាបង្កើតសហករណ៍របស់អង្គការ ។ ក្រោយមកគូរួមជាមួយ ស៊ាប កសាងកម្លាំងបានបីនាក់ ។

ឆ្នាំ១៩៧៤ ទន្ទឹមនឹងសភាពការណ៍យោធាកំពុងវាយខ្លាំង និងជម្លៀសប្រជាជនមកកាន់តំបន់រំដោះ គូ និងបក្ខពួក បានបំផុសប្រជាជនជាហូរហែ ឲ្យរត់ទៅតំបន់ខ្មាំងវិញអស់រាប់សិបគ្រួសារ ហើយបានទាក់ទងឈ្មោះ ខ្វែង រៀបចំផែនការ ដើម្បីបង្អាក់ដំណើររបស់ប្រជាជនមិនឲ្យចូលរស់នៅក្នុងតំបន់រំដោះ ដោយពេលកំពុងធ្វើការជម្លៀស ចាត់តាំងកម្លាំងមួយចំនួនឲ្យសម្ងំ គំរាមកំហែង និងឃោសនាមិនឲ្យប្រជាជនចូលទៅតំបន់រំដោះ ហើយ គូ ក៏បានចាត់កម្លាំងឲ្យបំផុសប្រជាជនដែលបានមកដល់តំបន់រំដោះមុន ឲ្យរត់ទៅតំបន់ខ្មាំងវិញ ដោយលើកពីការខ្វះស្បៀងអាហារ ។ បន្ទាប់មកគូ និងបក្ខពួក បានជម្លៀសប្រជាជនយកទៅដាក់ក្នុងព្រៃខុសពីគោលការណ៍ណែនាំរបស់បក្ស បណ្តាលឲ្យប្រជាជនស្លាប់អស់ជិត៥០០នាក់ ដោយសារការមិនដោះស្រាយបញ្ហាជីវភាព ។ នៅចុងឆ្នាំ១៩៧៤ បក្សមានផែនការឲ្យវាយផ្តាច់ផ្លូវជាតិលេខ៥ ពេលនោះ គូ បានប្រជុំបក្ខពួករបស់ខ្លួនដើម្បីរារាំងផែនការនេះ ដោយបានរៀបចំគម្រោងការវាយមិនឲ្យឈ្នះ និងចាត់ឲ្យឈ្មោះ នៅ ទាក់ទងទាហាននៅមង្គលបុរី ឲ្យមកកម្ទេចកម្លាំងទ័ពរបស់បដិវត្តន៍ ។

ក្រោយរំដោះ គូ បានទាក់ទងជាមួយ សាយ, សាន, អឿន, វ៉ាញ, អ៊ុយ, ឈុត, ស៊ាម និង លីម ដើម្បីរៀបចំផែនការបង្អត់បាយប្រជាជន ដោយបន្ថយរបប បំផុសប្រជាជនឲ្យរត់ទីកន្លែងមួយទៅកន្លែងមួយទៀត ឬរត់ទៅសៀម និងផែនការកសាងកម្លាំង ។ ពេលនោះដែរ សាយ បានខ្ទេសនាមឲ្យស្គាល់ឈ្មោះ ហឿន ជាប្រធានការដ្ឋានភ្នំសំពៅ ។ ក្រោយមក គូ បានទាក់ទងជាមួយឈ្មោះ រិត, ចុង និង ចាន់ ដើម្បីបំផ្លាញដំណាំកប្បាស ។ នៅចុងឆ្នាំ១៩៧៥ គូ បានចុះធ្វើការទាក់ទងខ្មែររយៈរបស់ខ្លួន និងអនុវត្តតាមផែនការជាបន្តបន្ទាប់ ។ ក្រៅពីនេះ គូ និងបក្ខពួកបានរៀបចំគម្រោងការសម្រាប់ឆ្នាំ១៩៧៦ គឺ៖ ១) វាយប្រហាររបបសមូហភាព ដោយចាត់តាំងប្រជាជនជាអ្នកមាន មេឃុំ អ្នករដ្ឋការ ឲ្យដើរចលនាតាមសហករណ៍ ២) បំផុតពាក្យស្លោកផ្សេងៗតាមសហករណ៍ វាយប្រហាររបបសមូហភាព ៣) ចាត់ឲ្យឈ្មោះ សាន ស្នើអង្គការនាំទ័ពទៅនៅព្រំដែន ដើម្បីងាយទាក់ទងខ្មែរខាងក្រៅវាយបកមកលើបដិវត្តន៍វិញ ដោយយកលេសថា ទៅវាយសៀម ។ បន្ទាប់ពីនេះ បន្តផែនការចាស់ គឺបំផ្លាញផែនការបីគោន និងប្រាំមួយគោនរបស់បក្ស ។

ឆ្នាំ១៩៧៦ គូ កសាងកម្លាំងបានបួននាក់ និងបានបន្តទាក់ទងជាមួយ រិត, ចុង និង ចាន់ ឲ្យបំផ្លាញដំណាំកប្បាសដោយមិនឲ្យបាញ់ថ្នាំការពារសត្វដង្កូវស៊ី ។ លើសពីនេះទៀត គូ បានសហការជាមួយ អឿន, ហឿន និង សំអាត ពិភាក្សារៀបចំផែនការបំផ្លាញស្រូវ៣.០០០ហិកតា ដោយប្រើវិធីបង្ហូរទឹកចេញអស់ពីស្រែធ្វើឲ្យស្រូវស្កក ហើយបានចាត់ខ្មែររបស់ខ្លួន ឲ្យនាំផ្លូវប្រជាជនរត់ទៅ

សៀមអស់រាប់រយគ្រួសារ បំផុសប្រជាជនឲ្យរត់ចេញពីសហករណ៍មួយទៅសហករណ៍មួយទៀត ធ្វើឲ្យសភាពការណ៍ច្របូកច្របល់ ។ ខែឧសភា មានការប្រជុំមួយនៅសូរ៉ាប៉ា មានអ្នកចូលរួមចំនួន១១ នាក់ ដែលខ្លឹមសារនៃការប្រជុំ គឺផ្តោតទៅលើផែនការវាយយកភាគពាយ័ព្យនាខែកក្កដា ឆ្នាំ១៩៧៦ ដែលមានឈ្មោះ ស៊ូ ជាអ្នកទាក់ទង សេ.អ៊ី.អា នៅក្រៅប្រទេស ។ ក្រោយពីប្រជុំរៀបចំផែនការមក គូ បានចុះទាក់ទងបក្ខពួកដើម្បីឲ្យត្រៀមជាស្បៀង និងបានបន្តអនុវត្តផែនការបំផ្លាញស្រូវ និងបញ្ជូនប្រជាជនឲ្យទៅស្រុកសៀម ។

**អំពីសភាពការណ៍ខ្មែរក្បត់ទាក់ទងជាមួយសៀម (រៀបរាប់ពីព្រឹត្តិការណ៍ប្រចាំថ្ងៃ)**

នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៧៧ គូ បានទៅជួប ខ្វៃង ជាលេខាកងពលទី២ របស់ភាគពាយ័ព្យនៅមន្ទីរ១៧ ខាងលិចក្រុងបាត់ដំបង ដើម្បីពិភាក្សាអំពីផែនការទាក់ទងជាមួយសៀម ។ លុះព្រឹកឡើងថ្ងៃទី២៧ គូ និងនីសារម្នាក់បានទៅជួប ខ្វៃង ម្តងទៀត ។ ជួបគ្នាបាន១៥នាទីក្រោយមក ខ្វៃង បានឲ្យនីសារទៅហៅ សុង ប្រធានសន្តិសុខភូមិឲ្យមកជួប ។ គូ បានទាក់ទងស្គាល់ សុង ជាខ្មែរ សេ.អ៊ី.អា តាមរយៈ សាន កាល សុង នៅធ្វើជាបញ្ជាការកងតូចយោធាតំបន់៣ ។ មុនពេលចេញដំណើរ ខ្វៃង, សុង និង គូ បានពិភាក្សាគ្នាម្តងទៀត ដោយពេលនោះ ខ្វៃង បានបញ្ជាក់ដោយខ្លីថា យើងធ្វើដំណើរទៅកំរៀង ហើយបន្តចេញទៅសៀម ដើម្បីទាក់ទងធ្វើផែនការថ្មី ។ បន្ទាប់មកអ្នកទាំងបីក៏ឡើងឡានហ្ស៊ីបរបស់ ខ្វៃង ចេញដំណើរទៅ ។ មកដល់ប៉ៃលិន ឈប់សម្រាកមួយម៉ោង ហើយបានជួបជាមួយ ហ៊ិន ប្រធានកងតូចដែលជាខ្មែរក្បត់ដែរ បន្ទាប់មកក៏ចេញដំណើរពីប៉ៃលិនតម្រង់ទៅវត្តកំរៀង ពេលនោះ ហ៊ិន ក៏បានរៀបចំអង្ករដាក់ឡានយកទៅកន្លែងរបស់ខ្លួននៅវត្តកំរៀងដែរ ។ គូ បានទៅដល់វត្តកំរៀងនៅម៉ោង១២កន្លះ ហើយបានជួបខ្មែរ សេ.អ៊ី.អា ម្នាក់នៅទីនោះឈ្មោះ ម៉ាប់ ជាបញ្ជាការកងធំវរសេនាតូច៣៦០ ។ គូ ក៏បានចាត់ឲ្យ ម៉ាប់ យកយោធាមួយកងតូចទៅយាមនៅតាមផ្លូវចូលមកព្រំដែនមិនឲ្យមានមនុស្សចេញចូល ឯពីរក្រុមទៀត យាមតាមបន្ទាត់ខ្សែព្រំដែនសងខាងផ្លូវចូលទៅសៀម និងមានយោធាមួយក្រុមផ្សេងទៀត យាមជុំវិញកន្លែងដែលណាត់ជួបជាមួយសៀម ។ នៅព្រឹកថ្ងៃបន្ទាប់ ហ៊ិន និងយោធាបីនាក់ទៀត បាននាំ ខ្វៃង, សុង និង គូ និងនីសារពីរនាក់ទៀតទៅជួបសៀមនៅរោងចម្ការរបស់ ម៉ុន ។ ពេលជូនទៅដល់ភ្លាម ហ៊ិន និងយោធាទាំងបីនាក់បានចេញពីទីនោះភ្លាមដែរ ។ ខាងសៀមមានពីរនាក់ឈ្មោះ សាក់ ស៊ិត ជាចៅហ្វាយខេត្ត មឿងចាន់ និងឈ្មោះ សាម៉ាត ស័ក្តិ៥ រីឯខាងខ្មែរមាន ខ្វៃង, សុង និង គូ ។ ការពិភាក្សាបានចាប់ផ្តើមដោយភាគីខាងខ្មែរបានស្នើឲ្យខាងសៀមរៀបចំកម្លាំង និងផែនការវាយអុកឡុកនៅតាមព្រំដែន និងវាយលុកចូលយកក្រុងបាត់ដំបង ដើម្បីស្តារកម្លាំង សេ.អ៊ី.អា ខាងក្នុង និងឆក់ឱកាសរៀបចំខ្សែសន្ទាក់ឡើងវិញ ។ ខាងសៀម សាក់ ស៊ិត បានឲ្យជាយោបល់ថា ចង់វាយក្រុងបាត់ដំបង ហើយជួយកម្លាំងខាងក្នុងបានលុះត្រាតែវាយយកទីក្រុងប៉ៃលិនជាមុន ធ្វើជាបង្អែកឲ្យបានរឹងមាំ ហើយយកទីក្រុងប៉ៃលិននេះ ជាមូលដ្ឋានកសាងកម្លាំងកងទ័ពថែមទៀត និងឈានទៅវាយយកក្រុងបាត់ដំបង ជាបន្ទាន់ដែរ ។

**ផែនការរបស់សៀមវាយយកក្រុងបាត់ដំបង ខែមករា-កុម្ភៈ ឆ្នាំ១៩៧៨**

**ការពិភាក្សាបានសម្រេចដូចខាងក្រោម ៖**

កម្លាំងពីក្រៅរៀបចំជាបីមុខព្រួញធំ ដោយយកទ័ព អ៊ិន តាំ និងស័ក្តិ៥ ហ៊ុល តួន ចេញមុខវាយយកក្រុងប៉ៃលិនជាដំបូង ឬទ័ពសៀម វាយសហការជាមួយគ្នា ។ មុខព្រួញទី១ ចូលតាមច្រកអូរឡាក់ ដោយទាក់ទងកម្លាំង សេ.អ៊ី.អា បង្កប់ខាងក្នុងមាន ម៉ាប់ អ្នកចាំទាក់ទង និងនាំផ្លូវ ។ មុខព្រួញទី២ ចូលតាមច្រកភ្នំខៀវ ត្រូវទាក់ទងជាមួយ ហ៊ិន និងមុខព្រួញទី៣ ចូលតាមច្រកភ្នំអំពង់ ឡើងតាមផ្លូវសាលាគ្រាវ ។ មុខព្រួញទី១ និងទី២ ទាក់ទង ហ៊ិន ព្រោះ ហ៊ិន នៅជិតគ្នា ហើយមុខព្រួញទាំងបីនេះ វាយសំដៅក្រុងប៉ៃលិន ពេលវាយបានក្រុមប៉ៃលិនសម្រេចហើយ ឈានទៅវាយយកក្រុងបាត់ដំបងភ្លាមដែរ ។ ក្រៅពីនេះ នៅមានមួយផ្នែកទៀតជាទ័ពសៀម គឺធ្វើការវាយលុកយកភ្នំម៉ាល័យទៀត ហើយតាមខ្សែព្រំដែន ពីភ្នំម៉ាល័យទៅខាងជើងអូរជ្រៅ គឺ គូ ធ្វើសកម្មភាពដោយកាណុង ។

**ផ្នែកកម្លាំង សេ.អ៊ី.អា នៅខាងក្នុងកម្ពុជា ៖**

ពេលផ្ទុះអាវុធតាមព្រំដែនវាយក្រុងប៉ៃលិន ត្រូវធ្វើសកម្ម

ភាពៈ ១) លួចបញ្ចេញកម្លាំងកងចល័តដែលបានរៀបចំទុកមុនឲ្យចេញមកសៀម និងចលនាបំផុសប្រជាជនតាមការដ្ឋាន សហករណ៍ឲ្យភៀសខ្លួនទៅសៀមដើម្បីប្រមូលជាកម្លាំងទ័ពបន្ថែមទៀត ២) បង្កើតឲ្យមានជាសភាពច្របូកច្របល់ ដោយបំផុសឲ្យយុវជន-យុវនារី ប្រព្រឹត្តអំពើពុករលួយ ខុសសីលធម៌ ពីសហករណ៍មួយទៅសហករណ៍មួយទៀត ធ្វើឲ្យខូចឥទ្ធិពលសន្តមបដិវត្តន៍ ៣) ធ្វើសកម្មភាពបំផ្លាញបដិវត្តន៍ ក្នុងសហករណ៍ឲ្យហិនហោច ៤) ឆកឱកាសនេះ ប្រមូល និងរៀបចំខ្មែរឡើងវិញ ៥) លាក់ស្រូវ អង្ករត្រៀមផ្តល់ឲ្យកម្លាំងទ័ពតាមលទ្ធភាព ។ ចំពោះសម្ភារសឹក និងស្បៀងពេលប្រយុទ្ធ គឺសៀមទទួលខុសត្រូវ ។ កម្លាំងខាងក្នុងសំខាន់ គឺប្រមូលកងចល័ត និងប្រជាជនបញ្ចេញមកសៀមឲ្យបានច្រើន ។ ការពិភាក្សាពីកិច្ចការនេះ មានរយៈពេលជាងពីរម៉ោងទើបចប់ ។ ចប់កិច្ចការជាមួយសៀម ខ្វែង, សុង និង គូ ក៏បានវិលត្រឡប់មកក្រុងបាត់ដំបងវិញ ។

ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៧៧ គូ បានទៅពិភាក្សាជាមួយ ខ្វែង នៅចម្ការចេករបស់ ខ្វែង ហើយបានសម្រេចហៅបក្ខពួកមកប្រជុំផ្សព្វផ្សាយផែនការនៅថ្ងៃបន្ទាប់ ។ នៅព្រឹកថ្ងៃទី៥ បន្ទាប់ពីសមាជិក សេ.អ៊ី.អា មកជុំគ្នាហើយ គូ បានផ្សព្វផ្សាយអំពីផែនការរបស់សៀមដែលត្រូវវាយយកក្រុងបាត់ដំបងនៅខែមករា-កុម្ភៈ ឆ្នាំ១៩៧៨ ឲ្យសមាជិកបានដឹង និងលើកជាផែនការត្រៀមអនុវត្ត គឺ៖ ១) តាមសហករណ៍ និងការដ្ឋាន គឺត្រូវជ្រើសរើសយកកម្លាំងនៅកងចល័តដែលមាននិន្នាការមិនល្អ ជាកូនចៅអតីតគិញ ជាកូនចៅទាហានចាស់ ប៉ូលីសចាស់ និងអ្នកដែលមានសាច់ញាតិត្រូវបដិវត្តន៍កម្ទេច មកប្រមូលផ្តុំតាមរូបភាពស្របច្បាប់ ដើម្បីដំណើរការអប់រំឲ្យមានកំហឹងនឹងបដិវត្តន៍ ។ ២) ចំណែកស្បៀង ត្រូវលាក់ស្រូវតាមរូបភាពស្របច្បាប់ក្នុងសហករណ៍ឲ្យបានច្រើន ដើម្បីត្រៀមផ្តល់ឲ្យកម្លាំងទ័ពពេលប្រយុទ្ធ ។

**សកម្មភាពត្រូវធ្វើនៅពេលផ្ទុះអាវុធ៖**

១) ឆក់ឱកាសពេលដែលកំពុងច្របូកច្របល់ រៀបចំខ្មែរចាស់ឡើងវិញឲ្យជាប់

២) ធ្វើសកម្មភាពបំផ្លាញផលស្រូវ និងអង្កររបស់សហករណ៍គ្រប់បែបយ៉ាង

៣) បំផុសចលនាប្រជាជន យុវជន យុវនារី ឲ្យច្របូកច្របល់បញ្ហាសីលធម៌ ដើម្បីបង្ខូចឥទ្ធិពលរបស់បដិវត្តន៍ ។

៤) ចលនាប្រជាជនទូទៅនៅក្នុងសហករណ៍ ការដ្ឋានឲ្យរត់ទៅសៀម ។ បន្ទាប់ពីប្រជុំចប់ សមាជិកទាំងអស់បានរំសាយទៅកន្លែងរៀងៗខ្លួន ។

នៅព្រឹកថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៧៧ គូ បានទៅទាក់ទងឈ្មោះ សិត ប្រធានកងចល័តតំបន់ និងបានណែនាំឲ្យ សិត រៀបចំមនុស្សនៅក្នុងកងចល័តតាមការដ្ឋាន និងសហករណ៍ដែលគេផ្ញើមកដាក់ដោយឡែក ងាយស្រួលអប់រំ និងឲ្យ សិត ធ្វើការណែនាំអង្គភាពនេះ តាមរូបភាពលាក់ការណ៍ ដោយបំផុសឲ្យមានកំហឹង មានគំនុំជាមួយរដ្ឋអំណាចបដិវត្តន៍ ដែលបានកម្ទេចសាច់ញាតិ បងប្អូន និងក្រុមគ្រួសាររបស់ខ្លួន ។ កងចល័តនេះ គូ បានចាត់តាំងឲ្យ សិត គ្រប់គ្រងស្របច្បាប់ និងពាក់កណ្តាលស្របច្បាប់ ដើម្បីអូសទាញកម្លាំងនេះទៅជាឧបករណ៍របស់ខ្មែរក្បត់នៅពេលខាងមុខ ។

ព្រឹកថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៧៧ គូ បានជួបឈ្មោះ ឆាំ ខ្មែរចាស់របស់ សាយ បច្ចុប្បន្នជាអនុប្រធានកសិកម្មរដ្ឋភ្នំសំពៅ និង ហៀរ ជាខ្មែររយៈចាស់ ដើម្បីប្រាប់ពីខ្លឹមសារនៃការប្រជុំកាលពីថ្ងៃទី៥ ។

ក្រោយពីបានណែនាំពីគម្រោងការក្បត់រួចហើយ គូ បានចាត់ឲ្យអ្នកទាំងពីរ អនុវត្តផែនការលាក់ស្រូវក្នុងសហករណ៍ឲ្យបាន៥០០តោនតាមរូបភាពស្របច្បាប់ ដើម្បីត្រៀមទុកសម្រាប់ផែនការទៅថ្ងៃមុខ ។ បន្ទាប់ពីបានធ្វើការណែនាំដល់អ្នកទាំងពីរហើយ គូ ក៏បានត្រឡប់មកផ្ទះរបស់ខ្លួនវិញ សម្រាកបានមួយថ្ងៃ បានទៅជួបខ្មែរចាត់តាំងចំនួនប្រាំនាក់ទៀត នៅសហករណ៍គោកឃ្មុំ ដែលជាកម្លាំងមិនទាន់ម្ចាស់ការក្នុងការធ្វើសកម្មភាពផ្សេងៗ ដោយបានធ្វើការអប់រំ និងពង្រឹងគោលជំហរ ស្មារតីបន្ថែមទៀត ហើយបានយកផែនការធំរបស់សៀមមកផ្សព្វផ្សាយ លើកទឹកចិត្ត និងណែនាំឲ្យធ្វើសកម្មភាព ដោយឲ្យរកវិធីបំផ្លិចបំផ្លាញសមិទ្ធផលបដិវត្តន៍ឲ្យបាន និងឲ្យឃោសនាបំផុសប្រជាជនឲ្យរត់ទៅនៅសៀម ។

ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៧ គូ បានទៅសហករណ៍ជ្រោយម្ទេស ដើម្បីជួប គឹម និង សៀប នៅផ្ទះរបស់ ស៊ាប ។ ពេលនោះ គូ បានលើកអំពីផែនការឲ្យអ្នកទាំងពីរធ្វើរួច និងបាន

អប់រំបន្ថែម គឺចាប់ពីពេលនេះទៅ ទោះបីជាសភាពការណ៍របស់កម្លាំងខាងក្រៅលេចចេញយប់ក្តី ថ្ងៃក្តី ត្រូវដឹកនាំកម្លាំង សេ.អុី.អា នៅក្នុងស្រុក ឲ្យឆាប់កម្រើកសកម្មភាពគ្រប់បែបយ៉ាង ។ ក្រោយពីណែនាំហើយ គូ បានវិលមកកន្លែងរបស់ខ្លួនវិញ ។

ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៧៧ គូ បានទៅជួប ខ្វង និង សុង នៅចម្ការបេក ។ ការណ៍ដែលទៅជួបនេះ គឺបានលើកអំពីផែនការស្រាវជ្រាវរកកម្លាំងណាដែលមានបងប្អូន ម៉ែឪ ជាប់និន្នាការត្រូវបានបក្សមានវិធានការ (តាមកម្ទេច) តាមការដ្ឋាន ដើម្បីយកមករៀបចំចាត់តាំងធ្វើជាគោលដៅ ហើយយកកម្លាំងនេះ ត្រៀមធ្វើផែនការវាយបដិវត្តន៍នៅខែមករា-កុម្ភៈ ឆ្នាំ១៩៧៨ ។ គូ ក៏បានពិភាក្សាពីបញ្ហាអាវុធ និងគ្រាប់រំសេវដែលត្រៀមបំពាក់ឲ្យកម្លាំងខាងលើ និងកម្លាំងចល័តមួយចំនួនរបស់ សិត ។ ការពិភាក្សាបានសម្រេចថា អាវុធដែលត្រៀមបំពាក់ឲ្យកងចល័តរបស់ សិត ខាង គូ នឹងយកទៅបំពាក់ឲ្យកងការពាររបស់ ផល គឺកំណត់យកអាវុធនៅក្នុងឃ្លាំងរបស់ភាគនៅចម្ការបេកដោយប្រគល់ឲ្យ សុង ជាអ្នករៀបចំ ។ ប៉ុន្មានថ្ងៃក្រោយពីត្រឡប់មកពីជួប ខ្វង វិញ គូ បានទៅជួប ហឿន និង ហៀវ នៅស្រុកភ្នំសំពៅម្តងទៀត ដើម្បីរំឭក អំពីផែនការដែលត្រូវអនុវត្តនាពេលខាងមុខ ។ បន្ទាប់មក គូ បានជួប សិត និងបានជំរុញឲ្យខិតខំអប់រំកងចល័តមួយកងធំនេះ ឲ្យបានឆាប់រហ័សដើម្បីបានបម្រើផែនការក្បត់ ។

នៅល្ងាចថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៧៧ គូ បានទៅបរិល ដែលជាកន្លែងយោធាតំបន់៣ ដើម្បីជួបឈ្មោះ ផន ប្រធានសេដ្ឋកិច្ចយោធាវរសេនាតូច៣៧០ ។ ពេលបានជួបហើយ គូ បានប្រគល់ភារកិច្ចឲ្យ ផន អនុវត្តគឺនៅពេលដែលកម្លាំងនៅខាងក្រៅផ្ទុះអាវុធវាយចូលក្រុងបាត់ដំបង សភាពការណ៍នឹងច្របូកច្របល់ ពេលនោះ ផន ត្រូវគេចចេញពីអង្គភាពទៅរួមដឹកនាំនៅផ្នែកកងចល័តតំបន់៣ ជាមួយ សិត ដើម្បីធ្វើសកម្មភាព ។ ព្រឹកថ្ងៃបន្ទាប់ គូ បានជិះម៉ូតូសំដៅទៅចម្ការបេកឯ បាត់ដំបងដែលជាកន្លែងរបស់ ខ្វង ស្នាក់នៅ ។ ពេលទៅដល់ជួបតែ ខ្វង ម្នាក់ទេ ពេលនោះ ខ្វង បានប្រើកុមារដែលជានីរសារឲ្យទៅហៅ សុង នៅមន្ទីរ១៧ ខាងលិចពេទ្យព-២ ។ មួយសន្ទុះក្រោយមក សុង ក៏បានជិះម៉ូតូសេអិលមកដល់ ការពិភាក្សាគ្នាក៏បានចាប់ផ្តើម ។ ជាដំបូង គូ បានសួរ ខ្វង បញ្ជាក់ថា តើកងសមាសភាព (សមាសភាពកងៈ សំដៅទៅកម្លាំងនៅក្នុងកងចល័តដែលមាននិន្នាការបងប្អូន ឪពុកម្តាយ និងសាច់ញាតិជាទាហាន ប៉ូលីស មន្ត្រី រដ្ឋការ និងគ្រូបង្រៀន ហើយដែលជាមុខព្រួញអង្គការតាមកម្ទេច) ដោយយើងរៀបចំជាខ្លឹមសារបម្រើផែនការរបស់យើង ដោយចាត់តាំងតាមរូបភាពជាកងការពារថែស្រូវនោះយ៉ាងណាហើយ? ពេលនោះ ខ្វង បានបញ្ជាក់ថា កម្លាំងនោះ សព្វថ្ងៃនៅជារូបភាពចំហជាកងថែផលដដែល យើងមិនទាន់អប់រំបានទាំងស្រុងទេ តែកម្លាំងនេះ បើសិនជាមានសមាសភាពមិនល្អ យើងអាចអប់រំបំផុសចលនាឲ្យប្រឆាំងបក្សបាន ។

ពេលនោះ សុង បានបន្ថែមថា កម្លាំងទាំងនោះ គឺយើងអាចប្រើការបានតែមួយអនុសេនាធំ ឯផ្សេងពីនេះ គឺជាកម្លាំងមិនទាន់ច្បាស់លាស់ទេ ។ ការពិភាក្សាបានសម្រេចដោយឲ្យក្តាប់ប្រវត្តិរូបឲ្យបានច្បាស់លាស់ ហើយជ្រើសរើសយកមកអប់រំបន្ថែមទៀតនៅក្នុងចំណោមមួយកងវរសេនាតូចនេះ យ៉ាងណាៗចាំជួបពិភាក្សាគ្នាបន្តនៅពេលក្រោយទៀត ការពិភាក្សាគ្នាត្រូវបានបញ្ចប់ ។ បន្ទាប់ពីនោះមក គូ បានចុះទៅជួប និងពង្រឹងខ្សែ សេ.អុី.អា នៅក្នុងតំបន់៣ ជាបន្តបន្ទាប់ ។

នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៧៧ គូ, ខ្វង និង សុង បានទៅទាក់ទងជាមួយសៀមម្តងទៀត ដើម្បីរៀបចំផែនការវាយយកភាគពាយ័ព្យនៅខែមីនា ឆ្នាំ១៩៧៧ ។ លើកនេះ ផែនការវាយយកប៉ៃលិនជាជំហានដំបូង និងពង្រីកទ័ពក្រុម ហ៊ុន ទោន តាមរយៈខ្សែខាងក្នុងបញ្ជូនឲ្យ ។ ផែនការនេះឲ្យកម្លាំងខាងក្រៅវាយដើម្បីឲ្យខ្សែខាងក្នុងមានពេលរៀបចំខ្សែសង្វាក់តាមការដ្ឋានសហករណ៍ឡើងវិញ ។ ក្រោយពីរៀបចំផែនការនេះហើយ គូ បានទាក់ទង សិត ឲ្យរៀបចំកម្លាំងចលនាត្រៀមចាំអនុវត្តផែនការវាយបដិវត្តន៍ និងបានចេញចូលទាក់ទងជាមួយ ខ្វង, សុង និងខ្សែផ្សេងៗទៀតនៅក្នុងតំបន់៣ ឲ្យត្រៀមស្បៀងជាបន្តបន្ទាប់ទៀតរហូតដល់ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ក៏ត្រូវបានអង្គការចាប់ខ្លួន និងបានបញ្ជូនមកឃុំឃាំងនៅក្នុងមន្ទីរស-២១ នាថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៧ ។

**ឆេង ទ៉េង**

# ពុទ្ធបរិស័ទប្រារព្ធធ្វើពិធីកាន់បិណ្ឌវេន
# ត្រូវនឹងថ្ងៃទី៥ ខែ









# ទីមួយ នៅវត្តលង្កា ក្នុងក្រុងភ្នំពេញ ខែកញ្ញា ឆ្នាំ២០១៧









# បុគ្គលិក និងនិស្សិតស្ម័គ្រចិត្តនៃវិទ្យាស្ថានកម្ពុជា ដើម្បី
# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កា









# កិច្ចសហប្រតិបត្តិការ និង សន្តិភាព ទស្សនកិច្ចសិក្សា
# លពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧









# ពិធីសម្ពោធពាក្យស្លោក និងបណ្ដុះបណ្ដាលគ្រូមុ
# ប្រជាធិបតេយ្យ (១៩៧៥-៧៩) នៅវិទ្យាល័យត្រពាំ









# បដ្ឋានស្តីពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជា ងប្រាសាទ កាលពីថ្ងៃទី២៥-២៧ ខែកញ្ញា ឆ្នាំ២០១៧









# ដើម្បីទទួលអំណរខួបទី១៧ដ៏មហាជោគជ័យនៃកំណើតបក្សកុម្មុយនីស្តកម្ពុជា យុវជន-យុវនារីបដិវត្តន៍យើង ប្តេជ្ញាខិតខំកសាងខ្លួនឱ្យបានល្អតាមគោលជំហរបដិវត្តន៍របស់បក្សយើង ដើម្បីបន្តវេនបដិវត្តន៍ឱ្យក្រហមឆ្អិនឆ្អៅជារៀងរហូត

*ដកស្រង់ចេញពីឯកសារទស្សនាវដ្តី យុវជន និង យុវនារី បដិវត្តន៍ លេខពិសេស ខែកញ្ញា ឆ្នាំ១៩៧៧ D២១៤០៣*

ថ្ងៃ៣០ ខែកញ្ញា ឆ្នាំ១៩៧៧នេះ ជាថ្ងៃខួបកំណើតឆ្នាំទី១៧ នៃបក្សកុម្មុយនីស្តកម្ពុជា ដ៏មហាជោគជ័យ ។ អាយុ១៧ឆ្នាំ បើប្រៀបធៀបនឹងអាយុមនុស្សយើង គឺជាវ័យក្មេងខ្ចីណាស់ ។ ប៉ុន្តែ បក្សកុម្មុយនីស្តកម្ពុជា មានពិសោធដឹកនាំចលនាតស៊ូបដិវត្តន៍បត់បែន ស្មុគស្មាញ លំបាកវេទនាច្រើនឥតគណនា ។ ដូច្នេះ បក្សកុម្មុយនីស្តកម្ពុជាយើងមានពិសោធជ្រាលជ្រៅណាស់ក្នុងការដឹកនាំចលនាបដិវត្តន៍ នៅគ្រប់រយៈកាលតស៊ូបដិវត្តន៍ ។

ចាប់តាំងពីកកើតភ្លាមម៉្លេះ បក្សកុម្មុយនីស្តកម្ពុជាយើង បានពុះពារគ្រប់ឧបសគ្គតូចធំ ច្រើនរាប់មិនអស់ ហើយបានធ្វើពលិកម្មសព្វបែបយ៉ាង ជាបន្តបន្ទាប់ ប្រយុទ្ធដឹកនាំប្រជាជនកម្ពុជា ពិសេសប្រជាជន កម្មករ ពលករ និងកសិករក្រីក្រ ធ្វើការតស៊ូបដិវត្តន៍ យ៉ាងអង់អាចក្លាហាន ហើយដណ្តើមបានជ័យជម្នះធំៗ


កម្មករនៅក្នុងរោងចក្រ កំពុងកូរទឹកជ័រកៅស៊ូ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

ជាបន្តបន្ទាប់ រហូតដល់ដណ្តើមបានជ័យជម្នះទាំងស្រុង និងជាស្ថាពរ នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ កន្លងទៅនេះ ។ ដោយឡែកតែចំពោះយុវជន-យុវនារីកម្ពុជាយើង បក្សបានយកចិត្តទុកដាក់ឃោសនាអប់រំ បំពាក់បំប៉នទាំងគោលជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងជាប់ជានិច្ច ធ្វើឲ្យយុវជន-យុវនារីកម្ពុជាយើង មានការភ្ញាក់រលឹកបដិវត្តន៍ជាបន្តបន្ទាប់ ។ យុវជន-យុវនារីកម្ពុជាយើង ដែលត្រូវចក្រពត្តិអាណានិយគមនិយមចាស់ថ្មី វណ្ណៈសក្តិភូមិ និងវណ្ណៈនាយទុន ដែលជាវណ្ណៈកាន់អំណាចក្បត់ជាតិ ក្បត់ប្រជាជន ជិះជាន់ គាបសង្កត់ បំបិទសិទ្ធិសេរីភាព និងបំពុកបំពុលឲ្យពាលាអាវ៉ាសែ ឲ្យងងឹតងងុល វង្វេងវង្វាន់ ភ្លេចកំណើតជាតិឯង ភ្លេចប្រទេសជាតិឯង និងប្រជាជនឯង ហើយធ្លាក់ទៅក្នុងអំពើអបាយមុខសព្វបែបយ៉ាង រាប់សតវត្សរ៍មកហើយ ត្រូវបានបក្សកុម្មុយនីស្តកម្ពុជា ស្រោចស្រង់ឲ្យមានជីវិត មានខ្លឹមសារ ដើរតាមផ្លូវត្រឹមត្រូវ និងក្នុងកិត្តិយសថ្លៃថ្នូរមកវិញ ។ ដោយសារបក្សកុម្មុយនីស្តកម្ពុជា យកចិត្តទុកដាក់ឃោសនាអប់រំ បំពាក់បំប៉នជាប់ជាប្រចាំ យុវជន-យុវនារីកម្ពុជាយើង ក៏មានស្មារតីស្នេហាជាតិ ស្នេហាប្រជាជន មើលឃើញនូវទុក្ខវេទនាមួយរយ មួយពាន់ជំពូក ដែលប្រទេសជាតិ និងប្រជាជនកំពុងឆ្លងកាត់ ស្គាល់មិត្ត ស្គាល់សត្រូវ របស់ប្រទេសជាតិ និងប្រជាជនខ្លួនយ៉ាងច្បាស់លាស់ ។ ដូច្នេះ យុវជន-យុវនារីកម្ពុជាយើង ក៏មានកំហឹងឆាបឆេះ ពុះពោរ សន្ធោសន្ធៅ ចំពោះខ្មាំងសត្រូវប្រទេសជាតិ ដែលជាចក្រពត្តិ អាណានិគមនិយមចាស់ថ្មី ពិសេសចក្រពត្តិអាមេរិក និងបរិវារ និងខ្មាំងសត្រូវវណ្ណៈ ដែលជាវណ្ណៈសក្តិភូមិ វណ្ណៈនាយទុន និងវណ្ណៈជិះជាន់ផ្សេងទៀត ។ យុវជន-យុវនារីកម្ពុជាយើង ក៏ចាប់ផ្តើមមានពន្លឺភ្លឺស្វាង មើលឃើញច្បាស់ ផ្លូវដ៏ត្រឹមត្រូវ និងល្អបរិសុទ្ធ ដែលខ្លួនត្រូវប្រកាន់យក ដើម្បីរំដោះប្រទេសជាតិ រំដោះប្រជាជន រំដោះវណ្ណៈក្រីក្រ ក៏ដូចជាដើម្បីកិត្តិយសថ្លៃថ្នូរចំពោះយុវជន-យុវនារីកម្ពុជាយើងដែរ ។ ពោលគឺធ្វើបដិវត្តន៍ដាច់ខាតវាយកម្ទេចខ្មាំងសត្រូវគ្រប់ប្រភេទទាំងអស់ ឲ្យបរាជ័យរលំរលាយអស់ពីលើទឹកដីកម្ពុជាយើងទាំងស្រុង ។ ដូច្នេះហើយ បានជាចាប់តាំងពីពេលមានបក្សកុម្មុយនីស្តកម្ពុជា ដឹកនាំចលនាតស៊ូបដិវត្តន៍ កាលណាមក យុវជន-យុវនារីកម្ពុជាយើង ពិសេសយុវជន-យុវនារីដែលជាកូនចៅប្រជាជនក្រីក្រ បានលះបង់គ្រួសារ ម៉ែឪ បងប្អូន ផ្ទះសម្បែង លះបង់ផលប្រយោជន៍ស្ទួនតួផ្ទាល់ខ្លួន ចូលបម្រើបុព្វហេតុបដិវត្តន៍យ៉ាងអង់អាចក្លាហាន សស្រោកសស្រាំជាប់ជារៀងរហូតមក ។ ដូច្នេះ យុវជន-យុវនារីបដិវត្តន៍យើងទាំងអស់ ក៏បានក្លាយខ្លួនពីចំណីខ្មាំង មកជាយុវជន-យុវនារីស្នេហាជាតិឈានមុខក្នុងកិច្ចការបដិវត្តន៍តូច-ធំទាំងអស់ និងជាយុវជន-យុវនារីដែលមានការភ្ញាក់រលឹកបដិវត្តន៍ខ្ពស់ ។ នេះហើយជាកិត្តិយសរុងរឿង ឧត្តុង្គឧត្តមរបស់យុវជន-យុវនារីកម្ពុជាយើងជំនាន់នេះ ។ កិត្តិយសទាំងអស់នេះ គឺពិតជាបានមកដោយសារបក្សកុម្មុយនីស្តកម្ពុជាដ៏ត្រឹមត្រូវ និងភ្លឺស្វាងមហាអស្ចារ្យ ។ បើគ្មានបក្សកុម្មុយនីស្តកម្ពុជាដឹកនាំត្រឹមត្រូវ និងភ្លឺស្វាងយ៉ាងនេះទេ នោះប្រហែលជាប្រទេសជាតិកម្ពុជាយើង ប្រជាជនកម្ពុជាយើង នឹងស្ថិតនៅជាខ្ញុំកញ្ជះចក្រពត្តិបរទេស ពិសេសចក្រពត្តិអាមេរិក និងបរិវារ ជារៀងរហូតទៅហើយ ។ ម្ល៉េះសមប្រជាជនកម្ពុជា និងយុវជន-យុវនារីកម្ពុជាយើង រស់នៅរងទុក្ខវេទនា ឈឺចាប់ខ្លោចផ្សា អាប់ឱនកិត្តិយស គ្មានពេលណាងើបមុខងើបមាត់នឹងគេរួចឡើយ ។ ម្ល៉េះសមយុវជន-យុវនារីកម្ពុជាយើងជំនាន់នេះ នឹងក្លាយទៅជាចំណីខ្មាំង ដែលគ្មានលក្ខណៈ និងធាតុពិតជាជាតិមួយ សាសន៍មួយនឹងគេឡើយ ។ ប្រទេសជាតិមាតុភូមិកម្ពុជា ជាទីស្នេហា ម្ល៉េះសមនឹងត្រូវវិនាសខ្ទាត់ខ្ទាយ បាត់បង់អស់នូវទឹកដី ព្រលឹងជាតិ រហូតដល់ត្រូវវិនាសសាបសូន្យឈ្មោះជាខ្លាំងអស់ពីលើផែនទីសកលលោកថែមទៀតផង ។

ប៉ុន្តែ ដោយសារមានបក្សកុម្មុយនីស្តកម្ពុជា ដ៏មហារុងរឿង ដឹកនាំតាមមាគ៌ាត្រឹមត្រូវ និងភ្លឺស្វាងមហាអស្ចារ្យ មាតុភូមិកម្ពុជាជាទីស្នេហានៃយើង ត្រូវបានរំដោះទាំងស្រុង និងជាស្ថាពរនៅថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥ ។ ប្រទេសកម្ពុជាយើងមានឋានៈជាប្រទេសមួយ ឯករាជ្យ មានអធិបតេយ្យភាពបរិបូរណ៍ក្នុងបូរណភាពដែនដីពិតប្រាដករបស់ខ្លួន ។ ប្រជាជាតិកម្ពុជាដែលធ្លាប់តែជាខ្ញុំគេរាប់សតវត្សរ៍មកហើយ ធ្លាប់តែត្រូវគេជាន់ពន្លិច វាយពន្លឹបថោកទាបអាប់ឱនកិត្តិយស ពុំដែលមានពេលណាងើបមុខរួចនឹងគេម្តងសោះនោះ ឥឡូវក៏បានក្លាយទៅជាប្រជាជាតិមួយ ឯករាជ្យម្ចាស់ការពេញទី ហើយមានកិត្តិនាម កិត្តិសព្ទល្បីល្បាញខ្ទរខ្ទារទូទាំងប្រទេស និងពេញទាំងសកលលោក ។ ប្រជាជនកម្ពុជាដែលធ្លាប់តែរស់នៅ

រងទុក្ខវេទនា ក្នុងខ្ទុះឈាម ភក់ជ្រាំ ក្រោមរបបជិះជាន់ ហ្វាស៊ីស ផ្ដាច់ការ របស់អាណានិគមនិយម ចក្រពត្តិនិយម វណ្ណៈសក្តិភូមិ វណ្ណៈនាយទុនជាងពីរពាន់ឆ្នាំមកហើយនោះ ឥឡូវក៏បានឡើងទៅជាម្ចាស់ប្រទេស ម្ចាស់បដិវត្តន៍ ម្ចាស់ទឹកដីព្រៃព្រឹក្សា និងស្រែចម្ការរបស់ខ្លួនពេញទីហើយ ហើយបានកាន់កាប់វាសនាអនាគតប្រទេសជាតិខ្លួន និងប្រជាជនខ្លួនយ៉ាងណែននៅក្នុងដៃដោយខ្លួនឯងហើយ ។ ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងមហាអស្ចារ្យនៃបក្សកុម្មុយនីស្តកម្ពុជាយើង ប្រជាជនកម្ពុជា ដែលធ្លាប់តែត្រូវគេមើលងាយមើលថោក បន្តុះបង្អាប់ថាជាប្រជាជនមួយ ទន់ខ្សោយ ល្ងិតល្ងង់ និងខ្ជិលច្រអូសនោះ បានបង្ហាញយ៉ាងច្បាស់នូវសមត្ថភាពខ្លួន ក្នុងការធ្វើសង្គ្រាមរំដោះប្រទេសជាតិ ក៏ដូចជាក្នុងការវាយកម្ទេចសង្គ្រាមឈ្លានពាន ដ៏កំណាចឃោរឃៅ ហ្វាស៊ីសអស្ចារ្យរបស់ចក្រពត្តិអាមេរិក ដែលជាមេក្លោងចក្រពត្តិធំជាងគេក្នុងសកលលោក ។ ក្រោយរំដោះប្រទេសជាតិបានទាំងស្រុង និងជាស្ថាពរហើយ ប្រជាជនកម្ពុជាយើង ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជា ក៏បានបង្ហាញឲ្យឃើញច្បាស់នូវសមត្ថភាពរបស់ខ្លួនក្នុងកិច្ចការពារប្រទេស និងកសាងប្រទេសឲ្យរីកចម្រើនលូតលាស់លើគ្រប់វិស័យផងដែរ ។ តាមរយៈនេះ អត្តភាព និងកិត្យានុភាពរបស់ប្រជាជាតិ និងប្រជាជនកម្ពុជា ក៏បានលេចធ្លោឡើងខ្ពស់ត្រដែតត្រដឹមនៅទូទាំងប្រទេស និងនៅលើសកលលោកទាំងមូល ។ ព្រឹត្តិការណ៍ទាំងអស់នេះ ជាព្រឹត្តិការណ៍ថ្មី និងធំសម្បើមអស្ចារ្យ មានអត្ថន័យជាប្រវត្តិសាស្ត្រ ហើយដែលពុំធ្លាប់មានទេ ក្នុងប្រវត្តិសាស្ត្រកម្ពុជាយើងជាងពីរពាន់ឆ្នាំមកហើយ ។ ទាំងអស់នេះ គឺពិតជាបានមកដោយសារការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងរបស់បក្សកុម្មុយនីស្តកម្ពុជាយើង ។ ដូច្នេះ ប្រជាជន និងយុវជន-យុវនារីកម្ពុជាយើង សូមថ្លែងនូវកតញ្ញូគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះបក្សកុម្មុយនីស្តកម្ពុជា ជាទីគោរពស្នេហា គ្មានពេលណាបំភ្លេចបានឡើយ ។ ក្នុងឱកាសបុណ្យខួបទី១៧ នៃកំណើតបក្សកុម្មុយនីស្តកម្ពុជាដ៏មហាជោគជ័យនេះ ដែលបក្សប្រកាសចេញចំហជាផ្លូវការលើកដំបូងបំផុត នៅក្នុងប្រទេសក៏ដូចនៅលើសកលលោកទាំងមូល យើងខ្ញុំជាយុវជន-យុវនារីបដិវត្តន៍កម្ពុជា សូមបន្លឺនូវជ័យឃោស អបអរសាទរ និងរំភើបរីករាយក្នុងចិត្តឥតឧបមា ចំពោះថ្ងៃប្រវត្តិសាស្ត្ររបស់បក្ស ជាទីគោរពស្នេហានៃយើងនេះ ។ យុវជន-យុវនារីបដិវត្តន៍កម្ពុជាយើង បានស្គាល់ បានដឹង និងបានឃើញបក្សកុម្មុយនីស្តកម្ពុជាយើងថាជាបក្សត្រឹមត្រូវ ភ្លឺស្វាង ដែលមានវីរភាពខ្ពង់ខ្ពស់បំផុត និងដែលបានធ្វើពលិកម្មយ៉ាងធំធេងអស្ចារ្យជារៀងរហូតមក ដើម្បីដឹកនាំប្រជាជនកម្ពុជា និងយុវជន-យុវនារីកម្ពុជាយើងខ្ញុំ ធ្វើការតស៊ូបដិវត្តន៍យ៉ាងខ្លាំងក្លាសន្ធោសន្ធៅក្នុងគ្រប់កាលសម័យតស៊ូបដិវត្តន៍ វាយខ្មាំងសត្រូវគ្រប់ប្រភេទដណ្តើមបានជ័យជម្នះ ជាបន្តបន្ទាប់ជាប់មិនដាច់ ។ យើងខ្ញុំជាយុវជន-យុវនារីបដិវត្តន៍កម្ពុជា មានមនោសញ្ចេតនាបដិវត្តន៍ជ្រាលជ្រៅបំផុត គោរពស្រឡាញ់ ដឹងគុណចំពោះបក្សតាំងពីដើមរៀងមក ។ យើងខ្ញុំទាំងអស់គ្នាក៏តែងរង់ចាំពេលវេលា និងថ្ងៃដែលបក្សប្រកាសចេញជាចំហតាំងពីយូរណាស់មកហើយ ។ ដូច្នេះ ក្នុងឱកាសថ្ងៃខួបទី១៧ នៃកំណើតបក្សកុម្មុយនីស្តកម្ពុជាដ៏មហាជោគជ័យនេះ ហើយដែលបក្សប្រកាសចេញជាចំហលើកដំបូងនេះដើម្បីជាកិច្ចតបស្នងសងគុណចំពោះបក្ស និងដើម្បីសម្តែងនូវមនោសញ្ចេតនា រំភើបរីករាយឥតឧបមា យុវជន-យុវនារីបដិវត្តន៍កម្ពុជាយើងខ្ញុំជំនាន់នេះ ប្តេជ្ញាថា និងខិតខំកសាងខ្លួនឲ្យបានល្អ តាមគោលជំហរបដិវត្តន៍របស់បក្ស ដើម្បីបន្តវេនបដិវត្តន៍ឲ្យក្រហមឆ្អិនឆ្អៅជារៀងរហូត ដើម្បីការពារប្រទេស ការពារប្រជាជន ការពារបដិវត្តន៍ និងការពារបក្សកុម្មុយនីស្តកម្ពុជាដ៏ត្រឹមត្រូវនៃយើងនេះ ឲ្យបានស្ថិតស្ថេរគង់វង្ស និងរឹងប៉ឹង ខ្លាំងក្លា ថ្កុំថ្កើង រុងរឿងជារៀងរហូតអង្វែងកាលតទៅ ។

ដើម្បីកសាងខ្លួនឲ្យបានល្អ តាមគោលជំហរបដិវត្តន៍ដ៏ត្រឹមត្រូវរបស់បក្ស យុវជន-យុវនារីកម្ពុជាយើងចាំបាច់ត្រូវស្គាល់ខ្លួនឲ្យបានច្បាស់ និងត្រូវមានទស្សនៈ គោលជំហរត្រឹមត្រូវមួយចំនួនដូចតទៅ ៖

១) យុវជន-យុវនារីយើងទាំងអស់ គឺសុទ្ធតែស្ថិតនៅក្នុងវ័យយុវភាពក្លៀវក្លា (គិតពីអាយុ១៨ឆ្នាំ រហូតទៅទល់នឹងអាយុ៣០ឆ្នាំ) ។ ក្នុងវ័យនេះ យុវជន-យុវនារីយើងមានកម្លាំងកាយខ្លាំងក្លា ស្វាហាប់ មានកម្លាំងចិត្តក្លៀវក្លា និងអង់អាចក្លាហានណាស់ ។ តែបើហួសពីអាយុនេះទៅ មិត្តយើងនឹងឈានចូលដល់វ័យកណ្ដាលរូបទៅវ័យចាស់ជរាហើយ ។ ឯកម្លាំងកាយ កម្លាំងចិត្ត ក៏នឹងថមថយ

ជាលំដាប់ដែរ ។ ដូច្នេះ យុវជន-យុវនារីយើង ត្រូវចេះប្រើប្រាស់យុវវ័យនេះ ឲ្យអស់លទ្ធភាព ឲ្យមានប្រយោជន៍ ជាអតិបរមាដល់ប្រទេសជាតិប្រជាជន និងចលនាបដិវត្តន៍កម្ពុជាយើង កុំឲ្យដល់ចាស់ទៅនឹកស្តាយក្រោយ ។

(២) ក្នុងវ័យយុវភាពនេះ យុវជន-យុវនារីយើងឆាប់ទទួលណាស់ នូវរបស់អ្វីដែលថ្មី ថ្មីជាល្អ ឬថ្មីជាមិនល្អ ។ ចូលចិត្តសម្លឹងមើលសង្គមកម្ពុជាយើងបច្ចុប្បន្ននេះ មានការវិវត្ត ប្រែប្រួលសម្បើមអស្ចារ្យទៅខាងផ្លូវល្អ ផ្លូវរីកចម្រើនដូចយើងបានរៀបរាប់ពីខាងលើស្រាប់ ។ ឧទាហរណ៍ៈ សង្គមកម្ពុជាបានវិវត្តប្រែប្រួលពីសង្គមអាណានិគមពាក់កណ្តាលសក្តិភូមិមកជាសង្គមសង្គមនិយមដែលប្រជាជនប្រុសស្រី ក្មេងចាស់គ្រប់រូប រស់នៅស្មើភាពគ្នាមានសុភមង្គល កិត្តិយសថ្លៃថ្នូរដូចៗគ្នា ។ ប្រជាជនកម្ពុជាដែលធ្លាប់តែរស់នៅក្រខ្សត់ អត់ឃ្លាន ឈឺចាប់ខ្លោចផ្សា និងអាប់ឱនកិត្តិយសបាត់ឈ្មោះបោះសំឡេង រាប់សតវត្សរ៍មកហើយ ក្រោមនឹមដែករបស់ចក្រពត្តិអាណានិគមនិយមចាស់ថ្មី ក៏បានឡើងធ្វើជាម្ចាស់ប្រទេសម្ចាស់បដិវត្តន៍ កាន់កាប់វាសនាប្រទេសជាតិ និងប្រជាជនខ្លួនដោយដៃផ្ទាល់ ហើយមានសិទ្ធិចាត់ចែងការងារសព្វបែបយ៉ាង ដើម្បីការពារប្រទេស និងកសាងប្រទេសជាតិខ្លួន ឲ្យរីកចម្រើន លូតលាស់លើគ្រប់វិស័យ ដោយឯករាជម្ចាស់ការ ខ្លួនទុកត្តម្ខ្លួនពេញទី ។ បច្ចុប្បន្ននេះ ប្រជាជនកម្ពុជាយើង កំពុងវាយសម្រុកការពារប្រទេសនិងកសាងប្រទេសយ៉ាងខ្លាំងក្លាសស្រោកសស្រាំ ទាំងយប់ទាំងថ្ងៃ ទាំងប្រាំង ទាំងវស្សា ដោយគោលជំហរវីរភាពខ្ពង់ខ្ពស់អស្ចារ្យ និងដោយជំហរលះបង់ផលប្រយោជន៍សួនតួ និងលះបង់អ្វីៗទាំងអស់ ដើម្បីប្រទេសជាតិ ដើម្បីបដិវត្តន៍ ដោយឥតលក្ខខណ្ឌ ។ ចំណែកឯទឹកដី ព្រៃព្រឹក្សានៃមាតុភូមិកម្ពុជាយើង ក៏កំពុងប្រែក្លាយទៅជាសួនស្រូវ និងសួនដំណាំ ស្រស់បំព្រងគ្រប់រដូវនៅគ្រប់ទីកន្លែងហើយ ។ សហករណ៍ កសិករយើង ដែលជាមូលដ្ឋាន និងជាគ្រឹះយ៉ាងរឹងមាំនៃរបបសង្គមនិយមនៅកម្ពុជាយើង បច្ចុប្បន្ននេះ ក៏កំពុងវិវត្តយ៉ាងលឿន និងកាន់តែរីកចម្រើន រឹងប៉ឹង ទាំងខាងចាត់តាំង ទាំងខាងទស្សនគោលជំហរ ទាំងខាងជីវភាពប្រជាជន ។ល ។

ទាំងអស់នេះ សុទ្ធសឹងជាការប្រែប្រួលថ្មី ធំសម្បើមអស្ចារ្យពុំធ្លាប់មានឡើយតាំងពីដើមរៀងមក ។ ការប្រែប្រួលថ្មី ធំសម្បើមអស្ចារ្យទាំងអស់នេះហើយ ដែលយុវជន-យុវនារីយើង ត្រូវក្រេបជញ្ជក់ទទួលយក ។ ក្នុងរយៈកាលថ្មីនៃបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងកិច្ចការការពារប្រទេស បច្ចុប្បន្ននេះ យុវជន-យុវនារីយើង ចេះក្រេបជញ្ជក់ទទួលយកការប្រែប្រួលថ្មី សម្បើម



កងចល័តនៅសហករណ៍ កំពុងគាស់គល់ឈើដើម្បីរានដីដាំដំណាំ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩)

អស្ចារ្យទាំងនេះ នោះយុវជន-យុវនារីយើង នឹងកសាងខ្លួនបានរីកចម្រើនលឿនណាស់ ពីព្រោះយើងទាំងអស់គ្នា កំពុងស្ថិតក្នុងវ័យដែលឆាប់ទទួលរបស់ថ្មីស្រាប់ ។

៣) មិត្តយុវជន-យុវនារីយើងជំនាន់នេះ ដែលបច្ចុប្បន្នស្ថិតនៅក្នុងយុវវ័យនៅឡើយ មិត្តត្រូវរស់នៅបន្តវេនធ្វើបដិវត្តន៍បន្តទៅទៀត បានយូរណាស់ ។ បើគិតត្រឹមអាយុ៦០ឆ្នាំ មិត្តយើងអាចរស់នៅធ្វើបដិវត្តន៍ ការពារ និងកសាងប្រទេសបានពី៣០ ទៅ៤០ឆ្នាំទៀតជាមធ្យម ។ រយៈកាលនេះយូរណាស់ ធ្វើការងារបម្រើប្រទេសជាតិប្រជាជនបានច្រើនណាស់ ។ ប៉ុន្តែដោយរបបសង្គមនិយមយើង ចេះតែវិវត្ត រីកចម្រើនទៅមុខជារៀងរាល់ឆ្នាំ ហើយជីវភាពប្រជាជនយើង ចេះតែត្រូវរីកចម្រើនឡើងជារៀងរាល់ឆ្នាំដែរ ជីវិតមនុស្សយើងក៏ត្រូវពន្យារកាន់តែវែងទៅទៀត ។ ដូច្នេះបើគិតជាមធ្យមមនុស្សយើងអាចរស់នៅ៧០ឆ្នាំបានយ៉ាងធូរ ។ ដូច្នេះមិត្តយុវជន-យុវនារីយើងជំនាន់នេះ អាចបន្តវេនធ្វើបដិវត្តន៍បានពី៤០ឆ្នាំ ទៅ៥០ឆ្នាំប្លាយទៀត ។ ដូច្នេះ ជារយៈពេលយូរណាស់ ដែលមិត្តយើងអាចធ្វើការងារបម្រើប្រទេសជាតិ និងបម្រើបដិវត្តន៍បានជាច្រើន ហើយអាចទទួលផល និងឃើញផលនៃការកសាងសង្គមនិយម ការកសាងប្រទេសជាតិជាច្រើន ដោយផ្ទាល់ដៃផ្ទាល់ភ្នែកតែម្តង ។

ដើម្បីបន្តវេនធ្វើបដិវត្តន៍តទៅទៀត បានខ្លាំងក្លា ល្អប្រសើរ និងក្រហមឆ្អិនឆ្អៅជារៀងរហូតទៅ មិត្តយុវជន-យុវនារីយើងត្រូវហ្វឹកហ្វឺន លត់ដំ កសាងខ្លួននៅក្នុងចលនាមហាជនក្តៅជាប់ជានិច្ច ទើបមិត្តមានបទពិសោធច្រើនតទៅអនាគតទៀត ។ ដូច្នេះមិត្តកុំរើសអើងការងារ កុំរាថយ ចំពោះឧបសគ្គតូចធំ ឬការលំបាកស្មុគស្មាញសព្វបែបយ៉ាង ។ តែផ្ទុយទៅវិញ មិត្តត្រូវប្រឡូកក្នុងចលនាមហាជន ប្រយុទ្ធធ្វើការងារតូចធំ ធ្ងន់ស្រាល លំបាក ស្រួលសព្វបែបយ៉ាង ឆ្លងកាត់ការខុស ការត្រូវជាបន្តបន្ទាប់ ទើបមិត្តមានពិសោធច្រើន ។ ទាល់តែមិត្តប្រយុទ្ធធ្វើគ្រប់ការងារប្រឡូកក្តៅជាប់ នៅក្នុងចលនាមហាជនក្នុងគ្រប់រយៈកាលឆ្លងកាត់ការខុស ការត្រូវជាបន្តបន្ទាប់ទើបមិត្តមានពិសោធការងារច្រើន អាចលត់ដំហ្វឹកហ្វឺន កសាងខ្លួនបានល្អក្នុងចលនាជាលំដាប់ ។ ដូច្នេះ ទើបមិត្តអាចបន្តវេនធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេស តទៅអនាគតទៀតបានល្អប្រសើរ ហើយធានាឲ្យចលនាបដិវត្តន៍កម្ពុជាយើង នឹងនៅតែក្រហមឆ្អិនឆ្អៅជារៀងរហូត ហើយកាន់តែក្រហមឆ្អិនឆ្អៅថែមទៀតផង ។

ដោយហេតុផលទាំងអស់ខាងលើនេះហើយ បានជាយុវជន-យុវនារីយើងជំនាន់នេះ ត្រូវចាប់អារម្មណ៍ឲ្យដល់កម្រិត ខិតខំកសាងខ្លួនឲ្យបានល្អ តាមគោលជំហរបដិវត្តន៍ គ្រប់ផ្នែករបស់បក្សយើង កុំរវីរវល់ ឬជំពាក់ជំពិននឹងបញ្ហាកំប៉ិកកំប៉ុកជីវិញអាត្មាខ្លួន ជុំវិញបុគ្គលខ្លួន ដែលជាហេតុនាំឲ្យយើង កសាងខ្លួនយឺត ឬក៏ប្រទាញខ្លួនយើងឲ្យធ្លាក់ថយក្រោយវិញនោះឡើយ ។ បក្សកុម្មុយនីស្តកម្ពុជាទាំងមូល ប្រជាជនកម្ពុជាទាំងមូល និងប្រទេសជាតិ មាតុភូមិកម្ពុជា ជាទីស្នេហានៃយើង ដាក់ក្តីសង្ឃឹមទាំងស្រុងមកលើមិត្តយុវជន-យុវនារីយើងជំនាន់នេះ ហើយប្រគល់ភារកិច្ចបន្តវេនធ្វើបដិវត្តន៍ ឲ្យក្រហមឆ្អិនឆ្អៅ តទៅទៀត ដើម្បីការពារប្រទេស ការពារបក្ស ការពារវណ្ណៈ និងប្រជាជនកម្ពុជាយើង ឲ្យបានស្ថិតស្ថេរគង់វង្ស រឹងប៉ឹង ខ្លាំងក្លាជារៀងរហូតទៅ ព្រមទាំងបន្តវេនកសាងប្រទេស ឲ្យរីកចម្រើន លូតលាស់លើគ្រប់វិស័យ ឈានទៅសម្បូរសប្បាយ ថ្កុំថ្កើង រុងរឿង ជារៀងរហូត អង្វែងកាលតទៅ ។ នេះជាភារកិច្ចធ្ងន់ធ្ងរ តែខ្ពង់ខ្ពស់ឧត្តុង្គឧត្តម ហើយជាកិត្តិយស ថ្លៃថ្លារុងរឿងបំផុតចំពោះយុវជន-យុវនារីយើងជំនាន់នេះ ដែលប្រទេសជាតិ បក្សប្រជាជនកម្ពុជាទាំងមូលប្រគល់ជូន ។ ដូច្នេះ យុវជន-យុវនារីយើងជំនាន់នេះ គ្មានហេតុផលអ្វីទៅជាប់ជំពាក់ជំពិន និងរឿងកំប៉ិចកំប៉ុកក្រៅពីភារកិច្ចដែលជាកិត្តិយសឧត្តុង្គឧត្តមរបស់ខ្លួនទាំងអស់នេះឡើយ ។ យើងទាំងអស់គ្នាដែលជាយុវជន-យុវនារីជំនាន់នេះ ត្រូវតែប្តេជ្ញាឆ្លើយតបនឹងការអំពាវនាវ និងទំនុកទុកចិត្ត និងក្តីសង្ឃឹម ដែលប្រទេសជាតិ បក្ស និងប្រជាជនកម្ពុជាយើង ដាក់ទាំងស្រុងមកលើយុវជន-យុវនារីយើងជំនាន់នេះ ដែលយើងទាំងអស់គ្នាត្រូវផ្តង់ចិត្តគំនិត សតិអារម្មណ៍ និងគ្រប់សកម្មភាពទាំងអស់ ដើម្បីសម្រេចឲ្យបាន ។ តាមរយៈនេះ យុវជន-យុវនារីយើងជំនាន់នេះទាំងអស់គ្នា សម្តែងនូវការគោរព ស្រឡាញ់ និងដឹងគុណឥតត្រើយត្រាណ ចំពោះបក្សកុម្មុយនីស្តកម្ពុជាយើង ក្នុងឱកាសបុណ្យខួបទី១៧ នៃកំណើតបក្សកុម្មុយនីស្តកម្ពុជា ដ៏មហាជោគជ័យនេះ ក៏ដូចជារៀងរហូតទៅដែរ ។ **ឆេង ទ៉េង**

# អង្ករមួយគ្រាប់អាចឱ្យមនុស្សម្នាក់ស្លាប់ ឬរស់បាន

“ក្នុងជំនាន់ខ្មែរក្រហម បើសិនគេឲ្យខ្ញុំជ្រើសរើសរវាងអង្ករ និងគ្រឿងអលង្ការ ច្បាស់ណាស់ ខ្ញុំនឹងជ្រើសរើសយកអង្ករ ដើម្បីចម្អែតក្រពះ” ។ ទាំងនេះជាសម្តីរបស់ជនរងគ្រោះក្នុងជំនាន់កម្ពុជាប្រជាធិបតេយ្យ ម្នាក់ឈ្មោះ ដួន រ៉ាយ ។

ប្រទេសមួយដែលដាំដុះស្រូវស្ទើរគ្រប់ទិសទី ចុះហេតុអ្វីបានជាប្រជាជនរស់នៅដោយភាពអត់ឃ្លាន? នេះជារឿងពិតដែលកើតមានឡើងក្នុងរបបពផ្នាំ ៨ខែ និង២០ថ្ងៃ។ ដួន រ៉ាយ អាយុ៦២ឆ្នាំ ជាជនរងគ្រោះដែលឆ្លងកាត់របបនេះ បានបានរៀបរាប់ពីក្តីលំបាក និងបទពិសោធឈឺចាប់ ដែលគាត់បានជួបផ្ទាល់ក្នុងជំនាន់នោះ ។ ដួន រ៉ាយ ត្រូវបានខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញទៅកាន់ តំបន់២៥ ក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ពេលដែលគាត់ទៅដល់ដំបូង ខ្មែរក្រហមបានចែកអង្ករមួយថ្ងៃ៣កំប៉ុង និងអំបិលមួយស្លាបព្រាបាយ ដល់គ្រួសាររបស់គាត់ ដែលមានសមាជិក ៦នាក់ ។

ក្នុងខែសីហា ឆ្នាំ១៩៧៥ ភូមិគោកគ្រប់ ដែលស្ថិតក្នុងតំបន់២៥ ត្រូវបានអង្គការខ្មែរក្រហមរៀបចំបង្កើតជាសហករណ៍ដើម្បីហូបរួម និងធ្វើការរួម ។ របបអាហារដែលទទួលបានប្រចាំថ្ងៃ គឺបានតែ បបរាវជាមួយអំបិល៣-៤គ្រាប់ប៉ុណ្ណោះ ។ ដោយសារតែទ្រាំនឹងភាពអត់ឃ្លានមិនបាន នាយប់មួយ ពេលដែលយោធាដេកលក់ រ៉ាយ បានចេញពីផ្ទះ លួចចូលទៅក្នុងរោងបាយដើម្បីរកអាហារមកហូបចម្អែតក្រពះ ។ ពេលនោះ គាត់លួចបានអង្ករមួយក្តាប់ ហើយក៏បានត្រឡប់មកផ្ទះវិញ ។ ប៉ុន្តែពេលដែលគាត់កំពុងដើរតាមផ្លូវ ឈ្លបភូមិបានចាប់គាត់ ហើយយកទៅសួរចម្លើយនៅផ្ទះមេភូមិ ។ សំណាងល្អ យោធាខ្មែរក្រហមបានដោះលែងគាត់ ដោយគ្រាន់តែព្រមានគាត់មិនអោយលួចអង្ករអង្គការហូបឯកជនទៀត ។ ចាប់តាំងពីពេលនោះមក រ៉ាយ លែងហ៊ានទៅលួចរបស់អង្គការទៀតហើយ ព្រោះខ្លាចមានបញ្ហា ។

រ៉ាយ បានរៀបរាប់ពីរឿងរ៉ាវមួយដែលកើតឡើងក្នុងឆ្នាំ ១៩៧៧ នៅពេលដែលអ្នកជិតខាងរបស់គាត់ម្នាក់ ឈ្មោះ សុក សម បានទៅលួចអង្ករឲ្យគ្រួសាររបស់គាត់ហូប តែត្រូវឈ្លបខ្មែរក្រហមមកទាន់ ហើយចាប់គាត់ព្រមទាំងគ្រួសារយកទៅរៀនសូត្រ ។ ចាប់តាំងពីពេលនោះមក គ្រួសារមួយនេះ បាត់ដំណឹងរហូត ។

ភាពអត់ឃ្លាន បានក្លាយជាមច្ចុរាជឆក់យកជីវិតកូនប្រុសម្នាក់របស់ រ៉ាយ ក្នុងឆ្នាំ១៩៧៨ ដោយសារកង្វះអាហារូបត្ថម្ភ និងធ្លាក់ខ្លួនឈឺធ្ងន់ ។ កូនរបស់ រ៉ាយ បានស្រែករកបាយហូបរហូតទាល់តែដាច់ខ្យល់ស្លាប់ ។ រ៉ាយ មិនចង់បាត់បង់សមាជិកគ្រួសារណាម្នាក់របស់គាត់ទេ ដូច្នេះហើយ ឲ្យតែដល់ពេលដែលប្រជាជនប្រមូលផលស្រូវហើយ គាត់តែងតែទៅរើសកួរស្រូវដែលជ្រុះនៅក្នុងស្រែ ដាក់ក្នុងថ្នក់ក្រមា លួចលាក់មិនឲ្យនរណាឃើញឡើយ ។ ជួនកាល រ៉ាយ បាន លួចយកស្រូវខ្លះទៅដូរយកអំបិលទុកហូប ។ រ៉ាយ និយាយថា “សម័យនោះបើមានអង្ករ និងអំបិល គឺវិសេសវិសាលលើសលប់ហើយ” ។ ទោះបីពេលនេះ រ៉ាយ មានអង្ករហូបចុកគ្រប់គ្រាន់ក៏ដោយ ក៏គាត់មិនដែលភ្លេចនូវរឿងរ៉ាវដែលបានកើតឡើងក្នុងជីវិតរបស់គាត់ក្នុងសម័យដ៏ខ្មៅងងឹតនោះដែរ ។ អង្ករមួយគ្រាប់អាចធ្វើឲ្យមនុស្សម្នាក់រស់ ហើយវាក៏អាចធ្វើឲ្យមនុស្សម្នាក់ស្លាប់បានដែរ ។

ប្រជាជនកម្ពុជាភាគច្រើន ត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើការច្រើនជាង១២ម៉ោងក្នុងមួយថ្ងៃ ស្ទើរតែគ្មានពេលឈប់សម្រាក ។ អង្គការបានបញ្ជាប្រជាជនឲ្យទៅធ្វើការនៅតាមវាលស្រែ ជីកព្រែក លើកទំនប់ និងធ្វើការនៅតាមរោងចក្រផ្សេងៗ ។ របបកម្ពុជាប្រជាធិបតេយ្យ បានដាក់ចេញនូវគោលនយោបាយកសិកម្មដែលជ្រើសរើសស្រូវជាអទិភាព នាំចេញទៅក្រៅប្រទេស ដើម្បីដូរយកគ្រឿងសព្វាវុធ និងសម្ភារកសិកម្មនានា មកប្រើប្រាស់ក្នុងប្រទេសវិញ ។ ប៉ុន្តែ ជាលទ្ធផល របបនេះបានសម្លាប់មនុស្សអស់រាប់លាននាក់ ។ **ស្ងួស សកល**

# ភូមិអំពិលទឹកបន្ទាប់ពីរដ្ឋប្រហារ

ស្ថិតក្នុងវ័យ៧៧ឆ្នាំ លោកតា គឹម ផន ហាក់មានកម្លាំងពលំមាំមួនជាងមនុស្សមួយចំនួនដែលមានវ័យស្របាលគាត់ ។ កំពុងតែមមាញឹកធ្វើកិច្ចការផ្ទះ តាផន បានមកទទួលខ្ញុំ និងក្រុមការងារឲ្យចូលទៅអង្គុយលេងនៅលើគ្រែក្រោមម្លប់ដើមស្វាយ មុខផ្ទះស្លឹករបស់គាត់ដោយក្តីរាក់ទាក់ ។ តា ផន ដែលមានរាងទាប មាឌមាំ សម្បុរខ្មៅ បានរៀបរាប់ប្រាប់ខ្ញុំគ្រួសៗអំពីភូមិស្រុកដែលគាត់រស់នៅ ។ គាត់រស់នៅភូមិអំពិលទឹក ជាភូមិមួយក្នុងចំណោមភូមិទាំងបួន រួមមាន (ភូមិកោះដ្តៅ, ភូមិសុភិន, ភូមិកំពង់ក្របី និងភូមិអំពិលទឹក) ដែលស្ថិតនៅលើកោះរងាវ ។ កោះរងាវមានប្រវែង៤៥គីឡូម៉ែត្រ និងមានផ្ទៃដីធំជាងកោះផ្សេងៗទៀតដែលស្ថិតនៅក្នុងទន្លេមេគង្គនៃខេត្តក្រចេះ ។ ផ្ទះរបស់ តា ផន ស្ថិតនៅឆ្ងាយពីអ្នកភូមិបន្តិច ហើយនៅខាងក្រោយផ្ទះរបស់គាត់ មានទន្លេមេគង្គ និងខាងមុខផ្ទះ មានស្រែ និងដំណាំហូបផ្លែ ។

តា ផន ធំដឹងក្តីនៅភូមិអំពិលទឹកនេះតែម្តង ។ គាត់បានឲ្យដឹងថា កាលពីជំនាន់សង្គមរាស្ត្រនិយម មិនមានប្រជាជនរស់នៅភូមិអំពិលទឹកច្រើនទេគឺមានតែ៥ ឬ៦គ្រួសារ ប៉ុណ្ណោះ ។ ប្រជាជនក្នុងភូមិរបស់គាត់ និងភូមិមួយចំនួនទៀត ដែលរស់នៅលើកោះរងាវភាគច្រើនប្រកបរបរនេសាទ និងធ្វើស្រែចម្ការ ។ ជីវភាពប្រចាំថ្ងៃរបស់អ្នកភូមិនៅពេលនោះ មិនមានចោទជាបញ្ហាឡើយ ព្រោះមិនមានការខ្វះខាតម្ហូបអាហារទេ ទោះបីជានៅឆ្ងាយពីខេត្តក៏ដោយ ។ តា ផន ប្រាប់ខ្ញុំលាយឡំជាមួយសំណើចថា បើនិយាយពីត្រីវិញ គឺសម្បូរខ្លាំងណាស់ គ្រាន់តែដើរទៅក្រោយផ្ទះ បង់តែមួយសំណាញ់ចែកគ្នាហូបបានពីរបីគ្រួសារ ។ ចំពោះដំណាំ អ្នកភូមិភាគច្រើនដាំសណ្តែក និងល្ង ហើយពេលដែលប្រមូលផលបាន ត្រូវយកទៅលក់នៅស្រុកសម្បូរណ៍ ដើម្បីយកប្រាក់មកទិញគ្រឿងឧបភោគបរិភោគ ។ អ្នកភូមិត្រូវចំណាយពេលកន្លះថ្ងៃទម្រាំបែរទូកទៅដល់



គឹម ផន កំពុងរៀបរាប់ពីរឿងរ៉ាវរបស់គាត់ដែលឆ្លងកាត់របបខ្មែរក្រហមប្រាប់ដល់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ បច្ចុប្បន្ន គឹម ផន រស់នៅលើកោះរងាវ ស្រុកសម្បូរណ៍ ខេត្តក្រចេះ ។

ស្រុកសម្បូរណ៍ ហើយក្នុងការធ្វើដំណើរទៅមក គឺត្រូវចំណាយពេលមួយថ្ងៃ ដែលអ្នកភូមិភាគច្រើនចេញដំណើរទៅពេលព្រឹក និងត្រឡប់មកផ្ទះវិញនៅពេលល្ងាច ។

ក្រឡេកមើលទៅចៅៗដែលកំពុងប្រឡែងគ្នា តា ផន បានរម្លឹកថា ការរស់នៅដោយសុខសាន្តរបស់ប្រជាជននៅត្រឹមឆ្នាំ ១៩៧០ តែក្រោយរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ អ្វីៗក៏ប្រែប្រួលដែរ ។ កងទ័ពរំដោះរបស់ខ្មែរក្រហមបានមកដល់ភូមិរបស់គាត់ ។ តា ផន ក៏ដូចជាអ្នកភូមិដទៃទៀតបានឮការអំពាវនាវរបស់សម្តេច សីហនុ ឲ្យកូនចៅចូលព្រៃម៉ាគី តស៊ូប្រឆាំងនឹងរបបលន់ នល់ ដើម្បីដណ្តើមអំណាចថ្វាយព្រះអង្គវិញ ។ តា ផន បានឲ្យដឹងថា គាត់មិនដឹងថា ព្រៃម៉ាគីនោះនៅកន្លែងណាទេ ហើយក៏មិនបានចូលធ្វើជាកងទ័ពរំដោះរបស់ខ្មែរក្រហមដែរ ។ គាត់ និងអ្នកភូមិរស់នៅជាធម្មតា ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ អំឡុងពេលនោះ ខ្មែរក្រហមចាត់អ្នកភូមិឲ្យធ្វើការងារជាក្រុមប្រវាស់ដៃ ហើយរស់នៅជួបជុំក្រុមគ្រួសារជាធម្មតា និងហូបជាឯកជនតាមផ្ទះរៀងខ្លួន ។

ក្រោយជ័យជម្នះទូទាំងប្រទេសថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ខ្មែរក្រហមបានផ្លាស់ប្តូររចនាសម្ព័ន្ធគ្រប់គ្រងរបស់ខ្លួន ។ ខ្មែរក្រហមបានលែងឲ្យមានការធ្វើការជាក្រុមប្រវាស់ដៃទៀតហើយ គឺបានបង្កើតជាសហករណ៍វិញ ។ អង្គការបានបែងចែកអ្នកភូមិជាក្រុម ជាកង ទៅតាមការងារដែលអង្គការចាត់តាំងរៀងៗខ្លួន ។ ជាមួយគ្នានេះ អង្គការបំបែកសមាជិកគ្រួសារមិនឲ្យរស់នៅជាមួយគ្នាទេ គឺតម្រូវឲ្យទៅនៅតាមកង តាមក្រុម ដែលអង្គការបានចាត់តាំង ។ តា ផន ត្រូវបែកពីប្រពន្ធ និងកូនប្រាំបីនាក់ ទៅធ្វើនៅកងនេសាទ ប៉ុន្តែស្ថិតនៅក្នុងភូមិដដែល ។ កងនេសាទរបស់គាត់មានសមាជិកទាំងអស់៤នាក់ ហើយអង្គការតម្រូវឲ្យកងរបស់គាត់នេសាទត្រីដើម្បីផ្គត់ផ្គង់សហករណ៍ ។ កងនេសាទរបស់តា ផន ត្រូវចេញទៅនេសាទនៅពេលយប់ និងត្រឡប់មកវិញនៅពេលព្រឹកដើម្បីយកត្រីមកឲ្យសហករណ៍ធ្វើម្ហូប ។ តា ផន បានឲ្យដឹងទៀតថា អង្គការមិនបានដាក់កំហិតថា ត្រូវរកត្រីឲ្យបានចំនួនប៉ុន្មានក្នុងមួយថ្ងៃទេ ប៉ុន្តែកងនេសាទរបស់គាត់ មានកាតព្វកិច្ច និងធានាយ៉ាងណាត្រូវតែមានត្រីមកឲ្យសហករណ៍បានគ្រប់គ្រាន់ ។ តាផន រៀបរាប់ប្រាប់ខ្ញុំបន្តជាមួយនឹងសំណើចថា ត្រីពេលនោះសម្បូរខ្លាំងណាស់ ហើយកងរបស់គាត់អាចរកបានមួយថ្ងៃរាប់រយគីឡូ ។ ក្រៅពីការងារនេសាទ តា ផន មិនមានធ្វើការងារផ្សេងទេ គឺគ្រាន់តែចំណាយពេលបន្តិចបន្តួចជួសជុលសំណាញ់ ឬមងដែលខូចប៉ុណ្ណោះ ។ កងនេសាទរបស់គាត់មានពេលសម្រាកគ្រប់គ្រាន់នៅពេលថ្ងៃ ។ តាផន បានបន្តថា អ្នកធ្វើការនៅកងនេសាទ មានសំណាងជាងគេ ព្រោះកងនេសាទធ្វើការ តែពេលយប់ ហើយអាចដាំបាយបរិភោគជាមួយនឹងត្រីដែលរកបានដោយសេរី ។ ទោះជាយ៉ាងណា តា ផន បានឲ្យដឹងថា គាត់អាចបរិភោគបរិបូរណ៍តែខ្លួនឯងប៉ុណ្ណោះ មិនអាចយកបាយ ឬត្រីដែលរកបានមកផ្ញើគ្រួសារនៅសហករណ៍បានទេ ។ នៅសហករណ៍ ប្រជាជនត្រូវបរិភោគរួមនៅរោងបាយ ដែលទទួលបានរបបបបរខាប់ (បបរឈ្នោល) មួយវែកតូចក្នុងមួយពេល ។

នៅអំឡុងឆ្នាំ១៩៧៨ សភាពការណ៍នៅក្នុងភូមិរបស់ តា ផន រស់នៅមានការប្រែប្រួល ដោយមានកម្មាភិបាលខ្មែរក្រហមថ្មីចូលមកគ្រប់គ្រងជំនួស ។ គាត់បានឲ្យដឹងថា កម្មាភិបាលចាស់ ត្រូវបានអង្គការស្នើទៅរៀនសូត្រ ឬផ្លាស់ទៅកន្លែងថ្មី ហើយអ្នកទាំងអស់នោះ ក៏មិនដែលឃើញត្រឡប់មកវិញដែរ ។ ចំពោះការរស់នៅរបស់ប្រជាជន និងការងារនៅក្នុងសហករណ៍មានការតឹងតែងជាងមុន ។ អ្នកគ្រប់គ្រងថ្មីមានចរិតកាចសាហាវ និងម៉ឺងម៉ាត់ខ្លាំងណាស់ ។ ទោះជាយ៉ាងណា តា ផន នៅតែបន្តធ្វើការនៅកងនេសាទរហូតដល់របបខ្មែរក្រហមត្រូវបានផ្តួលរំលំ ។ គាត់បានរម្លឹកថា ពេលដែលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិ និងកងទ័ពស្ម័គ្រចិត្តវៀតណាមវាយចូលមកដល់ មេភូមិ ឈ្លប និងកម្មាភិបាលខ្មែរក្រហមមួយចំនួន មិនបានគេចខ្លួនចេញពីភូមិទេ គឺរស់នៅជាមួយប្រជាជនដូចធម្មតា ។ មិនមានអ្នកភូមិណាម្នាក់ហ៊ានរាយការណ៍ប្រាប់កងទ័ពរំដោះថា អ្នកនេះជាឈ្លបខ្មែរក្រហម ឬអ្នកនោះជាអតីតមេភូមិទេ ព្រោះអ្នកភូមិខ្លាចខ្មែរក្រហមវាយដណ្តើមបានអំណាចវិញ ។ អតីតកម្មាភិបាលខ្មែរក្រហមទាំងនោះ ក៏បន្តរស់នៅជាមួយអ្នកភូមិរហូតដល់បច្ចុប្បន្ន ។

ក្រោយរបបខ្មែរក្រហមបានដួលរលំ តាផន បានជួបជុំប្រពន្ធកូន និងចាប់ផ្តើមជីវិតថ្មីនៅភូមិកំណើត ដោយប្រកបរបរធ្វើស្រែចម្ការ និងនេសាទ ។ តាផន តែងតែបង្រៀនកូនៗអំពីរបៀប

នេសាទត្រី ។ បច្ចុប្បន្ននេះ កូនៗមិនឲ្យគាត់ទៅនេសាទទៀតទេ គឺកូនៗរបស់គាត់ជាអ្នករ៉ាប់រងជិនួស ។ ប៉ុន្តែ ធនធានត្រីនៅពេលនេះ មិនសូវសម្បូរដូចពីជំនាន់មុនទេ ព្រោះមានឈ្មួញទុច្ចរិតមកនេសាទខុសច្បាប់ ដោយប្រើឧបករណ៍ឆក់ និង ដាយវែងៗ ជាហេតុធ្វើឲ្យត្រីមួយចំនួនស្ទើរតែផុតពូជទៅហើយ ។ គាត់ពិតជាមានក្តីបារម្ភណាស់ចំពោះបញ្ហានេះ ។ ត្រីមួយចំនួននឹងផុតពូជមិនខាន ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចមិនទប់ស្កាត់ឲ្យបានហ្មត់ចត់ ។ តាផន បានមានប្រសាសន៍ថា កូនចៅយើងជំនាន់ក្រោយនឹងមិនស្គាល់ពូជត្រីដែលបាត់បង់ ប្រសិនបើយើងទាំងអស់គ្នាមិននាំគ្នាចូលរួមថែរក្សាធនធានត្រី និងលុបបំបាត់ការនេសាទខុសច្បាប់ ។ ដោយសារតែចំណូលដែលបានមកពីការនេសាទ និងការធ្វើស្រែចម្ការមិនគ្រប់គ្រាន់នឹងការផ្គត់ផ្គង់ជីវភាពគ្រួសារ យុវជន យុវនារី នៅក្នុងភូមិមួយចំនួនបានសម្រេចចិត្តចាកចេញពីគ្រួសារ ភូមិដ្ឋាន ទៅរកការងារធ្វើនៅតាមបណ្តារោងចក្រនានា ឬទៅធ្វើការនៅប្រទេសជិតខាង ។

ទោះបីជាមានការប្រែប្រួលមិនដូចពីអតីតកាលក៏ដោយ តែសម្រាប់ តា ផន អនុស្សាវរីយ៍ដែលគាត់បានឆ្លងកាត់ និងភាពរីករាយជាមួយក្រុមគ្រួសារ នៅភូមិអំពិលទឹក នៅតែដក់ជាប់នៅក្នុងចិត្តគាត់ជានិច្ច ។ តាផន រម្លឹកពីវេលាដែលរីករាយជាមួយនឹងកូនៗថា រៀងរាល់ថ្ងៃ ក្រោយពេលបាយល្ងាច ក្មេងៗតែងតែមកអង្គុយជុំគ្នាក្រោមពន្លឺចង្កៀងភ្លឺភ្លឹមៗ ដើម្បីស្តាប់ជីដូនជីតា ឬឪពុកម្តាយនិទានរឿងឲ្យស្តាប់ ។ ម្នាក់ៗស្តាប់យ៉ាងស្ងប់អារម្មណ៍ទៅតាមរឿងនិទាន ។ រឿងនិទានដែល តា ផន នៅចងចាំបាន គឺរឿងនិទានដែលទាក់ទងនឹងប្រវត្តិនៃសត្វផ្សោត ដែលមាននៅក្នុងទឹកដី នៃខេត្តក្រចេះនេះ ។ ប៉ុន្តែ បច្ចុប្បន្ននេះ សម្រាប់ តា ផន ផ្ទាល់យល់ថា ភាពស្និទ្ធស្នាលក្នុងគ្រួសារមានការថយចុះ ដោយសារតែស្រុកទេសមានការអភិវឌ្ឍ និងមានបច្ចេកវិទ្យាទំនើប ក្មេងៗជំនាន់ក្រោយ លែងអង្គុយចាំស្តាប់ការនិទានរឿងដូចមុនទៀតហើយ ដោយម្នាក់ៗងាកទៅមើលទូរទស្សន៍ ស្តាប់ចម្រៀង និងមើលទូរសព្ទរៀងៗខ្លួន ។ ទោះជា យ៉ាងណា តា ផន ពេញចិត្តនឹងការរស់នៅនាពេលបច្ចុប្បន្ន ព្រោះប្រទេសមានសុខសន្តិភាព ហើយប្រជាជនម្នាក់ៗមានសិទ្ធិសេរីភាពពេញលេញក្នុងការរស់នៅប្រកបរបរចិញ្ចឹមជីវិត និងបានរស់នៅជួបជុំគ្រួសារ មិនបែកបាក់គ្នាដូចជំនាន់ខ្មែរក្រហម ។

**ឆាង សារៈមុនិន្ទ**


ប្រជាជនដែលរស់នៅលើកោះរងាវ ស្រុកសម្បូរណ៍ ខេត្តក្រចេះ កំពុងនេសាទត្រី ។

# ការសម្របខ្លួនជួយឱ្យយើងរស់រានមានជីវិត

អ្នកគ្រូ លក្ខាវណ្ណ កើតនៅឆ្នាំ១៩៥២ នៅឃុំព្រែកតាណូង ស្រុកកោះសូទិន ខេត្តកំពង់ចាម ។ លក្ខាវណ្ណ មានបងប្អូនចំនួន១៣ នាក់ ប៉ុន្តែបងប្អូនបីនាក់ (ប្រុសម្នាក់ និងស្រីពីរនាក់) បានស្លាប់នៅក្នុងរបបខ្មែរក្រហម ។

លក្ខាវណ្ណ បានរៀបរាប់ថា មុនព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចព្រះបាទ នរោត្តម សីហនុ គាត់ និងក្រុមគ្រួសាររស់នៅស្រុកកំណើត ។ បន្ទាប់មក ឪពុករបស់គាត់បាននាំក្រុមគ្រួសារទៅរស់នៅទីរួមខេត្តកំពង់ចាមវិញ ។ ឪពុករបស់គាត់បានសាងសង់ផ្ទះមួយខ្នងនៅខាងក្រោយវត្តដីដុះ និងបានបន្តបង្រៀនសិស្សនៅទីនោះ ។ រីឯគាត់វិញបានចូលរៀននៅវិទ្យាល័យកំពង់ចាម ដែលជាអតីតវិទ្យាល័យព្រះសីហនុ ។

ប្រហែលជានៅក្នុងអំឡុងឆ្នាំ១៩៧២ យោធាខ្មែរក្រហម និងកងទ័ពយៀកកុង បានប្រយុទ្ធគ្នាកាន់តែខ្លាំងឡើងៗ ។ ដូនកាលគ្រាប់កាំភ្លើងបានផ្លោងធ្លាក់ចូលក្នុងបរិវេណវិទ្យាល័យកំពង់ចាម ដែលគាត់កំពុងសិក្សា ។ ម្ល៉ោះហើយ ឪពុករបស់គាត់ បានបញ្ជូនគាត់ឲ្យទៅរៀនបន្តនៅវិទ្យាល័យទួលស្វាយព្រៃ នៅរាជធានីភ្នំពេញ ។ នៅឆ្នាំ១៩៧៣ លក្ខាវណ្ណ បានប្រឡងចូលសាលាវិចិត្រសិល្បៈផ្នែកយីកេ ។ លក្ខាវណ្ណ បានសិក្សាផ្នែកយីកេ រហូតដល់ថ្ងៃដែលខ្មែរក្រហមដណ្តើមបានទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ ទើបគាត់ត្រឡប់ទៅស្រុកកំណើតវិញ ។

**មុនពេលខ្មែរក្រហមឡើងកាន់អំណាច**

លក្ខាវណ្ណ បានរំលឹកឡើងវិញថា នៅពេលដែលគាត់កំពុងសិក្សានៅទីក្រុងភ្នំពេញ ខ្មែរក្រហមបានវាយដល់ក្រុងកំពង់ចាម ។ ឪពុករបស់គាត់បាននាំក្រុមគ្រួសារត្រឡប់ទៅស្រុកកំណើតនៅកោះសូទិនវិញ ។ ខណៈនោះ ឪពុករបស់គាត់ក៏ត្រូវបានខ្មែរក្រហមចាប់បញ្ជូនទៅឃុំឃាំងនៅស្រុកកោះញែក ខេត្តមណ្ឌលគិរី ដោយ



អ្នកគ្រូ លក្ខាវណ្ណ ស្លៀកសម្លៀកបំពាក់ចងក្បិន

សារតែឪពុកគាត់ជាគ្រូបង្រៀន ។ ចំណែកម្តាយរបស់គាត់បានធ្វើនំលក់ដើម្បីចិញ្ចឹមកូនៗ ។ លុះដល់ឆ្នាំ១៩៧៥ ឪពុករបស់គាត់ត្រូវបានខ្មែរក្រហមដោះលែងឲ្យត្រឡប់មកជួបជុំគ្រួសារវិញ ។ ពេលនោះ ខ្មែរក្រហមមិនបានអនុញ្ញាតឲ្យប្រជាជនរស់នៅតាមផ្ទះក្នុងភូមិដូចកាលពីមុនទេ ។ ខ្មែរក្រហមបានជម្លៀសប្រជាជនឲ្យទៅរស់នៅក្នុងព្រៃនៅមុំស្ពាយផ្លូវក្បែរមាត់ស្ទឹង ដោយបានបង្កើតជាភូមិមួយឈ្មោះ "ភូមិបញ្ញាជន" ។ ឪពុកគាត់រស់នៅទីនោះបានប្រហែលមួយឆ្នាំ ខ្មែរក្រហមបានជម្លៀសឪពុកគាត់ និងប្រជាជនដែលភាគច្រើនជាគ្រូបង្រៀនឲ្យទៅតំបន់ផ្សេងៗទៅតាមមុខព្រួញរបស់ខ្មែរក្រហម ។ ប្រជាជនដែលត្រូវខ្មែរក្រហមជម្លៀស តម្រូវឲ្យឆ្លងទន្លេទៅពាមជីកងដើម្បីរង់ចាំឡានដឹកជញ្ជូនបន្ត ។ ប្រជាជនមួយចំនួនត្រូវបានជម្លៀសទៅស្រុកចម្ការលើ រីឯក្រុមគ្រួសាររបស់គាត់ត្រូវបានជម្លៀសទៅតាមផ្លូវភ្នំសន្ទុក ខេត្តកំពង់ធំ ។ ឡានបានបរហួសភ្នំសន្ទុកប្រហែលមួយគីឡូម៉ែត្រ ស្រាប់តែបែកកង់ ។ ខ្មែរក្រហមបានបញ្ជាឲ្យប្រជាជនទាំងអស់ឲ្យចុះពីលើឡាន ដើម្បីរង់ចាំឡានផ្សេងទៀត ។ មួយសន្ទុះក្រោយមក ឡានថ្មីបានមកដល់ ប៉ុន្តែពេលធ្វើដំណើរទៅដល់ទីរួមខេត្តកំពង់ធំ ឡាននោះក៏អស់សាំង ។ ប្រជាជនបាននាំគ្នាចុះពីលើឡានជាលើកទីពីរ ដើម្បីរង់ចាំឡានថ្មីមកទទួល ។ នៅពេលធ្វើដំណើរដល់ភូមិឫស្សីជះ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ឡានមកទទួលនោះក៏អស់សាំងម្តងទៀត ហេតុដូច្នេះ ខ្មែរក្រហមបានសម្រេចចិត្តដាក់ប្រជាជនទាំងអស់នោះ រួមទាំងក្រុមគ្រួសាររបស់គាត់ឲ្យរស់នៅភូមិឫស្សីជះតែម្តង ។

នៅក្នុងភូមិឫស្សីជះ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ខ្មែរក្រហមបានចាត់ចែងឲ្យប្រជាជនជម្លៀសស្នាក់នៅតាមផ្ទះជាមួយប្រជាជនមូលដ្ឋានមួយរយៈ ទម្រាំប្រជាជនកាប់ឆ្ការព្រៃនៅជាប់ភូមិដើម្បីសង់ខ្ទមបាន ។ នៅពេលនោះ លក្ខាវណ្ណ ចាប់ផ្តើមមានអារម្មណ៍អស់សង្ឃឹមថានឹងបានវិលត្រឡប់ទៅស្រុកកំណើតវិញ ។ ចំណែកឯឪពុករបស់គាត់ បានត្រឹមតែនៅស្ងាត់ស្ងៀម មិនហ៊ានមាត់កអ្វីទាំងអស់ ក្រៅអំពីខិតខំប្រឹងប្រែងធ្វើការតាមការបញ្ជារបស់ខ្មែរក្រហម ។ ចាប់តាំងពីពេលនោះមក ជីវិតគ្រួសាររបស់គាត់ត្រូវផ្លាស់ទៅជាកសិករ ។ ឪពុករបស់ លក្ខាវណ្ណ ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅបោចវល្លិ៍ នៅក្នុងព្រៃ ។ ចំណែក គាត់ត្រូវបានបញ្ជូនឲ្យទៅនៅក្នុងកងចល័តសង្កាត់ ធ្វើការជីកប្រឡាយ និងលើកទំនប់ ។ ប្រសិនបើប្រជាជនណាធ្វើគ្រប់ផែនការដែលខ្មែរក្រហមបានដាក់ ប្រជាជននោះនឹងឆាប់បានសម្រាក ។ ប៉ុន្តែខ្មែរក្រហមនឹងដាក់ផែនការបន្ថែមនៅថ្ងៃបន្ទាប់ ។ ចំពោះគាត់ធ្វើមិនអាចសម្រេចតាមផែនការរបស់ខ្មែរក្រហមបានទេ ដោយសារតែគាត់មិនធ្លាប់ធ្វើការងារធ្ងន់ពីមុនមក និងមិនមានអាហារហូបគ្រប់គ្រាន់ ។ បើទោះបីជាគាត់ធ្វើមិនគ្រប់ផែនការក៏ដោយ ក៏គាត់នៅតែប្រឹងរហូតដល់ប្រធានសហករណ៍ តាបូរ អាណិត ហើយបានប្រាប់គាត់ឲ្យឈប់សម្រាកប្រសិនបើគាត់នឿយហត់ ។ រីឯមិត្តយុវជនវិញ បានមកជួយគាត់ នៅពេលដែលយុវជនទាំងនោះសម្រេចផែនការងាររបស់ខ្លួនរួចរាល់ ។ លក្ខាវណ្ណ បានបន្តថា ប្រជាជននៅក្នុងភូមិមានចិត្តល្អ ចេះស្រឡាញ់រាប់អានប្រជាជនថ្មី ឬប្រជាជន១៧មេសា ។ ទន្ទឹមនឹងនេះ មានប្រជាជនមូលដ្ឋានមួយចំនួនតូច ហាក់នៅមានការរើសអើង និងមិនចូលចិត្តប្រជាជនថ្មី ។ អ្វីដែល លក្ខាវណ្ណ គិតថាពិបាកវេទនានៅក្នុងរបបនោះ គឺរស់នៅបែកពីឪពុកម្តាយបងប្អូន ដែលធ្វើឲ្យប៉ះទង្គិចអារម្មណ៍របស់គាត់យ៉ាងខ្លាំង ។ ពេលនោះ គាត់ហាក់ដូចជារស់នៅក្នុងទុក្ខព្រួយ ។ នៅពេលគាត់ពុស៊ីផ្ទៃឡានពេល



អ្នកគ្រូ លក្ខាវណ្ណ នៅក្នុងមហោស្រពអាស៊ាន ប្រទេសថៃ កាលពីខែមេសា ឆ្នាំ២០១៧

ដើរទៅស្ទូង ឬទៅច្រូតស្រូវម្តងៗ គាត់ស្ទើតែទប់ទឹកភ្នែកមិនបាន ដោយសារតែគាត់នឹកដល់សាលារៀន និងនឹកដល់ជីវិតនៅទីក្រុងភ្នំពេញ ។ បើទោះបីជាការហូបចុកមិនសូវពិបាកយ៉ាងណាក៏ដោយ ក៏ការធ្វើទារុណកម្មផ្លូវចិត្ត ហាក់ដូចជាធ្ងន់សម្រាប់គាត់ ។

លក្តាវណ្ណ បានរៀបរាប់ថា នៅរដូវច្រូតកាត់ ខ្មែរក្រហមបានចែកអង្ករឲ្យម្នាក់បីកំប៉ុង ។ នៅរដូវស្ទូងដក ខ្មែរក្រហមបានកាត់បន្ថយមកត្រឹមម្នាក់កន្លះកំប៉ុងវិញ ។ រីឯការងារ ប្រជាជនចាប់ផ្តើមធ្វើតាំងពីម៉ោង៤ទៀបភ្លឺ ។ រដូវវស្សា គឺជារដូវមួយដែលប្រជាជនមិនមានអាហារបរិភោគគ្រប់គ្រាន់ ។ ជាលទ្ធផល រាងកាយរបស់គាត់ចាប់ផ្តើមចុះស្គម ហើយកដៃរបស់គាត់នៅប៉ុនដងវែកប៉ុណ្ណោះ ។ លក្តាវណ្ណ បានមានប្រសាសន៍ថា ប្រជាជនម្នាក់ៗត្រូវតែខិតខំធ្វើការងារ បើពុំនោះសោតទេ ខ្មែរក្រហមនឹងយកទៅសម្លាប់ ។ លក្តាវណ្ណ បានដឹងអំពីការសម្លាប់មនុស្សតាមរយៈយាយតាពីរនាក់ដែលគាត់ស្នាក់នៅជាមួយបាននិយាយប្រាប់ ។ យាយតា បានដាស់តឿន លក្តាវណ្ណ ឲ្យប្រយ័ត្នប្រយែង ដោយសារតែនៅឆ្នាំ១៩៧៦ ខ្មែរក្រហមចាប់ផ្តើមយកប្រជាជនថ្មីទៅសម្លាប់ ។ ពេលស្តាប់ឮដំណឹងនេះ លក្តាវណ្ណ ចាប់ផ្តើមព្រួយបារម្ភ ។ គាត់នឹកបារម្ភដល់ឪពុកម្តាយ និងប្អូនៗរបស់គាត់ ។ បើទោះបីជា លក្តាវណ្ណ មានការភិតភ័យយ៉ាងណាក៏ដោយ ក៏គាត់នៅតែខំពង្រឹងចិត្តខ្លួនឯងប្រឹងប្រែងធ្វើការដើម្បីយិតយោងគ្រួសារ និងខ្លួនគាត់ ។

## ប្អូនប្រុសត្រូវខ្មែរក្រហមចាប់ខ្លួន និងទង្វើខុសសីលធម៌

ថ្ងៃមួយ ប្អូនប្រុសរបស់ លក្តាវណ្ណ ឈ្មោះ អ៊ុយ សុភ័ណារិទ្ធ អាយុប្រហែល១៣ឆ្នាំ ត្រូវបានខ្មែរក្រហមចាប់ដោយសារតែប្អូនប្រុសរបស់គាត់បានលួចស្ករមួយស្លាបព្រាយកទៅហូប ។ នៀម អាយុប្រហែល២៣ ឬ២៤ឆ្នាំ ដែលជាយុវជននៅក្នុងសហករណ៍ជាមួយ បានប្រាប់ លក្តាវណ្ណ អំពីការចាប់ខ្លួនប្អូនប្រុសរបស់គាត់ ។ បន្ទាប់ពីបានដឹងដំណឹងនេះ លក្តាវណ្ណ បានរត់ទៅជួយប្អូនប្រុស ។ លក្តាវណ្ណ បានអង្វរអង្គការឲ្យអនុគ្រោះ និងស្នើសុំទទួលកំហុសជំនួសប្អូនប្រុសរបស់គាត់ ពីព្រោះប្អូនគាត់នៅក្មេង មិនសូវយល់ដឹងច្រើន ។ ប៉ុន្តែ អង្គការមិនយល់ព្រមទេ ដោយបានឆ្លើយតបវិញថា “អ្នកណាធ្វើ អ្នកហ្នឹងត្រូវទទួលទោស” ។ នៅក្នុងក្រុមជំនុំជម្រះទោសប្អូនប្រុសរបស់ លក្តាវណ្ណ មានប្រធានយុវជនបីនាក់ និងប្រធានយុវនារីម្នាក់ ។ នៅក្នុងចំណោយុវជនទាំងបីនាក់មានយុវជនម្នាក់ឈ្មោះ យី ។ បន្ទាប់ពីអង្វរកមិនបានសម្រេច លក្តាវណ្ណ បានត្រឡប់មកកងវិញ ។ ក្រោយមក មិត្ត យី បានប្រាប់ថា ប្រសិនបើ លក្តាវណ្ណ ព្រមស្រឡាញ់គាត់ នោះគាត់នឹងជួយឲ្យប្អូនប្រុសរបស់ លក្តាវណ្ណ គាត់រួចទុក្ខទោស ។ លក្តាវណ្ណ បានឆ្លើយប្រាប់ថា ចាំគាត់គិតមើលសិន ។ បន្ទាប់មក លក្តាវណ្ណ បានប្រាប់រឿងនេះទៅមិត្តជិតស្និទ្ធម្នាក់ ឈ្មោះ នី ។ នី បានណែនាំ លក្តាវណ្ណ ឲ្យរាយការណ៍ប្រាប់មិត្តនារី និងមិត្តយុវជនពីរនាក់ផ្សេងទៀតឲ្យបានដឹង ។ បន្ទាប់ពីបានដឹងអំពីហេតុការណ៍ មិត្តនារី និងមិត្តយុវជនបានប្រាប់ លក្តាវណ្ណ ថា នឹងតាមដានសកម្មភាពរបស់មិត្ត យី ។ លក្តាវណ្ណ បានបញ្ជាក់ថា មូលហេតុដែលគាត់រាយការណ៍ប្រាប់ប្រធានយុវជន និងយុវនារី ពីព្រោះគាត់មិនមានចេតនាផ្សំគំនិតជាមួយមិត្ត យី នោះទេ ។

ថ្ងៃមួយនាខែភ្លឺ លក្តាវណ្ណ ត្រូវបានចាត់តាំងឲ្យធ្វើជាចុងភៅ ។ មិត្ត យី បានមកហៅគាត់ចេញទៅតាំងពីម៉ោងបីទៀបភ្លឺ ។ មុននឹងចេញទៅ នី បានផ្តាំ លក្តាវណ្ណ ឲ្យប្រយ័ត្នខ្លួន ។ លក្តាវណ្ណ ក៏តបទៅ នី កុំឲ្យបារម្ភអំពីគាត់ ។ បន្ទាប់មក លក្តាវណ្ណ បានដើរទៅប្រាប់ប្រធាននារីឲ្យជួយគាត់ ប្រសិនបើមានហេតុការណ៍ចៃដន្យណាមួយកើតឡើង ។ មិត្តយី បានឲ្យ លក្តាវណ្ណ ទៅដងទឹកនៅស្រះទឹកមួយខាងក្រោយវត្តពាមមេត្រី ។ ប្រធាននារីបានដើរតាមពីក្រោយ ហើយបានស្រែកហៅ លក្តាវណ្ណ នៅពេលដែលមិត្ត យី បម្រុងនឹងធ្វើសកម្មភាពចាប់គាត់ ។

នៅចុងឆ្នាំ១៩៧៧ បន្ទាប់ពី លក្តាវណ្ណ បានរាយការណ៍អំពីមិត្ត យី ដែលមានបំណងមិនល្អមកលើរូបគាត់ នីរសារខ្មែរក្រហមដែលប្រដាប់ដោយកាំភ្លើងនៅនឹងដៃបានមកហៅគាត់ទៅប្រជុំសាជាថ្មី អំពីរឿងសីលធម៌ ។ ប្រធានសហករណ៍ តាបូរ និងប្រជាជននៅក្នុងសហករណ៍គ្រាន់តែស្តាប់ឮភ្លាម បានខ្សឹបប្រាប់ លក្តាវណ្ណ ឲ្យប្រយ័ត្នខ្លួន ។ នៅពេលដើរតាមផ្លូវពីការដ្ឋានទៅកន្លែងប្រជុំ ប្រជាជនដែលកំពុងកាប់ដីនាំគ្នាឈប់ ហើយសម្លឹងមើលគាត់គ្រប់ៗគ្នា ។ ប្រជាជនទាំងអស់នោះគិតថា គាត់ប្រហែលជាមិនអាចរស់ទេ ។ នៅក្នុងរបបខ្មែរក្រហម ប្រសិនបើប្រជាជនណាម្នាក់ត្រូវបានខ្មែរក្រហមហៅចេញទៅ ពេលកំពុងធ្វើការជននោះ

ច្រើនតែត្រូវបានខ្មែរក្រហមសម្លាប់ ។ នៅកន្លែងប្រជុំ ខ្មែរក្រហមបានបញ្ជាឲ្យ លក្ខាវណ្ណ និងមិត្ត យី និយាយម្នាក់ម្តងអំពីរឿងរ៉ាវដែលបានកើតឡើង ។ មិត្ត យី ចាប់ផ្តើមនិយាយមុន បន្ទាប់មកដល់វេនគាត់ ។ មិត្តយី បានព្យាយាមឆ្លើយបដិសេធនៅពេលដែល លក្ខាវណ្ណ លើកឡើងនូវព្រឹត្តិការណ៍កន្លងមក ។ ប៉ុន្តែ មិត្តយី ត្រូវបានខ្មែរក្រហមហាមនិយាយកាត់សម្តីរបស់ លក្ខាវណ្ណ ។ បន្ទាប់ពីប្រជុំចប់ លក្ខាវណ្ណ ត្រូវបានខ្មែរក្រហមបញ្ជូនត្រឡប់ទៅសហករណ៍វិញ រីឯមិត្តយី ត្រូវបានខ្មែរក្រហមចាប់ដាក់មន្ទីរឃុំឃាំងនៅខេត្តកំពង់ធំ ។ លក្ខាវណ្ណ មិនបានចាំថា មន្ទីរឃុំឃាំងនោះឈ្មោះអ្វីនោះទេ ។

ពេលវេលាកន្លងផុតទៅមិនបានប៉ុន្មានផង មិត្តយី ត្រូវបានខ្មែរក្រហមដោះលែង ហើយបានទៅរក លក្ខាវណ្ណ នៅការដ្ឋានម៉ុំមាត់ស្ទឹងសែននៅម៉ោងសម្រាកហូបបាយថ្ងៃត្រង់ ។ លក្ខាវណ្ណ មិនបានជួប មិត្តយី ទេ ដោយសារតែគាត់ទៅយឺត ។ ក្រោយមក ប្រធានសហករណ៍ឈ្មោះ តាបូរ បានចាត់នីរសារឲ្យទៅហៅ លក្ខាវណ្ណ ។ នៅតាមផ្លូវ លក្ខាវណ្ណ បានជួបជាមួយមិត្តនារីម្នាក់ឈ្មោះ សុខេង ដែលត្រូវជាប្អូនជីដូនមួយរបស់ មិត្តយី ។ សុខេង បានប្រាប់ លក្ខាវណ្ណ ថា ខ្មែរក្រហមមានបំណងរៀបការ លក្ខាវណ្ណ ជាមួយនឹងមិត្តយី តែប្រសិនបើ លក្ខាវណ្ណ មិនស្រឡាញ់ មិត្តយី ទេ សុំឲ្យ លក្ខាវណ្ណ ជម្រាបប្រាប់ប្រធានសហករណ៍ថា ខ្ញុំ (សុខេង) សុខចិត្តរៀបការជាមួយ មិត្តយី ព្រោះខ្ញុំលួចស្រឡាញ់ មិត្តយី ។ នៅពេលដែល លក្ខាវណ្ណ ទៅដល់កន្លែងប្រជុំ ប្រធានអង្គប្រជុំបានសួរគាត់ថា តើគាត់យល់ព្រមរៀបការជាមួយ មិត្តយី ដែរឬទេ? លក្ខាវណ្ណ បានឆ្លើយបដិសេធ ព្រមទាំងបានប្រាប់ប្រធានសហករណ៍ថា គាត់ជាប្រជាជនថ្មី មិនទាន់យល់ច្បាស់អំពីមាគ៌ា និងមិនទាន់បានបម្រើបដិវត្តន៍ឲ្យអស់ពីចិត្តថ្លើមនៅឡើយទេ ។ បើអង្គការចាត់តាំងឲ្យគាត់រៀបការមានកូនចៅ កម្លាំងស្រួចនឹងត្រូវថយ ហេតុដូច្នេះគាត់ស្នើសុំបន្តធ្វើការបម្រើបដិវត្តន៍មួយរយៈសិន ។ មិនតែប៉ុណ្ណោះ លក្ខាវណ្ណ បានជម្រាបប្រាប់ តាបូរ ថា ប្រសិនបើអង្គការចង់ចាត់ចែងឲ្យ មិត្តយី មានគូស្រករ មិត្តនារី សុខេង ស្នើសុំរៀបការជំនួស ។ ប៉ុន្តែ មិត្តយី បានប្រកែកមិនព្រមទទួលយកមិត្តនារី សុខេង ធ្វើជាភរិយាទេ ។ លក្ខាវណ្ណ បានរំលឹកថា មូលហេតុដែលគាត់ហ៊ានតស៊ូបញ្ចេញមតិយោបល់ ដោយសារតែគាត់បានយល់ដឹង និងសិក្សាស្វែងយល់អំពីគោលគំនិតរបស់ខ្មែរក្រហម ។ ជាលទ្ធផល គាត់អាចរក្សាជីវិតរស់តាមរយៈការលើកសរសើរអំពីគោលការណ៍បដិវត្តន៍របស់ខ្មែរក្រហម ។

## គណៈស្រុកចាស់ត្រូវចាប់ខ្លួន គណៈស្រុកថ្មីឡើងមកជំនួស

ក្រោយមក ខ្មែរក្រហមបានបញ្ជូន លក្ខាវណ្ណ ឲ្យទៅធ្វើការនៅក្នុងកងចល័តស្រុក នៅការដ្ឋានក្បែរស្ទឹងមួយជិតភ្នំសន្ទុក ។ ខ្មែរក្រហមបានបញ្ជាឲ្យប្រជាជនរែកដីលុបស្ទឹង ដោយបានបែងចែកជាក្រុមតូចៗ ដែលមួយក្រុមមានគ្នាចំនួនបីនាក់ ពោលគឺធ្វើយ៉ាងណាសម្រេចឲ្យបានបីម៉ែត្រគូបក្នុងមួយថ្ងៃតាមផែនការ ។ នៅទីនោះ គណៈស្រុកឈ្មោះ តា ហឿន ដែលជាអតីតសាស្ត្រាចារ្យវិទ្យាល័យកំពង់ចាម ដែលបានចូលរួមចលនាតស៊ូរបស់ខ្មែរក្រហមនៅក្នុងព្រៃតាំងពីឆ្នាំ១៩៦៨ ជាអ្នកគ្រប់គ្រង ។ តា ហឿន បានចាត់ចែងឲ្យក្រុមចុងភៅរៀបចំបាយដាក់លើធ្នើរផុតពីដី ព្រមទាំងឲ្យគ្របក្រណាត់ពីលើ ។ តាហឿន ជាមនុស្សល្អ និងយកចិត្តទុកដាក់ដល់ប្រជាជន ។ គាត់ធ្លាប់ប្រជុំប្រាប់ប្រជាជនថា «យើងជាអ្នកធ្វើ អីចឹងយើងក៏ជាអ្នកហូបដែលមិនមែនគោខ្ញុំប្រើងអូសនង្គ័ល សេះជាអ្នកស៊ីនោះទេ» ។ មិនយូរប៉ុន្មាន តាហឿន បានបាត់ខ្លួន ។ អ្នកគ្រូបានឮប្រជាជនខ្សឹបខ្សៀវតៗគ្នាថា តាហឿន ត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់ ជាមួយប្រធានសង្កាត់នារីម្នាក់ទៀត ឈ្មោះ លី ។ ប្រជាជនមានសេចក្តីសង្វេគអាណិត តាហឿន និងមិត្តនារី លី ជាពន់ពេក ដោយសារតែអ្នកទាំងពីរមានសន្តានចិត្តល្អ ។ ប៉ុន្តែ ខ្មែរក្រហមបែរជាយល់ឃើញថា តាហឿន កំពុងកសាងទំពស្រួច ដែលអាចនឹងប្រឆាំងបដិវត្តន៍របស់ខ្មែរក្រហមនៅថ្ងៃអនាគត ។

គណៈស្រុកថ្មីឈ្មោះ តាឌី ដែលមកពីខេត្តតាកែវ បានចូលមកគ្រប់គ្រងប្រជាជនជំនួស តាហឿន ។ តាឌី បានប្រជុំប្រាប់ប្រជាជនថា ចាប់ពីពេលនោះតទៅ អង្គការបានប្តូរទិសមិនឲ្យមានប្រជាជនចាស់ឬប្រជាជនថ្មីនោះទេ ដូច្នេះប្រជាជនត្រូវតែចេះស្រឡាញ់គ្នា ។ ផ្ទុយពីសម្តីនោះ តាឌី គឺជាមនុស្សផ្តាច់ការម្នាក់ ។ ប្រជាជនមិនត្រូវបានអនុញ្ញាតឲ្យទៅសួរសុខទុក្ខឪពុកម្តាយ ឬសាច់ញាតិដែលឈឺសម្រាកនៅពេទ្យទេ ។

## ការប៉ុនប៉ងធ្វើអត្តឃាត

បន្ទាប់ពីធ្វើការនៅក្បែរភ្នំសន្ទុកបានមួយរយៈមក លក្ខា

វណ្ណ ត្រូវបានផ្លាស់ទៅធ្វើការនៅភូមិអូរក្រូច ខេត្តកំពង់ធំ នៅតាមផ្លូវបំបែកទៅស្រុកសណ្តាន់ ។ ប្រជាជននៅទីនោះបានហាម លត្តាវណ្ណ កុំឲ្យផ្ទូតទឹកនៅព្រៃក្បែរនោះ ព្រោះជាតំបន់ចាញ់ ។ ប៉ុន្តែ លត្តាវណ្ណ បានលួចទៅផ្ទូតទឹកនៅទីនោះតែម្នាក់ឯងនៅពេលសម្រាកបរិភោគអាហារថ្ងៃត្រង់រួច ។ លត្តាវណ្ណ មានបំណងចង់ធ្វើអត្តឃាតបញ្ចប់ជីវិតខ្លួនឯង ដោយសារតែគាត់ធុញថប់នឹងជីវិតរស់នៅក្នុងរបបខ្មែរក្រហម ។ លត្តាវណ្ណ បានចុះមុជទឹក និងក្បង់ទឹកនោះមកផឹកថែមទៀត ។ លត្តាវណ្ណ បានគិតថា គាត់នឹងចាញ់ស្លាប់ដូចពាក្យប្រជាជនក្នុងភូមិដំណាល ប៉ុន្តែ គាត់មិនបានកើតជំងឺគ្រុនចាញ់នោះទេ ។

មិនយូរប៉ុន្មាន ស្នូរកាំភ្លើងបានបន្លឺឡើងកាន់តែញឹកញាប់ឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ។ លត្តាវណ្ណ បានឮពាក្យចចាមអារ៉ាមថា កងទ័ពរំដោះបានចូលមកដល់ហើយ ។ នៅពេលដែល លត្តាវណ្ណ បានឮដំណឹងនេះ គាត់មិនហ៊ាននិយាយស្តីអ្វីទេ ប៉ុន្តែ គាត់បានលួចអរសប្បាយនៅក្នុងចិត្ត ដោយសង្ឃឹមថារួចផុតពីរបបខ្មែរក្រហម ។

## ក្រោយរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ និងការងារសិល្បៈ

នៅពេលដែលកងទ័ពរំដោះបានចូលមកដល់ប្រជាជនមួយចំនួនបានបបួលឪពុករបស់ លត្តាវណ្ណ រត់ទៅប្រទេសថៃ ។ ប៉ុន្តែ ក្រុមគ្រួសាររបស់ លត្តាវណ្ណ បានធ្វើដំណើរត្រឡប់ទៅស្រុកកោះសូទិន ខេត្តកំពង់ចាមវិញ ដោយសារតែឪពុកម្តាយគាត់ឮថា ប្រជាជនដែលរត់ទៅព្រំដែនថៃជាច្រើនបានស្លាប់ ។

នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៧៩ លត្តាវណ្ណ សម្រេចចិត្តធ្វើដំណើរទៅទីក្រុងភ្នំពេញ បន្ទាប់ពីគាត់បានឮដំណឹងថា រដ្ឋជ្រើសរើសសិល្បករដើម្បីចូលបម្រើការនៅក្នុងក្រសួងវប្បធម៌ ។ លត្តាវណ្ណ បានចូលបម្រើការងារផ្នែករបាំប្រពៃណី ។ ពេលនោះ សិល្បករពុំទាន់ទទួលបានប្រាក់បៀវត្សរ៍ទេ ប៉ុន្តែក្រសួងបានបើកជាអង្ករ និងសម្ភារផ្សេងសម្រាប់ប្រើប្រាស់ប្រចាំខែ ។ ក្រោយមក លត្តាវណ្ណ ទទួលបានប្រាក់បៀវត្សរ៍ប្រចាំខែប្រហែលជា៣០ រៀល ។

នៅខែកញ្ញា ឆ្នាំ១៩៨១ លត្តាវណ្ណ រួមជាមួយសិល្បករប្រហែល៤០នាក់បានចេញទៅសម្តែងរបាំនៅសហភាពសូវៀតរយៈពេលមួយអាទិត្យ និងប្រទេសអាល្លឺម៉ង់មួយអាទិត្យ ។ នៅខែវិច្ឆិកា ឆ្នាំដដែល លត្តាវណ្ណ បានចេញទៅសម្តែងសិល្បៈនៅហាវយ៉ាង ប្រទេសវៀតណាម ។ ឆ្នាំ១៩៩៧ លត្តាវណ្ណ បានចេញទៅប្រទេសបារាំងសម្តែងល្ខោនស្បែកតូច និងសម្តែងល្ខោនស្បែកធំ ។ ឆ្នាំ២០០២ លត្តាវណ្ណ បានទៅច្រៀងឲ្យក្រុមសម្តែងរបាំប្រពៃណី នៅក្នុងកម្មវិធីពាណិជ្ជកម្មអាស៊ានប្រទេសថៃ ។ នៅឆ្នាំ២០០៨ លត្តាវណ្ណ បានដឹកនាំក្រុមសម្តែង នៅក្នុងកម្មវិធីមហោស្រពអាស៊ាននៅប្រទេសភូមា និងមហោស្រពអាស៊ាននៅប្រទេសថៃ នៅឆ្នាំ២០១៧ ។

ទន្ទឹមនឹងការសម្តែងនៅក្រៅប្រទេស លត្តាវណ្ណ បានបង្កើតនូវស្នាដៃជាច្រើនដូចជា ដឹកនាំសម្តែងល្ខោនបាសាក់រឿង «ម៉ាក់ យុងកែវ» «ឃុនឆាងឃុនផែន» «ក្រុងសុភមិត្រ» ។ យីកេរឿង «ហង្សយន្ត» «ចាបជីបកប្បាស» និង «ទុំទាវ» ។ មិនតែប៉ុណ្ណោះ លត្តាវណ្ណ បានចូលរួមដឹកនាំខ្សែភាពយន្តមួយចំនួនដូចជារឿង «ថ្ងៃលិចបំភ្លេចស្នេហ៍» «ជំនោរវាសនា» «ព្រហ្មលិខិតឥតប្រណី» និង «សំឡេងស្លឹក រលឹកស្នេហ៍» ជាដើម ។ ជាងនេះទៅទៀត លត្តាវណ្ណ បានទទួលពានរង្វាន់សម្រាប់ស្នាដៃរឿង «ពៀររំងាប់ដោយការមិនចងពៀរ» ។

លត្តាវណ្ណ បានបញ្ជាក់អំពីមូលហេតុដែលគាត់សម្រេចចិត្តចូលបម្រើការងារផ្នែកសិល្បៈ បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ ដោយសារតែគាត់ស្រឡាញ់សិល្បៈ និងបានសិក្សាផ្នែកយីកេតាំងពីមុនរបបខ្មែរក្រហម ។ លត្តាវណ្ណ បានរំលឹកថា កាលពីគាត់នៅតូច គាត់ចូលចិត្តគូររូបលេង ។ មិនតែប៉ុណ្ណោះ កាលពីពេលដែលគាត់នៅរៀនថ្នាក់ទី៥ (សង្គមចាស់) នៅអនុវិទ្យាល័យជីហែ គាត់ធ្លាប់ប្រឡងជាប់លេខមួយប្រចាំសាលាផ្នែកចម្រៀង ។

នៅឆ្នាំ២០០០ ប្តីរបស់គាត់ឈ្មោះ អោម សាមឌី ដែលជាមន្ត្រីយោធាមួយរូប បានស្លាប់បាត់បង់ជីវិត ។ បច្ចុប្បន្ន លត្តាវណ្ណ ត្រូវបានក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ តែងតាំងជាទីប្រឹក្សាអមក្រសួងនៅក្នុងនាយកដ្ឋានសិល្បៈ បន្ទាប់ពីគាត់បានចូលនិវត្តន៍ ។

លត្តាវណ្ណ បានលើកឡើងថា នៅក្នុងរបបខ្មែរក្រហម គាត់មិនខ្លាចនឹងបញ្ចេញមតិយោបល់ទេ ប្រសិនបើយើងបានយល់ដឹង និងសិក្សាស្វែងយល់អំពីគោលចិត្តគំនិតរបស់ខ្មែរក្រហម តាមរយៈការសរសើរគោលការណ៍បដិវត្តន៍របស់ខ្មែរក្រហម ។

**ម៉ែន ពិចិត្រ**

# អោម មុត : កងនារីស្រែអំបិល

អោម មុត មានស្រុកកំណើតនៅភូមិព្រៃខ្វាវ ឃុំស្តុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ មុត រៀបការជាមួយនឹងប្តីពោះម៉ាយកូន៤ ឈ្មោះ កែវ សួង និងមានកូនបង្កើតម្នាក់ ។ មុត និងគ្រួសារប្រកបរបរធ្វើស្រែ ។ មុត មានឪពុកឈ្មោះ អោម ង៉ែត (ស្លាប់ដោយជំងឺរបេង តាំងពី មុត អាយុ៨ឆ្នាំម្ល៉េះ) និងម្តាយឈ្មោះ កង ម៉ៃ ។ មុត ជាកូនទី៧ ក្នុងចំណោម បងប្អូនប្រុសស្រី៩នាក់ ។

មុត បានរៀនសូត្រត្រឹមថ្នាក់ទី១២ សង្គមចាស់ និងអាចអានបានខ្លះៗ ។ មុត ឈប់រៀនបន្ទាប់ពីឪពុកស្លាប់ ដោយសារតែមិនមានប្រាក់គ្រប់គ្រាន់បង់សាលា ។ មុត បានមកជួយធ្វើស្រែម្តាយ និងបងប្អូនវិញ ។ មុត ធ្វើស្រែជាមួយម្តាយដល់ឆ្នាំ១៩៧២ ខ្មែរក្រហមបានចាត់ឲ្យគាត់ធ្វើការនៅក្នុងកងកុមារ និងឲ្យទៅរែកដីនៅទំនប់កាត់ភ្លុក និងដឹកព្រែកភ្នំភក់ ។ មិនយូរប៉ុន្មាន មានការទម្លាក់គ្រាប់បែកជាច្រើនពីសំណាក់កងទ័ពអាមេរិកដែលគាំទ្ររបប លន់ នល់ ។ ពេលនោះខ្មែរក្រហមបានជ្រើសរើសកុមារដែលមានមាឌធំៗឲ្យចូលធ្វើកងទ័ព ។ មុត ក៏ជាកុមារម្នាក់ក្នុងចំណោមកុមារដទៃទៀតដែលខ្មែរក្រហមជ្រើសដែរ ។ មុត បានឲ្យដឹងថា គាត់មិនស្គាល់ពាក្យថា “កងទ័ព” ជាអ្វីផង ព្រោះនៅក្មេងពេក ។ ពេលនោះ មុត យំ និងតវ៉ាដោយលើកហេតុផលថានៅជួយធ្វើស្រែម្តាយ និងមើលគោក្របី ប៉ុន្តែខ្មែរក្រហមប្រាប់ថា បើគាត់មិនព្រមទៅធ្វើកងទ័ពទេ នឹងធ្វើបាបម្តាយរបស់គាត់ ។ មុត និងម្តាយ គ្មានជម្រើសអ្វី ក្រៅពីឱបគ្នាយំ និងចេញទៅទាំងបង្ខំនោះទេ ។ មុត ត្រូវបានខ្មែរក្រហមជ្រើសរើសឲ្យចូលកង១០១ ដែលមានយាយ សេង ជា



កងនារីកំពុងប្រមូលផលអំបិល នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

អ្នកគ្រប់គ្រង ។ យាយ សេង បានចាត់គាត់ឲ្យធ្វើនីរសារនាំសំបុត្រទៅតាមឃុំក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ ។ ក្រោយមក យាយ សេង បានស្លាប់នៅសមរភូមិ អំឡុងពេលដែលគាត់ទៅប្រយុទ្ធជាមួយទាហាន លន់ នល់ នៅតំបន់៣៣ ។

ក្រោយជ័យជម្នះទូទាំងប្រទេសរបស់កងទ័ពបដិវត្តន៍ខ្មែរក្រហម ១៧ មេសា ១៩៧៥ កងរបស់ មុត ត្រូវបានថ្នាក់លើបញ្ជាឲ្យធ្វើដំណើរបន្តទៅនៅឃុំត្រើយកោះ ខេត្តកំពត ដើម្បីធ្វើស្រែអំបិល ។ មុត ធ្វើការនៅកងនារីស្រែអំបិលរហូតដល់ថ្ងៃដួលរលំនៃរបបខ្មែរក្រហម ។ មុត មិនដែលបានមកលេងម្ដាយទេ ។ ក្នុងអំឡុងពេលនោះ មុត បានរម្លឹកថា អង្គការធ្លាប់បានហៅកងនារីស្រែអំបិលទាំងអស់ឲ្យមកទស្សនកិច្ចតាមរោងចក្រនៅភ្នំពេញម្ដង ប៉ុន្តែគាត់មិនចងចាំថាឆ្នាំណានោះទេ ប៉ុន្តែបើតាមគាត់ប៉ាន់ស្មានប្រហែលនៅឆ្នាំ១៩៧៨ ។ កងនារីស្រែអំបិលទាំងអស់ធ្វើដំណើរមកភ្នំពេញដោយរថភ្លើង ។ ពេលនោះ មុត និងកងនារីស្រែអំបិលទាំងអស់បានទៅទស្សនកិច្ចនៅរោងចក្រកង់ឡាន និងរោងចក្រតម្បាញ ។ អ្វីដែលគួរឲ្យអស់សំណើចចំពោះ មុត គឺអំឡុងពេលទស្សនកិច្ច អង្គការបានចែកនំប៉័ងឲ្យហូបជំនួសបាយ ប៉ុន្តែម្នាក់ៗមិនចេះហូបនំប៉័ងទេ សុខចិត្តអត់ហូប និងត្រឡប់មកវិញដោយពោះទទេ ។

បន្ទាប់ពីកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាម បានជ័យជម្នះលើរបបកម្ពុជាប្រជាធិបតេយ្យ កងនារីរបស់ មុត បាននាំគ្នាភៀសខ្លួនមកតាមផ្លូវភ្នំគិរីរម្យ ឆ្ពោះទៅកំពង់សោម ។ ក្នុងអំឡុងពេលធ្វើដំណើរ មុត បានឲ្យដឹងថា មិនមាននរណាម្នាក់ហ៊ានដើរបែកចេញពីកងទេ ព្រោះយោធាខ្មែរក្រហមបានប្រាប់ថា ប្រសិនបើវៀតណាមចាប់បាននោះនឹងវះពោះញាត់ស្មៅមិនខាន ។ កងនារីស្រែអំបិលរបស់ មុត បានធ្វើដំណើរជិតដល់កំពង់សោម ស្រាប់តែជួបនឹងកងទ័ពវៀតណាម ក៏នាំគ្នាគេចខ្លួនត្រឡប់មកក្រោយវិញ ។ អំឡុងពេលធ្វើដំណើរនៅក្នុងព្រៃ មុត មិនមានស្បៀងអាហារហូបទេ ។ មុត និងអ្នកឯទៀតត្រូវហូបស្លឹកឈើ ក្តួច ឬប្រង់ជំនួសបាយ ។ មុត និងសមាជិកកងទាំងអស់ បានប្តូរផ្លូវធ្វើដំណើរមកខាងស្រុកកណ្ដៀងវិញ ។ នៅតាមផ្លូវធ្វើដំណើរ មុត បានជួបជាមួយនឹងវៀតណាម ក៏ប្រយុទ្ធគ្នា និងរត់បែកខ្ញែកគ្នា ។ ក្រោយមក សមាជិកក្នុងកងរបស់ មុត នៅសល់ប្រហែល១០០នាក់ប៉ុណ្ណោះ ហើយក៏បានជួបនឹងអង្គភាពកងពលទី៣ ដែលមាន តា សេង ជាប្រធានកងពល ។

បន្ទាប់មក សមាជិកកងទាំងអស់ក៏បានភៀសខ្លួនបន្តទៅខេត្តកោះកុង ។ មុត បានធ្វើដំណើរទៅដល់អូរថ្មដារ ហើយនៅអំឡុងឆ្នាំ១៩៨២-៨៣ មុត ត្រូវបានថ្នាក់លើចាត់តាំងឲ្យចូលធ្វើការនៅកងដឹកជញ្ជូន ។ ពេលនោះ មុត ត្រូវដឹកជញ្ជូនគ្រាប់ពីក្នុងទឹកដីថៃយកមកឲ្យកងទ័ពនៅកងពលទី២ និងកងពលទី៣ ។ នៅឆ្នាំ១៩៩១ មុត បានផ្លាស់មករស់នៅភូមិជន្លៀសដៃ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។ អំឡុងពេលនោះ មុត ក៏បានត្រឡប់ទៅភូមិកំណើតនៅខេត្តកំពង់ស្ពឺ និងបានជួបម្ដាយម្ដង ។ គាត់មិនបាននៅភូមិកំណើតជាមួយម្ដាយទេ ព្រោះដីស្រែរបស់គាត់ត្រូវបានអ្នកដទៃយកអស់ ហើយដោយមិនមានដីធ្វើស្រែ គាត់ក៏សម្រេចចិត្តត្រឡប់មករស់នៅភូមិជន្លៀសដៃ រានដីដើម្បីធ្វើស្រែចម្ការរហូតដល់បច្ចុប្បន្ន ។ **ធាន សារៈមុនិន្ទ**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន នឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.d.dccam.org*

# គ្រូរបាំបុរាណដែលរស់ពីរបបខ្មែរក្រហម


អ្នកគ្រូ ពេញ យ៉ុម

អ្នកគ្រូ ពេញ យ៉ុម បច្ចុប្បន្ន មានអាយុ៦៩ឆ្នាំ មានស្រុកកំណើតនៅភូមិកោះរះ ឃុំកោះរះ ស្រុកល្វាឯម ខេត្តកណ្ដាល ។ យ៉ុម មានឪពុកឈ្មោះ ពេញ នួន បានស្លាប់នៅក្នុងរបបខ្មែរក្រហមនៅឆ្នាំ១៩៧៦ ដោយខ្មែរក្រហមបានចោទប្រកាន់ថា បានលួចបេះផ្លែឈើរបស់អង្គការយកមកហូប ។ ចំណែកម្ដាយឈ្មោះ បែត យស បានស្លាប់នៅឆ្នាំ១៩៩៥ ដោយរោគាពាធ ។ យ៉ុម មានបងប្អូនបង្កើតចំនួនបីនាក់ ។ បងប្រុសរបស់ យ៉ុម ឈ្មោះ ពេញ នឹម ត្រូវបានខ្មែរក្រហមជម្លៀសជាមួយប្រពន្ធចេញពីទីក្រុងភ្នំពេញ ទៅខេត្តបាត់ដំបង និងប្អូនឈ្មោះ ពេញ យ៉ន ។

នៅឆ្នាំ១៩៥០ នៅពេលមានអាយុប្រហែល៥ឆ្នាំ យ៉ុម បានមករស់នៅទីក្រុងភ្នំពេញជាមួយម្ដាយចិញ្ចឹមឈ្មោះ យ៉ុន នៅក្នុងរាជដំណាក់ទក្សិណភិរម្យ ។ ម្ដាយចិញ្ចឹមរបស់ យ៉ុម ជាអ្នកបម្រើនៅក្នុងរាជដំណាក់ ។ បន្ទាប់មក យ៉ុម បានចូលហាត់សិល្បៈនៅក្នុងព្រះបរមរាជវាំងតាមរយៈម្ដាយមីងរបស់គាត់ឈ្មោះ ជា ខាន់ ដែលជាគ្រូល្ខោន ។ យ៉ុម បានហាត់សិល្បៈជាមួយម្ដាយមីង និងជាមួយអ្នកគ្រូ ឯម ធាយ ។

រហូតដល់អាយុ១០ឆ្នាំ យ៉ុម បានចេញទៅសម្ដែងដំបូងនៅខេត្តសៀមរាប តាមព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ។ នៅពេលនោះ យ៉ុម ជាអ្នកកាន់ផ្កា និងរាំ ។ យ៉ុម មិនបានរៀនសូត្រច្រើននោះទេ ដោយសារគាត់រវល់ហាត់របាំ និងចេញទៅសម្ដែងនៅតាមខេត្ត ។ បន្ទាប់មក យ៉ុម បានទៅហាត់របាំនៅព្រះរាជដំណាក់ចន្ទឆាយា ។ នៅទីនោះ យ៉ុម បានហាត់រៀនក្បាច់បាត និងពត់ដៃពត់ជើង ដើម្បីសម្ដែងជាតួយក្ស ។ ទន្ទឹមនេះ យ៉ុម ធ្លាប់បានចូលរួមសម្ដែងនៅមុខព្រះអង្គដងកើ និងនៅវត្តភ្នំដើម្បីបួងសួងសុំទឹកភ្លៀង និងសុំក្ដីសុខសប្បាយ ។ នៅសម័យនោះ យ៉ុម ទទួលបានប្រាប់ខបត្តម្ភប្រហែល៣ ទៅ៥រៀល ក្នុងមួយខែ ។ ប្រសិនបើ យ៉ុម បានសម្ដែងនៅក្រៅប្រទេស គាត់ទទួលបានប្រាប់ខបត្តម្ភចំនួន២៥០រៀលថែមទៀត ។

នៅឆ្នាំ១៩៦៦ យ៉ុម បានចេញទៅសម្ដែងនៅប្រទេសឥណ្ឌូនេស៊ីចំនួន២០ថ្ងៃ ជាមួយ លោកតា ហង្ស ធុនហាក់ និងសិល្បករចាស់ក្មេងជាច្រើនរូបទៀត ។ នៅពេលនោះ សិល្បករដែលចូលរួមសម្ដែងគឺមកពីប្រទេសផ្សេងៗ ។ ប្រជាជន និងភ្ញៀវចូលរួមនៅក្នុងកម្មវិធីនោះ ពុំធ្លាប់ស្គាល់ប្រទេសកម្ពុជាទេ ក្រៅអំពីព្រះនាមព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ។ នៅប្រទេសឥណ្ឌូនេស៊ី យ៉ុម បានចូលរួមសម្ដែងឈុតមួយនៅក្នុងរឿង "ព្រះស័ង្ខ និងរបាំម្កុរ" ។

បន្ទាប់ពីត្រឡប់មកពីប្រទេសឥណ្ឌូនេស៊ី យ៉ុម នៅបន្តហាត់របាំរៀងរាល់ព្រឹកនៅព្រះរាជដំណាក់ចន្ទឆាយា ។ សិស្សដែលចូលទៅហាត់របាំតម្រូវឲ្យស្លៀកក្បិន ។ លុះថ្ងៃឡើង គាត់បានទៅហាត់របាំនៅតាមផ្ទះរបស់គ្រូរបាំ ។ ការហាត់របាំតម្រូវឲ្យហ្វឹកហាត់រាល់ថ្ងៃ ជាពិសេសក្បាច់បាត និង ពត់ដៃជើង ដើម្បីជៀសវាងរាងកាយស្ពឹកស្រពន់ មិនរហ័សរហួន ឬទន់ភ្លន់ ។ ប្រសិនបើមានការសម្ដែងរឿងនៅក្នុងកម្មវិធីផ្សេងៗ សិស្សត្រូវហាត់ព្យាមរាល់ថ្ងៃរហូតដល់ថ្ងៃសម្ដែង ។

យ៉ុម បានរំលឹកថា បន្ទាប់ពីព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ទាមទារឯករាជ្យបានពីបារាំង ទ្រង់បានខិតខំកសាងទីក្រុងភ្នំពេញជាបន្តបន្ទាប់ ។ កាលពីដើម នៅមុខព្រះរាជដំណាក់ទក្សិណភិរម្យ ក្បែរវិមានឯករាជ្យបច្ចុប្បន្នគឺជាដីក្រហូង ។ ហេតុដូច្នេះ ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ទ្រង់បានចាត់ចែងឲ្យមានការចាក់ដីបំពេញ និងកសាងវិមានឯករាជ្យ ។ រីឯនៅមុខវត្តបុទុមវិញ ធ្លាប់ហ៊ុមព័ទ្ធទៅដោយព្រៃ និងមានអូរទឹកមួយ ។ យ៉ុម បានមានប្រសាសន៍

ថា គាត់ធ្លាប់វង្វេងម្តាយចិញ្ចឹមរបស់គាត់នៅផ្សារកាប់គោ នៅពេលដែលម្តាយចិញ្ចឹមរបស់គាត់កំពុងដើរទិញម្ហូប ។ យោងតាមសម្តីរបស់ យ៉ុម ផ្សារកាប់គោត្រូវបានបង្កើតឡើងតាំងពីមុនអគារបូឌីញសាងសង់ម៉្លេះ ។ នៅទីនោះ ប្រជាជនបានសង់សត្តឃាតដ្ឋានធំមួយ ។ ក្រោយមក ផ្សារនេះត្រូវបានបង្រួមតូចវិញ បន្ទាប់ពីសំណង់អគារបូឌីញចាប់ផ្តើមសាងសង់ ។ ចំណែកឯ អគារសាលាគរុកោសល្យគឺធ្វើអំពីឈើ និងដំបូលប្រក់ស្ងឹក ។ មិនតែប៉ុណ្ណោះ យ៉ុម ធ្លាប់បានហែហមព្រះបាទ សម្តេចព្រះ នរោត្តម យាងដំណើរទៅលាបំណន់នៅភ្នំគូលែន ខេត្តសៀមរាប វត្តសសរមួយរយ ខេត្តក្រចេះ និងប្រាសាទព្រះវិហារ នៅខេត្តព្រះវិហារ ។

នៅពេលអាយុ១៧ឆ្នាំ យ៉ុម បានរៀបការជាមួយបុរសម្នាក់ដោយមានឪពុកម្តាយជាអ្នកផ្សំផ្គុំ ។ ប្តីរបស់ យ៉ុម ធ្វើការនៅហាងសាប៊ូ ។ ចំណែកឯ យ៉ុម នៅបន្តហាត់របាំនៅក្នុងព្រះបរមរាជវាំងដដែល ។ នៅអាយុ១៨ឆ្នាំ យ៉ុម បានក្លាយជាគ្រូបង្ហាត់របាំ ។ ប៉ុន្តែ យ៉ុម មិនបានបង្ហាត់សិស្សទេ ដោយសារមានគ្រូចាស់ៗនៅច្រើន ។ យ៉ុម បន្តហាត់របាំដូចធម្មតារហូតដល់របបខ្មែរក្រហម ។

នៅល្ងាចថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ ។ ខ្មែរក្រហមបានមកដល់ផ្ទះ យ៉ុម នៅពេលដែលគាត់កំពុងហូបបាយល្ងាច ។ ខ្មែរក្រហមបានប្រាប់ យ៉ុម ឲ្យចាកចេញ និងឲ្យរៀបចំសម្ភារចាំបាច់មួយចំនួនប៉ុណ្ណោះ ត្បិតនឹងបានវិលត្រឡប់មកទីក្រុងវិញក្នុងរយៈពេលបីថ្ងៃទៀត ។ នៅពេលនោះ យ៉ុម និងក្រុមគ្រួសារស្នាក់នៅផ្ទះមួយក្បែរព្រះបរមរាជវាំង ។ បន្ទាប់ពីរៀបចំរបស់របរួចរាល់ យ៉ុម បានធ្វើដំណើរតាមផ្លូវមុខវត្តបទុមសំដៅទៅស្ពានក្បាលថ្នល់ដើម្បីត្រឡប់ទៅស្រុកកំណើត ។ នៅក្នុងពេលជម្លៀស យ៉ុម កំពុងមានផ្ទៃពោះ ។ មានមនុស្សណែនណាន់តាន់តាប់ ដូច្នេះធ្វើឲ្យការធ្វើដំណើរត្រឡប់ទៅស្រុកកំណើតរបស់ យ៉ុម ត្រូវចំណាយពេលយូរ ។ ក្រុមគ្រួសារ យ៉ុម បានលើកអង្ករបន្តិចបន្តួចដែលប្រជាជនជម្លៀសដូចគ្នាទម្លាក់ចោលដាក់លើកង់ ដោយសារតែគាត់ពុំមានកម្លាំង និងមធ្យោបាយដឹកជញ្ជូនសម្ភារបានច្រើន ។

មុននឹងធ្វើដំណើរទៅដល់ស្រុកកំណើត យ៉ុម និងក្រុមគ្រួសារតម្រូវឲ្យឆ្លងទឹក ។ យ៉ុម បានឃើញសាកសពជាច្រើនអណ្តែតពេញផ្ទៃទឹក ។ បន្ទាប់ពីឃើញទិដ្ឋភាពនោះ យ៉ុម មិនហ៊ានដឹកទឹកដែលដួសមកពីទន្លេទេ បើទោះបីទឹកនោះដាំឆ្អិនហើយក៏ដោយ ។ នៅពេល


អ្នកគ្រូ ពេញ យ៉ុម បានបង្ហាត់សិស្សរបាំនៅសាលាវិចិត្រសិល្បៈ កាលពីទសវត្សរ៍ ឆ្នាំ១៩៨០

ដែលក្រុមគ្រួសារធ្វើដំណើរទៅដល់ស្រុកកំណើតនៅភូមិកោះរះ ស្រុកល្វាឯម ខេត្តកណ្តាល យ៉ុម មិនមានផ្ទះនៅទេ ព្រោះផ្ទះចាស់របស់គាត់បានឆេះអស់ដោយសារការទម្លាក់គ្រាប់បែកនៅក្នុងអំឡុងពេលសង្គ្រាម ។ ដូច្នេះ ប្តីរបស់ យ៉ុម បានយកកម្រាលរបស់ទាហានទៅក្រាល និងប្រក់ជាដំបូល ទម្រាំនឹងគាត់កាប់ដើមឈើសង់ខ្ទមលើកផុតពីដីដើម្បីស្នាក់នៅ ។

ពីរបីខែបន្ទាប់ពីជម្លៀសចេញពីទីក្រុងភ្នំពេញ នៅយប់មួយ យ៉ុម បានឈឺពោះសម្រាលកូន ។ ប្តីរបស់ យ៉ុម បានរត់ទៅរកឆ្មបទាំងយប់ ។ សំណាងល្អ ប្តីរបស់ យ៉ុម បានជួបឆ្មបម្នាក់ដែលជម្លៀសមកពីទីក្រុងភ្នំពេញដូចគ្នា បានមកជួយសម្រាលកូនឲ្យ យ៉ុម ដោយសុវត្ថិភាព ។

បន្ទាប់ពីសម្រាលកូនរួច ខ្មែរក្រហមបានចាត់តាំង យ៉ុម ទៅដកសំណាប ប្តីរបស់ យ៉ុម តម្រូវឲ្យទៅដាំបន្លែ ។ ចំណែកឯឪពុកម្តាយរបស់ យ៉ុម ដែលរស់នៅផ្ទះផ្សេងពីគាត់ត្រូវបានចាត់តាំងឲ្យធ្វើការនៅក្នុងកងមនុស្សចាស់ ។ ជារៀងរាល់ថ្ងៃ មុនពេល យ៉ុម ទៅធ្វើការ គាត់បានយកកូនទៅផ្ញើចាស់ៗ ។ លុះដល់ល្ងាច ទើប យ៉ុម ទៅយកកូនត្រឡប់មកផ្ទះវិញ ។ យ៉ុម បានរអ៊ូថា របបអាហារដែលខ្មែរក្រហមបានផ្តល់ឲ្យគាត់មិនគ្រប់គ្រាន់ទេ ។ ជួនកាល យ៉ុម បានសុំបបរបន្ថែមដើម្បីហូបឲ្យមានទឹកដោះគ្រប់គ្រាន់សម្រាប់កូនបៅ ។ យ៉ុម តែងនឹកឆ្ងល់ក្នុងចិត្តថា ស្រូវដែលប្រមូលបានពេញជង្រុក ប៉ុន្តែហេតុអ្វីខ្មែរក្រហមមិនឲ្យប្រជាជនហូបគ្រប់គ្រាន់ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ យ៉ុម មិន ដែលត្អូញត្អែរអំពីភាពខ្វះខាតប្រាប់ខ្មែរក្រហមដែរ ។ នៅពេលដែលប្រធានសហករណ៍សួរគាត់ អំពីរបបអាហារម្តងៗ គាត់តែងតែនិយាយថា គាត់បានហូបឆ្អែតជានិច្ច ។

នៅរដូវទឹកស្រក ឆ្នាំ១៩៧៦ បន្ទាប់ពីជម្លៀសបានមួយឆ្នាំ យ៉ុម បានឈឺគ្រុនញាក់ និងបានទៅសម្រាកនៅមន្ទីរពេទ្យមួយដែលសង់អំពីឈើ ។ នៅទីនោះ ខ្មែរក្រហមបានរៀបចំគ្រែអ្នកជំងឺពីរជួរ ។ យ៉ុម មិនបានទទួលការព្យាបាលត្រឹមត្រូវនោះទេ ក្រៅអំពីលេបថ្នាំអាចម៍ទន្សាយ ។ ជាកុសល យ៉ុម បានជាពីជំងឺ និងបានត្រឡប់ទៅធ្វើការងារដូចធម្មតាវិញ ។ យ៉ុម បានរៀបរាប់ថា ប្រជាជនភាគច្រើនឈឺ ដោយសារតែពុំមានអាហារហូបចុកគ្រប់គ្រាន់ ការរស់នៅខ្វះអនាម័យ និងធ្វើការងារធ្ងន់ ។ ប៉ុន្តែ ប្រសិនបើប្រជាជនណាមិនប្រឹងប្រែងធ្វើការងារ ខ្មែរក្រហមនឹងមិនចែកអាហារឲ្យហូបឡើយ ។ ហេតុដូច្នេះ ប្រជាជនម្នាក់ៗត្រូវតែបញ្ចេញពលកម្មសូម្បីតែកុមារតូចៗ ។ រៀងរាល់យប់ យ៉ុម និងប្តីមិនហ៊ានជជែកគ្នាទេ ។ គាត់ខ្លាចឈ្លបខ្មែរក្រហមស្តាប់ឮ ។ រីឯប្តីរបស់ យ៉ុម ប្រឹងប្រែងធ្វើការងារណាស់ ។ ជារឿយៗ ខ្មែរក្រហមបានលបតាមដានការងារប្តីរបស់គាត់ ពីព្រោះគាត់មានសម្បុរស ដូចជាប្រជាជនដែលធ្លាប់រស់នៅស្រណុកសុខស្រួល និងមិនធ្លាប់ធ្វើការងារលំបាកពីមុនមក ។

ជាអកុសល ឪពុករបស់ យ៉ុម ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ ប្រហែលជានៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ ។ ម្តាយរបស់គាត់បានប្រាប់ថា ឪពុកគាត់ត្រូវខ្មែរក្រហមចាប់ដាក់មន្ទីរឃុំឃាំងនៅបារ៉ុងស្មោការ ដោយសារតែគាត់បានលួចបេះផ្លែឈើសមូហភាព ។ ហេតុដូច្នេះ យ៉ុម និងប្តី មិនហ៊ានលួចបន្លែ ឬផ្លែឈើមកហូបឡើយ ត្បិតខ្លាចខ្មែរក្រហមចាប់យកទៅសម្លាប់ពីបទក្បត់នឹងអង្គការ ។

ជាកុសល កងទ័ពរំដោះបានចូលមកដល់តាមកាណូត ។ កងទ័ពខ្មែរក្រហមបានរត់គេចខ្លួន ចំណែកឯប្រជាជនវិញនាំគ្នារត់ទៅពួននៅផ្ទះរៀងៗខ្លួន ទម្រាំសំឡេងគ្រាប់កាំភ្លើងបានស្ងប់ ។ យ៉ុម បានឃើញកងទ័ពខ្មែរក្រហមមួយចំនួនដោះសម្លៀកបំពាក់ខ្មៅ និងបោះកាំភ្លើងចោលដើម្បីកុំឲ្យទាហានរំដោះសម្លាប់ ។

ភ្លាមៗបន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ យ៉ុម និងក្រុមគ្រួសារមិនបានត្រឡប់មកទីក្រុងភ្នំពេញទេ ។ លុះដល់ខែកក្កដា ឆ្នាំ១៩៧៩ យ៉ុម បាននាំកូនត្រឡប់មកទីក្រុងភ្នំពេញ បន្ទាប់ពីបានទទួលដំណឹងអំពីការប្រកាសស្វែងរកសិល្បករចាស់ៗចូលបម្រើការងារសិល្បៈ ។ នៅពេលនោះ យ៉ុម បានប្រាប់ប្តីឲ្យនៅស្រុកកំណើតមួយរយៈសិន ។ ក្រោយពីបានជួបជុំ និងបានធ្វើការ យ៉ុម បានហៅប្តីឲ្យត្រឡប់ចូលទីក្រុងភ្នំពេញវិញ ។ យ៉ុម និងប្តី ព្រមទាំងកូនបានរស់នៅជាមួយសិល្បករដទៃដូចជា លោកយាយ ជា ខាន់ នៅក្នុងអគារបូឌីញ ។

នៅឆ្នាំ១៩៩០ យ៉ុម បានចូលបង្ហាត់សិល្បៈនៅសាលាមធ្យមវិចិត្រសិល្បៈ នៅក្បែរស្តាតចាស់ រហូតដល់គាត់ចូលនិវត្តន៍នៅឆ្នាំ២០០៥ ។ **ម៉េន ពិចិត្រ និង ខណ្ឌ ខិរៈបុត្រ**

# មិត្តភក្តិដែលខ្ញុំមិនអាចបំភ្លេចបាន នៅក្នុងរបបខ្មែរក្រហម

ក្រៅអំពីភាពលំបាកវេទនា និងការបែកបាក់គ្រួសារដែល អ្នកគ្រូ រស់ ណារី បានជួបប្រទះនៅក្នុងរបបខ្មែរក្រហម ណារី ក៏មានមិត្តជិតស្និទ្ធម្នាក់ដែលបានប្រព្រឹត្តល្អមកលើគាត់នៅក្នុង គ្រាលំបាក ហើយអំពើល្អនេះមានអត្ថន័យជ្រាលជ្រៅខ្លាំងណាស់ សម្រាប់គាត់ ព្រមទាំងបានជំរុញលើកទឹកចិត្តគាត់ឲ្យមានសង្ឃឹម ឡើងវិញ និងនៅរស់រានមានជីវិតមកដល់សព្វថ្ងៃ ។ ណារី បាន បញ្ជាក់ថា បើទោះបីជាពេលវេលាកន្លងផុតទៅច្រើនឆ្នាំមកហើយ ក៏ដោយ ក៏គាត់នៅតែចងចាំ ថុល ជានិច្ច ។ នៅពេលនោះ ថុល មាន ទម្រង់មុខវែង ភ្នែកធំ ច្រមុះស្រួច សម្បុរស្រអែម រាងស្គម និងកម្ពស់ ខ្ពស់ ។ ថុល មានស្រុកកំណើតនៅខេត្តតាកែវ ។ អំពើល្អដែល ថុល មានចំពោះគាត់នៅតែដក់ជាប់ក្នុងចិត្តរបស់គាត់ជានិច្ច ។ បច្ចុប្បន្ន ណារី នៅតែមានអារម្មណ៍រលឹក និងចង់ជួប ថុល ម្តងទៀត ប៉ុន្តែ គាត់មិនដឹងថា បន្ទាប់ពីរបបខ្មែរក្រហមបានដួលរំលំផុតទៅ ថុល រស់ នៅទីណានោះទេ ។



អ្នកគ្រូ រស់ ណារី

ណារី កើតនៅឆ្នាំ១៩៦៨ នៅសង្កាត់លេខ៤ ទីក្រុងភ្នំពេញ គឺគាត់កើតពីរឆ្នាំមុនរដ្ឋប្រហារទម្លាក់សម្តេចព្រះបាទ នរោត្តម សីហនុ ដោយសេនាប្រមុខ លន់ នល់ ។ ណារី មានឪពុកឈ្មោះ រស់ វ៉ាន់ និងម្តាយ គុយ អ៊ុង ។ ណារី ជាកូនស្រីពៅក្នុងចំណោមបង ប្អូនសរុបចំនួន៧នាក់ ។ បច្ចុប្បន្ន ណារី បម្រើការនៅក្នុងនាយកដ្ឋាន សិល្បៈ ។

កាលពីនៅវ័យកុមារ ណារី បានសិក្សានៅសាលាបឋម សិក្សាម៉ាឡាកា នៅក្បែរវត្តបទុមវត្តី ។ ឪពុករបស់ ណារី បាន ប្រកបរបរធាក់ស៊ីក្លូ និងម្តាយលក់ទឹកកក បន្ទាប់ពីបានចូលនិវត្តន៍ ពីអ្នកបម្រើនៅក្នុងព្រះបរមរាជវាំង ។ សិស្សភាគច្រើនដែល រៀននៅសាលាបឋមសិក្សា ម៉ាឡាកា នៅសម័យនោះ គឺជាកូន អ្នកមានទ្រព្យសម្បត្តិ ។ ប៉ុន្តែ ណារី អាចសិក្សានៅទីនោះបាន ដោយសារតែឪពុករបស់គាត់ ។

ជាអកុសល ណារី បានសិក្សាត្រឹមថ្នាក់ទី១០ (សង្គមចាស់) ដែលស្មើនឹងថ្នាក់ទី៣ បច្ចុប្បន្ន ក៏របបខ្មែរក្រហមបានចូលមកដល់ ។ ក្រោយពីកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជន នានា ។ ដោយឡែក ឪពុករបស់ ណារី បានសម្រេចចិត្តនាំគ្រួសារ ធ្វើដំណើរត្រឡប់ទៅស្រុកកំណើតខាងម្តាយនៅខេត្តតាកែវ ។ នៅ ពេលជម្លៀសនោះ បងស្រីម្នាក់របស់ ណារី ដែលបានរៀបការរួច មិនបានធ្វើដំណើរជាមួយគ្រួសារទេ ដ្បិតបងស្រីរបស់គាត់បាន ត្រូវទៅរស់នៅជាមួយឪពុកម្តាយក្មេកនៅខេត្តបាត់ដំបង ។

មុននឹងទៅដល់ខេត្តតាកែវ ណារី និងក្រុមគ្រួសារបានស្នាក់ នៅកោះប្រាក់មួយខែ ទម្រាំរកមធ្យោបាយធ្វើដំណើរបន្តទៅមុខ បាន ។ នៅខេត្តតាកែវ ណារី រស់នៅភូមិអង្គតាសោម ឃុំត្រពាំងធំ ស្រុកត្រាំកក់ ។ កម្មាភិបាលខ្មែរក្រហមបានដាក់ការងារផ្សេងៗឲ្យ គ្រួសាររបស់ ណារី ធ្វើ ដូចជា បងប្រុសនៅក្នុងកងយុវជន បង

ស្រីនៅក្នុងកងនារី ចំណែក ណារី នៅក្នុងកងកុមារី ។

ណារី បានបន្តថា គាត់ធ្លាប់បានឃើញខ្មែរក្រហមយកបុរសនារីវ័យជំទង់ទៅសម្លាប់ចោល គ្រាន់តែអ្នកទាំងពីរបានប្រព្រឹត្តកំហុស ។ ផ្ទុយទៅវិញ ខ្មែរក្រហមមិនសូវតឹងរ៉ឹង ឬធ្វើបាបកុមារតូចៗនោះទេ ។ ចំពោះ ណារី ខ្មែរក្រហមបានចាត់តាំងឲ្យធ្វើការងារផ្សេងៗ ដូចជា រែកដី បោកស្រូវ រែកដី និងដឹកប្រឡាយជាដើម ។ ជួនកាល ណារី បានលួចរត់ទៅជួបម្តាយនៅផ្ទះ ដោយសារតែអារម្មណ៍នឹករលឹកម្តាយខ្លាំងពេក ។ ជាងនេះទៅទៀត ណារី បានស្កាត់ទៅសួរសុខទុក្ខឪពុកម្តងនៅពេលដែលឪពុកគាត់កើតជំងឺហើមសម្រាកព្យាបាលនៅមន្ទីរពេទ្យ ។ ប៉ុន្តែ ខ្មែរក្រហមមិនបានដាក់ទារុណកម្មគាត់ទេ ។ ណារី បានប្រាប់ថា គាត់ធ្លាប់លួចដំឡូងមី អង្ករ និងស្រូវរបស់ខ្មែរក្រហមមកហូប ត្បិតអាហារដែលខ្មែរក្រហមចែកឲ្យមិនគ្រប់គ្រាន់ ។

ជារឿយៗ ណារី តែងតែនឹកឃើញទឹកទន្លេ ដែលគាត់ធ្លាប់រត់លេងកាលពីនៅតូចៗនៅទីក្រុងភ្នំពេញ ។ គាត់នឹកស្រមៃដល់ពេលវេលាទំនេរពីការសិក្សា ហើយបានចូលព្រះបរមរាជវាំងដកផ្សិត និងបេះផ្កាដើម្បីយកទៅលក់នៅវត្តសាលព្រះច័ន្ទនៅតាមមាត់ទន្លេ ។ ណារី អាចចូលព្រះបរមរាជវាំងបាន ដោយសារតែឪពុករបស់គាត់ធ្លាប់បម្រើសម្តេចព្រះបាទ នរោត្តម សីហនុ ។ មិនតែប៉ុណ្ណោះ បងប្រុស និងបងស្រីរបស់គាត់ក៏ធ្វើការងារនៅក្នុងព្រះបរមរាជវាំង និងស្នាក់នៅក្បែរនោះដែរ ។

នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានហៅបងប្រុសឈ្មោះ សុផល ឲ្យទៅជួយភ្ជួរស្រែទាំងកណ្តាលយប់ ។ ប៉ុន្តែ ប្រជាជននៅក្នុងភូមិបានមកខ្សឹបប្រាប់ថា បងប្រុសរបស់គាត់ត្រូវខ្មែរក្រហមនាំទៅសម្លាប់ មិនមែននាំទៅជួយភ្ជួរស្រែនោះទេ ។ ណារី គិតថា ប្រហែលជាខ្មែរក្រហមដឹងថាបងប្រុសរបស់គាត់ធ្លាប់ធ្វើការជាអ្នកបើកបរឲ្យព្រះអង្គម្ចាស់ នរ៉ាដេប៉ូ ។ រីឯកូនស្រីទាំងពីររបស់បងប្រុសគាត់ដែលទៅតាមម្តាយ បានបាត់ដំណឹងរហូតដល់សព្វថ្ងៃ ។

ជាកុសល ណារី បានស្គាល់មិត្តម្នាក់ឈ្មោះ ផុល ដែលជាកូនស្រីរបស់ប្រជាជនមូលដ្ឋាននៅក្នុងកងកុមារជាមួយគ្នា ។ ផុល ជាកុមារីម្នាក់មានសន្តានចិត្តល្អ និងចេះជួយយកអាសាមិត្តភក្តិដូចគ្នា ។ ណារី បានរំលឹកថា នៅពេលដែលគាត់ឈឺជើង ផុល បានដើររកថ្នាំផ្សេងៗមកស្អំជើងឲ្យគាត់ ទម្រាំនឹងគាត់បានជា និងអាចដើរបាន ។ មិនតែប៉ុណ្ណោះ ផុល បានលួចបាយមកឲ្យគាត់បរិភោគជារឿយៗ ។

នៅពេលដែលកងទ័ពវៀតណាមបានចូលមកដល់ប្រទេសកម្ពុជា នៅឆ្នាំ១៩៧៩ ណារី និងគ្រួសារបានរត់គេចខ្លួនពីខេត្តតាកែវទៅខេត្តបាត់ដំបងជាមួយនឹងខ្មែរក្រហម ។ ក្រោយមកគ្រួសាររបស់ ណារី បានធ្វើដំណើរត្រឡប់មកខេត្តតាកែវវិញ ដោយចំណាយពេលប្រហែលជាពីរខែ ។ នៅតាមផ្លូវ បងប្រុសរបស់គាត់ឈ្មោះ រស់ សុខា បានស្លាប់បាត់បង់ជីវិត ដោយសារកើតពិសជើង ហើយគ្មានថ្នាំព្យាបាល និងអាហារហូបចុក ។ ជាវិបាកនៃរបបខ្មែរក្រហម បងរបស់ ណារី និងក្រុមគ្រួសារ ចំនួន៤នាក់បានស្លាប់ និងបាត់ខ្លួន គឺនៅសល់តែបងស្រី រស់ ចាន់បុប្ផា បងប្រុស រស់ សុខមុន្នី តែប៉ុណ្ណោះ ។

នៅខេត្តតាកែវ គ្រួសាររបស់ ណារី ពុំមានដីធ្លី ឬផ្ទះសម្បែងនោះទេ ។ ជាសំណាងល្អ សាច់ញាតិរបស់គាត់បានចែកដីឲ្យមួយផ្នែកសម្រាប់សង់ផ្ទះ ។ នៅឆ្នាំ១៩៨០ ណារី បានចូលរៀនថ្នាក់ទី៣ នៅសាលាបឋមសិក្សាតាកេម ។ បន្ទាប់មក គ្រួសាររបស់ណារី បានចាកចេញពីខេត្តតាកែវ ត្រឡប់មកទីក្រុងភ្នំពេញវិញ បន្ទាប់ពីឪពុករបស់គាត់បានជួបលោកយាយ ជា ខាន់ នៅពេលដែលគាត់ស្វែងរកកូនស្រី ។ នៅទីក្រុងភ្នំពេញ គ្រួសាររបស់ ណារី បានទៅស្នាក់នៅក្បែរស្ពានជ្រោយចង្វារ ។ ណារី បានចូលរៀនថ្នាក់ទី៤ នៅសាលាបឋមសិក្សាបណ្តុះវិជ្ជា ។

បន្ទាប់ពីរៀនបានមួយឆ្នាំ ណារី បានប្រឡងចូលរៀននៅសាលាមធ្យមសិក្សាវិចិត្រសិល្បៈផ្នែកល្ខោននិយាយ ។ ណារី បានរៀននៅទីនោះអស់រយៈពេលប្រហែល១០ឆ្នាំ ។ នៅឆ្នាំ១៩៩០ ណារី បានចូលបម្រើការងារនៅក្នុងនាយកដ្ឋានសិល្បៈ ផ្នែកល្ខោននិយាយ ដែលដឹកនាំដោយលោកគ្រូ ពេជ្រ ទុំក្រវិល ។ នៅក្នុងការងារសិល្បៈ ណារី បានចូលរួមសម្តែងខ្សែភាពយន្តជាច្រើន ដូចជារឿងអប់រំ «ដីយើង» ដែលធ្លាប់ចាក់បញ្ចាំងនៅស្ថានីយទូរទស្សន៍ជាតិកម្ពុជា (ទទក) និងរឿងអប់រំផ្សេងទៀត ។ មិនតែប៉ុណ្ណោះ ណារី ធ្លាប់ចេញទៅសម្តែងនៅក្រៅប្រទេសមួយចំនួន ដូចជាប្រទេសឥណ្ឌា និងដាណឺម៉ាក ជាដើម ។

**យាង សេងហឿន និង ម៉េង ពិចិត្រ**

# វីរភាពម្ដាយខ្ញុំ

ជាស្ត្រីមេម៉ាយដែលទទួលបន្ទុកចិញ្ចឹមកូនប្រុសស្រី៨នាក់ ម្ដាយរបស់ខ្ញុំ កែវ សុច មិនដែលត្អូញត្អែរម្ដងណាឡើយ ចំពោះ អម្រែកគ្រួសារដ៏ធ្ងន់នេះ ។ កាលពីជាង១០ឆ្នាំមុន ដោយសារតែជីវភាពគ្រួសារមានការលំបាកខ្លាំង ម្ដាយខ្ញុំបានសម្រេចចិត្តមកធ្វើជាកម្មករ បោសសម្រាមឲ្យក្រុមហ៊ុនមួយនៅភ្នំពេញ ដើម្បីបានប្រាក់ខ្វះផ្គត់ផ្គង់ជីវភាពគ្រួសារ ។ ពីរឆ្នាំក្រោយមក គាត់បានធ្លាក់ខ្លួនឈឺ ហើយត្រឡប់ទៅស្រុកកំណើតនៅខេត្តតាកែវវិញ ។ បន្ទុកនៃការមើលថែគ្រួសាររបស់ម្ដាយខ្ញុំមិនមែនត្រឹមតែយើងខ្ញុំជាកូនៗនាពេលនេះទេ គាត់មានកាតព្វកិច្ច រួមចំណែកមើលការខុសត្រូវចំពោះគ្រួសាររបស់គាត់ តាំងពីមុន និងក្នុងជំនាន់ខ្មែរក្រហមមកម្ល៉េះ ។

ទោះបីជាខ្ញុំជាក្មេងម្នាក់ដែលកើតមិនទាន់របបខ្មែរក្រហម តែខ្ញុំបានដឹងអំពីរឿងរ៉ាវខ្លះនៃរបបនេះ តាមរយៈម្ដាយខ្ញុំផ្ទាល់ និងចាស់ទុំ ។ អ្វីដែលខ្ញុំចាប់អារម្មណ៍ខ្លាំងនោះគឺ ដំណើរជីវិតរបស់ម្ដាយខ្ញុំផ្ទាល់ ដែលគាត់បានតស៊ូពុះពាររហូតដល់រួចរស់ជីវិតពីរបបនេះ ។ គាត់បានរម្លឹកប្រាប់ខ្ញុំថា ប្រសិនបើគ្មានរបបខ្មែរក្រហម ជីវិតរបស់គាត់ និងគ្រួសារប្រហែលជាប្រសើរជាងនេះ ។ ម្ដាយរបស់ខ្ញុំ ជាកូនទីបួន ក្នុងចំណោមបងប្អូនប្រុសស្រី៩នាក់ ក្នុងគ្រួសារកសិករមួយ ដែលមានឪពុកឈ្មោះ ទន់ ជា និងម្ដាយឈ្មោះ កែវ នី ។ ម្ដាយរបស់ខ្ញុំរៀនសូត្របានត្រឹមថ្នាក់ទី៤ (សង្គមចាស់) ដែលអាចសរសេរ និងអានបាន ។ ការរស់នៅជួបជុំគ្រួសារមិនបានប៉ុន្មានផង នៅថ្ងៃ១៧ មេសា ១៩៧៥ ខ្មែរក្រហមបានរំដោះប្រទេសបានទាំងស្រុងពីរបប លន់ នល់ និងបានធ្វើការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុង និងទីប្រជុំជននានា ។ មិនខុសពីគ្រួសារដទៃ គ្រួសារម្ដាយខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅភូមិដូងខ្ពស់ ។

## មរណភាពលោកយាយខ្ញុំ

មករស់នៅភូមិដូងខ្ពស់បានមួយរយៈលោកយាយរបស់ខ្ញុំ បានសម្រាលកូនម្នាក់ទៀត បន្ទាប់ពីសម្រាលកូនរួចយាយរបស់ខ្ញុំ មានអាការៈមិនស្រួល ។ ពេលនោះ កូនៗនៅកងចល័ត មកពីធ្វើ



ម្ដាយរបស់ សន ល័ក្ខ (រូបពរកូន) និង សន ល័ក្ខ (រូបឈរខាងស្ដាំបង្អស់) ជាមួយបងប្អូនទាំង៨នាក់ និងបងថ្លៃប្រុស (ពាក់អាវយឺតស) ថតនៅអំឡុងទសវត្សរ៍ឆ្នាំ១៩៩០

ការនៅពេលល្ងាច ក៏នាំគ្នារូតរះយកគាត់ទៅពេទ្យតំបន់ ដែលមានចម្ងាយប្រមាណជាងបីគីឡូម៉ែត្រពីភូមិ ។ រឿងដែលគួរឲ្យហួសចិត្តនោះគឺ ពេលដែលនាំយាយរបស់ខ្ញុំទៅដល់មន្ទីរពេទ្យតំបន់ ស្រាប់តែពេទ្យនៅទីនោះប្រាប់ថា គ្មានថ្នាំព្យាបាលយាយរបស់ខ្ញុំទេ ។ មួយសន្ទុះក្រោយមក ពេទ្យម្នាក់បានយកម្រេច និងស្មៅក្រវាញជ្រូក ដែលដកនៅមុខមន្ទីរពេទ្យ មកបុកបញ្ចូលគ្នា និងលាយជាមួយទឹក ហើយច្រោះដាក់ចាន មកបញ្ចុកចូលមាត់យាយរបស់ខ្ញុំ ។ ម្ដាយខ្ញុំបន្តប្រាប់ទៀតថា ពេលនោះយាយរបស់ខ្ញុំបានស្រែកថា «ពេទ្យអើយ! កុំប្រកខ្ញុំ ខ្ញុំដាច់ខ្យល់ឥឡូវហើយ!» ។ ប៉ុន្តែពេទ្យម្នាក់នោះ មិនស្ដាប់ និងនៅតែបញ្ចុកថែមទៀត រហូតដល់លោកយាយដាច់ខ្យល់ស្លាប់ (ម្ដាយខ្ញុំបានបញ្ជាក់ថា នៅមន្ទីរពេទ្យមានតែគាត់ម្នាក់ប៉ុណ្ណោះ ព្រោះពេទ្យមិនឲ្យមានអ្នកកំដរច្រើនទេ) ។ ពេលនោះ មានពេទ្យម្នាក់ឈ្មោះ សួរ បានមកហៅម្ដាយខ្ញុំទៅសម្រាកនៅផ្ទះមីង សន នៅចុងភូមិដូង ខាងកើតមួយយប់ ។ លុះព្រឹកឡើង មីង សន បានឲ្យកូនគាត់ ជូនម្ដាយខ្ញុំមកផ្ទះ ដើម្បីប្រាប់តារបស់ខ្ញុំពីមរណភាពរបស់លោកយាយ និងយកសពលោកយាយមកកប់ ។ អំឡុងពេលនោះ មិនមានព្រះសង្ឃ ឬអាចារ្យទេ ក្រៅតែពីតារបស់ខ្ញុំ និងបងប្រុសពីរនាក់របស់ម្ដាយខ្ញុំ ដែលបានយកឫស្សីធ្វើជាទ្រាសចងរុំសពលោកយាយមុននឹងកប់ ។

## ក្រុមលត់ដី ឬ ក្រុមសែងអាចម៍មនុស្ស

បន្ទាប់ពីមរណភាពលោកយាយ ម្ដាយខ្ញុំត្រូវមានភារៈមើលថែប្អូនតូចដែលទើបនឹងកើតរបស់គាត់ ហើយប្រាំមួយខែក្រោយមក ប្អូនអភ័ព្វរបស់គាត់ក៏បានស្លាប់ទៀត ។ តមក ខ្មែរក្រហមក៏ចាប់ផ្ដើមប្រមូលទ្រព្យសម្បត្តិមកដាក់រួម និងបែងចែកមនុស្សទៅតាមក្រុម តាមកង ។ បងប្អូនរបស់ម្ដាយខ្ញុំ ត្រូវបានអង្គការបែងចែកទៅតាមកងរៀងខ្លួន ។ ម្ដាយខ្ញុំតែងតែលបលួចមើលប្អូនៗដែលកំពុងធ្វើការនៅតាមកង នៅពេលដែលគាត់មានពេលសម្រាកបន្តិចបន្តួច ។ ជាញឹកញយ ម្ដាយខ្ញុំត្រូវមេកងកសាងជាច្រើនសា ព្រោះតែពេលខ្លះគាត់គេចវេះពីការងារទៅមើលប្អូនៗ ។ ក្រោយមក គ្រួសារអ៊ំរបស់ម្ដាយខ្ញុំត្រូវបានអង្គការជម្លៀសទៅខេត្តបាត់ដំបង ពេលនោះម្ដាយខ្ញុំបានទៅជួបមេឃុំដើម្បីស្នើសុំទៅជាមួយនឹងអ៊ំរបស់គាត់ដែរ ប៉ុន្តែត្រូវមេឃុំបដិសេធ ព្រោះអ្នកទាំងនោះ បានចេញដំណើរទៅអស់ហើយ ។

ខុសប្លែកពីបងៗ ឬប្អូនៗ ម្ដាយរបស់ខ្ញុំ ត្រូវបានអង្គការចាត់ឲ្យធ្វើក្នុងក្រុមលត់ដី ។ អង្គការបានប្រាប់ថា បើគាត់ធ្វើមិនបានទេ នោះនឹងត្រូវជម្លៀសទៅឆ្ងាយជាក់ជាមិនខាន ។ ក្រុមលត់ដីនេះ យើងអាចហៅម្យ៉ាងទៀតបានថា ក្រុមសែងអាចម៍មនុស្ស ។ ក្នុងក្រុមនេះ មានសមាជិក៦នាក់ ។ ពីរនាក់ត្រូវចូកអាចម៍ពីបង្គន់ដាក់ធុង ហើយអ្នកឯទៀត នៅទប់ទំនប់ធ្វើជាថ្នាលសម្រាប់ត្រាំសំណាបនៅវាលស្រែ ។ ម្ដាយខ្ញុំបានរម្លឹកពីការងារនោះថា គាត់ត្រូវនៅចាំក្នុងថ្នាល ហើយពេលដែលគេចាក់អាចម៍មក គាត់ត្រូវកាយជ្រុំអាចម៍ឲ្យស្មើនឹងដី ហើយជញ្ជូនសំណាបរៀបពីលើ និងត្រាំឲ្យបានមួយយប់ ។ ការងារក្រុមរបស់គាត់មួយទៀត គឺត្រូវជញ្ជូនសំណាបទាំងនោះទៅឲ្យអ្នកស្ទូងរហូតទាល់តែអស់ ។

មួយរយៈក្រោយមក អង្គការបានដកម្ដាយខ្ញុំពីក្រុមលត់ដីឲ្យទៅកាប់ទន្រ្ទានខែត្រ និងជីកប្រឡាយ ។ ម្ដាយខ្ញុំបានឲ្យដឹងថា ការងារជីកប្រឡាយ អង្គការបានកំណត់ដោយម្នាក់ៗជីកទទឹងបីម៉ែត្រ បណ្ដោយប្រាំម៉ែត្រ និងជម្រៅពីរម៉ែត្រកន្លះ ។ បើនរណាម្នាក់ធ្វើមិនបានតាមអ្វីដែលអង្គការកំណត់ អ្នកទាំងនោះនឹងត្រូវអង្គការយកទៅសម្លាប់ចោលមិនខាន ។ ម្ដាយខ្ញុំបានរំឭកពីរបបអាហារដែលគាត់ទទួលបាននៅពេលនោះថា មិនបានគ្រប់គ្រាន់ទេ គឺទទួលបានតែបបរម្នាក់មួយកា ដែលមានគ្រាប់អង្ករមួយគ្រាប់ៗប៉ុណ្ណោះ ។

## ចាប់ផ្ដើមជីវិតថ្មី

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ ម្ដាយខ្ញុំបានស្វែងរក និងប្រមូលបងប្អូនមកជុំគ្នា ដើម្បីត្រឡប់ទៅស្រុកកំណើតវិញ ។ ប៉ុន្តែគាត់មិនបានជួបបងប្អូនទាំងអស់ទេ ដោយអ្នកខ្លះមិនមានដំណឹងសោះ ។ ពីរឆ្នាំក្រោយមក ទើបគាត់បានឮដំណឹងថា ប្អូនម្នាក់របស់គាត់ត្រូវបានបាញ់សម្លាប់ ។

ម្ដាយរបស់ខ្ញុំ និងគ្រួសារបានត្រឡប់មកភូមិកំណើតវិញ ចាប់ផ្ដើមជីវិតថ្មី ដោយប្រកបរបរធ្វើស្រែ ។ បច្ចុប្បន្ននេះ បន្ទុករបស់ម្ដាយខ្ញុំធូរស្រាលជាងមុន ព្រោះតែកូនៗមួយចំនួនមានគ្រួសារ និងការងារធ្វើដែលអាចជួយសម្រួលដល់ជីវភាពក្នុងគ្រួសារប្រសើរជាងមុន ។ **សន ល័ក្ខ**

# សហព្រះរាជអាជ្ញា បន្តធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ បញ្ចប់កិច្ចពិភាក្សាដេញដោល

**(តចប់)**

### *ការធ្វើទុកបុកម្នេញលើពុទ្ធសាសនិក*

*លោកស្រីសហព្រះរាជអាជ្ញាលើកឡើងថា ជនជាប់ចោទក៏ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការរំលោភបំពានជាមូលដ្ឋាននៃសាសនាចំពោះការធ្វើទុកបុកម្នេញលើពុទ្ធសាសនិក ។ លោកស្រី ជា លាង បានបង្ហាញអំពីគោលនយោបាយនៃបក្សកុម្មុនីស្តកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលផ្តោតទៅលើការបិទវត្តអារ៉ាម ការផ្សឹកព្រះសង្ឃហើយនឹងការហាមប្រាមការគោរពប្រណិប័តន៍ព្រះពុទ្ធសាសនា ។ ព័ត៌មាននេះផ្អែកទៅលើបទពិសោធអ្នកដែលធ្លាប់បានរស់នៅ និងរួចរស់ជីវិតពីរបបនេះ ហើយអ្នកដែលរួចរស់ជីវិតរកឃើញការផ្លាស់ប្តូរមួយក្នុងចំណោមទីពឹងដ៏សំខាន់នៃជីវិតប្រជាជនកម្ពុជានៅពេលដែលប្រជាជនមិនអាចទៅវត្ត និងបួងសួងបាន ។*

*លោកស្រី ជា លាង បានអះអាងថា មិនមានភ័ស្តុតាងដែលជឿជាក់បានពីការបដិសេធរបស់បក្សកុម្មុយនីស្តកម្ពុជាអំពីការលុបបំបាត់ពុទ្ធសាសនា ។ លោកស្រីកត់សម្គាល់ឃើញថា មានការដាក់បញ្ចូលឯកសារ E ចំពោះសេចក្តីសង្ខេបចុងក្រោយរបស់ព្រះរាជអាជ្ញា គ្រប់បញ្ជីសាក្សីដែលមកពីគ្រប់តំបន់មកផ្តល់សក្ខីចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងតំបន់របស់ខ្លួន ។ លោកស្រីបាននិយាយថា ការការពារគួរតែឲ្យអង្គជំនុំជម្រះជឿជាក់ថា វាបានកើតឡើងព្រមគ្នាដែលថា គ្រប់វត្តអារ៉ាមត្រូវបានបិទ ហើយព្រះសង្ឃគ្រប់អង្គត្រូវបានផ្សឹក នៅគ្រប់កន្លែងនៃប្រទេសកម្ពុជាចន្លោះ*



*ជនជាប់ចោទ ខៀវ សំផន នៅក្នុងសវនាការសំណុំរឿង ០០២/២ (រូបថតៈ អ.វ.ត.ក)*

ពេលដែលបក្សកុម្មុយនីស្តកម្ពុជាគ្រប់គ្រងអំណាចក្នុងខែមេសា ១៩៧៥ និងតទៅមុខទៀត ។ គោលនយោបាយនេះត្រូវបានកំណត់ដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅភ្នំពេញ ហើយគោលនយោបាយនេះ ត្រូវបានជូនដាដំណឹងដល់ក្រុមមេដឹកនាំកម្មាភិបាលជាន់ខ្ពស់ទាំងអស់នៅក្នុងកិច្ចប្រជុំមួយនៅភ្នំពេញ ដែលធ្វើឡើងចាប់ពីថ្ងៃទី២០ ដល់ ២៥ ខែឧសភា ឆ្នាំ១៩៧៥ ។ ម្នាក់ក្នុងចំណោមអ្នកដែលរស់ជីវិត ដែលបានចូលរួមកិច្ចប្រជុំនេះ បានផ្តល់សក្ខីកម្មថា ទាំង ប៉ុល ពត និង នួន ជា បាននិយាយអំពីការបិទវត្តអារ៉ាមនៅក្នុងកិច្ចប្រជុំ ។ លើសពីនេះទៀត ម្នាក់ក្នុងចំណោមអ្នកគ្រប់គ្រងតំបន់ត្រាំកក់ដែលចូលរួមប្រជុំនៅថ្ងៃទី២០-២៥ ខែឧសភា គឺ ជាកូនស្រីរបស់តា ម៉ុក ។ នៅពេលដែលនាងត្រឡប់មកពីប្រជុំវិញ នាងបានកោះប្រជុំនៅត្រាំកក់ និងប្រាប់ដំណឹងថា នឹងមានអ្វីកើតឡើងចំពោះវត្តអារ៉ាម ព្រះសង្ឃ និងពុទ្ធសាសនា ។

លោកស្រី ជា លាង បានកត់សម្គាល់ថា មានព្រះសង្ឃពីរអង្គបានផ្តល់សក្ខីកម្មអំពីបទពិសោធផ្ទាល់ខ្លួនអំពីការបង្ខំឲ្យសឹក ។ ព្រះសង្ឃត្រូវបានប្រាប់ថា មិនអាចនៅជាសង្ឃទៀតទេ ហើយដូចជាសង្ឃផ្សេង ត្រូវសឹក ឬដោះស្បង់ជីវរចេញ ។ ព្រះសង្ឃត្រូវបានប្រាប់ថា បើមិនស្តាប់តាមការណែនាំរបស់អង្គការនោះ នឹងត្រូវស្លាប់ ។ ឯកសារដូចគ្នាផ្សេងទៀតបានបញ្ជាក់ពីរបាយការណ៍នៃការតវ៉ារបស់យុទ្ធជនតំបន់ អំពីការបាត់ព្រះសង្ឃ និងកន្លែងបួងសួង ។

វត្តអារ៉ាមជាច្រើនត្រូវបានក្លាយជាគុក និងកន្លែងសម្លាប់មនុស្សរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចជា វត្តបារាយណ៍ជាន់ដែក ដែលមានទីតាំងនៅជិតទំនប់១មករា ។ នៅភូមិភាគនិរតី ១៥ ក្នុងចំណោម២១ មន្ទីរសន្តិសុខ ត្រូវបានដាក់នៅក្នុងវត្ត ។ ទោះជាយ៉ាងណាក៏ដោយ នួន ជា បានអះអាងថា មិនមានការហាមឃាត់លើសាសនាទេ ។ អតីតលេខាស្រុកត្រាំកក់ បានផ្តល់សក្ខីកម្មថា ពុទ្ធសាសនា ត្រូវបានលុបបំបាត់ ព្រោះវាស្ទូតបូតពេក ។ គាត់បានផ្តល់សក្ខីកម្មថា ព្រះសង្ឃត្រូវបានដោះស្បង់ជីវរចេញ ហើយប្រធានឈ្មោះ ខុម ជាអ្នកដាក់បញ្ជា និងខាងឃុំជាអ្នកអនុវត្ត ។

លោកស្រីសហព្រះរាជអាជ្ញា បានលើកឡើងថា ភ័ស្តុតាងនេះគឺច្បាស់ណាស់ថា បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តគោលនយោបាយនេះ ទាំងនៅក្នុងស្រុកត្រាំកក់ និងទូទាំងប្រទេសកម្ពុជា ។

ជាចុងបញ្ចប់ លោកស្រី ជា លាង បានសុំការអនុញ្ញាត ដើម្បីសហភាគារបស់លោកស្រី ព្រះរាជអាជ្ញារងលោក សេង ប៊ុនឃាង ធ្វើបទបង្ហាញអំពីឧក្រិដ្ឋនៃការបង្ខំឲ្យរៀបការដល់អង្គជំនុំជម្រះ ។ លោកប្រធានចៅក្រម និល ណុន បានអនុញ្ញាត ។

## រៀបការដោយបង្ខំ និងការរំលោភ

លោក ប៊ុនឃាង ចាប់ផ្តើមជាមួយនឹងការបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាជឿជាក់ថា បក្សកុម្មុយនីស្តកម្ពុជាចាត់ទុកប្រជាជនកម្ពុជាធម្មតា ជាកម្មសិទ្ធិចំពោះអ្វីមួយដែលខ្លួនរីករាយនឹងធ្វើ ហើយវាត្រូវបានបង្ហាញឲ្យឃើញតាមរយៈ អង្គការប្រើគោលនយោបាយបង្ខំឲ្យបុគ្គលម្នាក់រៀបការជាប្តីប្រពន្ធ និងរួមដំណេក ។

លោកបានបន្តថា គោលនយោបាយនេះ បានញែកជាពីរឧក្រិដ្ឋកម្មគឺ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗៈ ១)ការបង្ខំឲ្យរៀបការ ២)ការរំលោភ ដែលនៅក្នុងករណីនេះ ប្តីប្រពន្ធត្រូវបានបង្ខំឲ្យរួមសង្វាសគ្នា ទាំងម្នាក់ ឬអ្នកទាំងពីរមិនយល់ព្រម ។

លោក ប៊ុនឃាង បានពន្យល់ថា បក្សកុម្មុយនីស្តកម្ពុជា រៀបចំការរៀបការដោយមិនមានការយល់ព្រមពីប្រជាជន ក្នុងគោលបំណងបង្កើតគ្រួសារស្មោះត្រង់ចំពោះអង្គការ ។ វាត្រូវបានអនុវត្តគ្រប់តំបន់ និងតំបន់ស្វយ័តក្នុងប្រទេស ហើយនឹងតាមកងពល ។

លោក ប៊ុនឃាង បានលើកឡើងថា ជនជាប់ចោទទាំងពីរធ្លាប់បានបញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជាមានបំណងបង្កើនចំនួនប្រជាជនកម្ពុជាពី៨លានទៅ១៥ ឬ ២០លាននាក់ ក្នុងរយៈពេល ១០ឆ្នាំ ។ ខៀវ សំផន បានឯកភាពជាមួយអ្នកជំនាញដែលបានអះអាងថា ប៉ុល ពត ចង់បង្កើនចំនួនប្រជាជន និងមិនកាត់បន្ថយទេ ។ ខៀវ សំផន ក៏បានថ្លែងសុន្ទរកថា អំពីអ្វីដែលគាត់ពិភាក្សា និងគាំទ្រចំពោះគោលនយោបាយនេះ ។ នួន ជា បានសារភាពអំពីការគាំទ្រគោលនយោបាយនេះ នៅក្នុងកិច្ចសម្ភាសមួយក្នុងឆ្នាំ១៩៨១ ហើយគាត់បាននិយាយថា ផែនការ៤ឆ្នាំ ពីឆ្នាំ១៩៧៧-១៩៨០ ត្រូវបានធ្វើឡើងដើម្បីបង្កើនចំនួនប្រជាជនឲ្យបាន១៥លាននាក់ ក្នុងរយៈពេល១០-១៥ឆ្នាំ ។

បន្ថែមទៅលើសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទទាំងពីរ លោក ប៊ុនឃាង ក៏បានកត់សម្គាល់ពីឯកសារភ័ស្តុតាង ដែលបក្ស

កុម្មុយនីស្តអះអាងថា ចំនួនប្រជាជនកើនឡើង ប៉ុន្តែមិនច្រើនដូចដែលបក្សត្រូវការទេ ។ លោកបានកត់សម្គាល់ឃើញថា ការសម្រេចគោលដៅនៃការបង្កើនចំនួនប្រជាជនទ្វេដង គឺជាការចាប់ផ្តើមនៃការអត់ឃ្លាន និងការសម្លាប់ នឹងតម្រូវឲ្យមានការកើនឡើងនៃអត្រាបង្កកំណើតដែលមិនធ្លាប់មានពីមុនមក ។ ដើម្បីសម្រេចគោលដៅនេះ បក្សកុម្មុយនីស្តកម្ពុជាបានរៀបចំ និងអនុញ្ញាតឲ្យរៀបការ ។ នួន ជា បានប្រាប់ដល់អ្នកសរសេរជីវប្រវត្តិរបស់គាត់ឈ្មោះ ថេត សម្បត្តិ ថា បុរសតែងតែចង់ជ្រើសរើសនារីស្អាត ហេតុដូច្នេះហើយយើងបង្ខំឲ្យបុរសរៀបការ ហើយអង្គការជាអ្នករើសប្រពន្ធឲ្យ ។

តាមតំបន់ ស្រុកផ្សេងៗ និងបក្សកុម្មុយនីស្តកម្ពុជាជាអ្នកត្រួតពិនិត្យលើពិធីរៀបការ ។ វាគឺជាការអនុវត្តគោលនយោបាយដោយកម្មាភិបាលជាន់ខ្ពស់របស់បក្ស ហើយវាត្រូវបានអនុវត្តទៅលើមនុស្សគ្រប់លំដាប់ថ្នាក់ក្នុងសង្គម ។ ជាឧទាហរណ៍ សាក្សីម្នាក់ដែលធ្វើការនៅក្រសួងពាណិជ្ជកម្មរដ្ឋ ដែលត្រួតពិនិត្យដោយ ខៀវ សំផន ។ នាងបានផ្តល់សក្ខីកម្មថា ខៀវ សំផន បានថ្លែងសុន្ទរកថាដោយលើកឡើងថា កម្មាភិបាលនារីទាំងអស់ត្រូវធ្វើការដើម្បីជាតិ និងកម្មាភិបាលនារីទាំងអស់ដែលមានអាយុលើសពី១៩ឆ្នាំ គួរតែត្រូវរៀបចំឲ្យរៀបការ ។ ខៀវ សំផនមិនបាននិយាយថា ការរៀបការនោះ ធ្វើឡើងដោយការស្រឡាញ់ពេញចិត្ត ឬក៏អត់ទេ ប៉ុន្តែស្ត្រីដែលអាយុ១៩ និងយុទ្ធជនអាយុ២៥ឆ្នាំ គួរតែរៀបចំឲ្យរៀបការ ។ គាត់បាននិយាយថា ហេតុផលនៃការរៀបការនេះ គឺពួកគេត្រូវបង្កើតកូនដើម្បីការពារប្រទេស ។

លោក ប៉ិនយាង បានអះអាងថា សាក្សីផ្សេងទៀត បានផ្តល់សក្ខីកម្មថា នៅក្នុងឆ្នាំ១៩៧៧ ក្រសួងពាណិជ្ជកម្មរដ្ឋ ត្រូវបានប្រាប់ឲ្យការរៀបការយ៉ាងតិច១០០គូ ក្នុងមួយខែ ។ សាក្សីម្នាក់ទៀតមកពីក្រសួងសង្គមកិច្ចបានលើកឡើងថា នាងត្រូវបានបង្ខំឲ្យរៀបការ ហើយអង្គការជាអ្នករៀបចំការរៀបការនេះ ។

លោក ប៉ិនយាង បានអះអាងថា ភស្តុតាងនេះបានបង្ហាញថា គោលនយោបាយរៀបការដំបូង ចេញមកពីមជ្ឈិមបក្ស ។ នៅក្នុងសំណុំរឿង០០២ សាក្សី៥៤នាក់នៃអង្គជំនុំជម្រះបានផ្តល់សក្ខីកម្មអំពីការបង្ខំឲ្យរៀបការ និង១៣១នាក់ បានសរសេររបាយការណ៍នៃកិច្ចសម្ភាសអំពីការបង្ខំឲ្យរៀបការ ។ សាក្សី២៧នាក់ក្នុងតុលាការ បានផ្តល់សក្ខីកម្មថា សាក្សីត្រូវបានបង្ខំឲ្យរៀបការ ៥៩នាក់បានផ្តល់នូវភស្តុតាងដូចគ្នាទៅការិយាល័យសហចៅក្រមស៊ើបអង្កេតថា សាក្សីឃើញផ្ទាល់ភ្នែកពីការបង្ខំឲ្យរៀបការ ។ ភស្តុតាងនេះ គឺគ្របដណ្តប់ទាំងមូល នៅក្នុងសេចក្តីសង្ខេបចុងក្រោយ ។

លោក ប៉ិនយាង បានលើកឡើងថា ភស្តុតាងផ្សេងទៀតអំពីការបង្ខំឲ្យរៀបការលើសំណុំរឿងបង្ហាញពីការបង្ខំឲ្យរៀបការត្រូវបានអនុវត្ត បុរស និងនារី ដែលមិនធ្លាប់បានស្គាល់គ្នាមិនមុនមកតម្រូវឲ្យរៀបការ ។ ជាមួយនឹងការកត់សម្គាល់តិចតួច ឪពុកម្តាយកម្រត្រូវបានអនុញ្ញាតឲ្យមកចូលរួមពិធីការនេះណាស់ ។ បន្ទាប់ពីពិធីរៀបការ គូស្វាមីភរិយា ត្រូវធ្វើការប្តេជ្ញាចំពោះអង្គការ ហើយគោលនយោបាយក៏បានកំណត់ដែរថា អ្នកដែលត្រូវរៀបការជាមួយគ្នាបាន ជាអ្នកដែលមានវណ្ណៈភាពប្រហាក់ប្រហែលគ្នា ។ សាក្សីម្នាក់បានផ្តល់សក្ខីកម្មថា ប្រជាជនមូលដ្ឋានត្រូវតែរៀបការជាមួយប្រជាជនមូលដ្ឋាន មិនមែនប្រជាជន១៧មេសាទេ ពីព្រោះតែប្រជាជន១៧មេសា មានប្រវត្តិរូបមិនច្បាស់លាស់ ។ គាត់និយាយថា វាគឺជាការភ័យខ្លាចដែលថា ប្រជាជន១៧មេសា អាចជាប់ទាក់ទងជាមួយនឹង *KGB* ឬ *CIA* ។ សម្ព័ន្ធយុវជន ឬប្រជាជនចម្រើន គួរតែស្មើជាមួយក្រុមរបស់គេ ហើយដូចជាសមាជិកបក្ស គួរតែស្មើជាមួយសមាជិកបក្សផ្សេងទៀត ។ ការផ្គូផ្គងនេះ មិនបានធ្វើជាឯកសារអ្វីទេ ប៉ុន្តែគ្រាន់តែពិភាក្សានៅក្នុងអង្គប្រជុំប៉ុណ្ណោះ ។

ការបង្ខំឲ្យរៀបការ បានកើតឡើងគ្រប់តំបន់ទាំងអស់នៅក្នុងប្រទេស និងត្រូវបានរាយការណ៍ពីតំបន់ដែលបង្ហាញពីចំនួនប្រជាជនដែលត្រូវរៀបការ ។

លោក ប៉ិនយាង អះអាងថា វាគឺជាការព្រួយបារម្ភមួយដែលថា ការរួបរួមគ្នានេះ មិនបានធ្វើឲ្យមានការគំរាមកំហែងដល់បក្សកុម្មុយនីស្តកម្ពុជាទេ ។ ជាលទ្ធផល ប្តីប្រពន្ធត្រូវបានអនុញ្ញាតឲ្យជួបគ្នា ពីរបីដងក្នុងមួយខែ គ្រប់គ្រាន់ល្មមក្នុងការមានគភ៌ ប៉ុន្តែមិនគ្រប់គ្រាន់ក្នុងការបង្កើតមនោសញ្ចេតនាទេ ។ នេះគឺជាវិធីមួយដែលបក្សកុម្មុយនីស្តកម្ពុជាបានគ្រប់គ្រងមនោសញ្ចេតនាផ្ទាល់ខ្លួនរបស់ប្រជាជន ។ ខៀវ សំផន បានណែនាំលើការគ្រប់គ្រងមនោសញ្ចេតនាផ្ទាល់ខ្លួនប្រហែល៣៩លើក ដែលមនោសញ្ចេតនាទាំងនោះរួមមាន មនោសញ្ចេតនាចំពោះឪពុកម្តាយ កូនៗ ឬនរណា

ម្នាក់ ។ សម្តេច សីហនុ ក៏ធ្លាប់បានផ្លាស់ប្តូរយោបល់ជាមួយ ខៀវ សំផន អំពីបញ្ហានេះដែរ ។ ខៀវ សំផន បានទូលថ្វាយព្រះអង្គ មិនត្រូវមានមនោសញ្ចេតនាគ្រួសារទៀតទេ ប៉ុន្តែត្រូវតែគិតតែពីប្រទេសជាតិតែមួយគត់ ។ បុគ្គលិកក្រសួងពាណិជ្ជកម្មរដ្ឋ បានរម្លឹកថា ខៀវ សំផន និយាយថា យើងរស់នៅក្រោមការគ្រប់គ្រងរបស់អង្គការ និងមិនត្រូវទន្ទឹងចាំឪពុកម្តាយទេ ព្រោះអង្គការគឺជាឪពុកម្តាយហើយ ។

បន្ទាប់មក លោក ប៊ុនយាង បានពិភាក្សាអំពីពិធីរៀបការ វាគ្មានអ្វីដែលថាពិធីរៀបការមានភាពស្រដៀងគ្នាច្រើនទូទាំងប្រទេសទេ ជាមួយនឹងការប្រែប្រួលតូចមួយ ។ វាមិនមែនជាជំហររបស់ព្រះរាជអាជ្ញា ដែលថាគ្រប់ដៃគូក្នុងពិធីរៀបការត្រូវបានបង្ខំឲ្យរៀបការទេ ។ វាត្រូវបានបង្ហាញឲ្យឃើញថា កម្មាភិបាលខ្លះត្រូវបានអនុញ្ញាតឲ្យរៀបការជាមួយដៃគូដែលខ្លួនបានជ្រើសរើស ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកដទៃទៀតក៏មិនអាចមានជម្រើសរៀបការដែរ ទោះបីជាអ្នកទាំងនោះជាកម្មាភិបាលជាន់ខ្ពស់ ឬប្រជាជនថ្មីក៏ដោយ ។ បុរសអាចជ្រើសរើសស្ត្រី ហើយស្ត្រីមិនអាចបដិសេធមិនរៀបការបានទេ ។

សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា គូស្វាមីភរិយាបានបែកផ្លូវគ្នា បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ និងអ្នកផ្សេងទៀតបានលែងគ្នាដោយមូលហេតុផ្សេងៗ ។ លោក ប៊ុនយាង អះអាងថា ហេតុផលទាំងអស់នេះ គឺជាហេតុផលផ្ទាល់ខ្លួនចំពោះបុគ្គល និងជាប់ទាក់ទងនឹងការទទួលខុសត្រូវនៃឧក្រិដ្ឋកម្មចំពោះជនជាប់ចោទក្នុងបទឧក្រិដ្ឋនេះ ។

លោក ប៊ុនយាង បានគូសបញ្ជាក់ពីភ័ស្តុតាងដែលជាប់ទាក់ទងនឹងការបង្ខំឲ្យរៀបការ និងការរួមដំណេក ។ ការបង្ខិតបង្ខំបានបង្ហាញពីការគំរាមកំហែងយ៉ាងច្បាស់ ការដាក់ទណ្ឌកម្ម ហើយនឹងការសម្លាប់ចំពោះអ្នកដែលប្រឆាំងនឹងការរៀបការ ឬការរួមដំណេក ។ ការបង្ខិតបង្ខំបានកើតឡើងដោយគ្មានការតវ៉ា ក្នុងបរិយាកាសមួយនៃភាពភ័យខ្លាចចំពោះការធ្វើទណ្ឌកម្ម នៅក្នុងមជ្ឈដ្ឋានមួយដែលប្រជាជនពិបាកនឹងរួចរស់ជីវិត ។ បរិយាកាសនៃការបង្ខិតបង្ខំទាំងស្រុងនេះត្រូវបានបង្កើតឡើងដើម្បីជាការព្រមានមិនឲ្យសួរទៅអង្គការ ទណ្ឌកម្មសម្រាប់ការបដិសេធនឹងបញ្ហា ទោះបីជាកំហុសតូចតាចក៏ដោយ ឬក៏បំពានច្បាប់ ។ សរុបមក អង្គការមានអំណាចពេញលេញ និងត្រូវបានដឹងថា អ្នកណាដែលប្រឆាំង និងត្រូវទទួលទណ្ឌកម្ម និងសម្លាប់ ។

នៅក្នុងបរិយាកាសនេះ ការពេញចិត្តជាបុគ្គលដែលស្នើសុំរៀបការទៅអង្គការគឺមិនអាចទៅរួច និងការប្រកែកអាចនឹងជាលទ្ធផលនៃការចោទប្រកាន់បុគ្គលនោះជាសត្រូវ និងអាចយកទៅកសាងអប់រំ និងដាក់ទោស ។ ប្រជាជនភាគច្រើនត្រូវបានបង្ខំឲ្យរៀបការ និងបង្ខំឲ្យរួមដំណេក ឬក៏មានអ្នកមកមើលការរួមដំណេក ។ ទាំងបុរស និងស្ត្រី បានផ្តល់សក្ខីកម្មអំពីការបង្ខំឲ្យរៀបការ និងរួមដំណេក ជាមួយនឹងភាពភ័យខ្លាចដែលមិនអាចធ្វើអ្វីបាន ចំពោះលទ្ធផលដែលបុរស នារី នឹងទទួលបានប្រសិនបើជំទាស់ គឺមានតែការធ្វើទោស និងសេចក្តីស្លាប់ប៉ុណ្ណោះ ។ បុរសនារីបានផ្តល់សក្ខីកម្មអំពីការប៉ះពាល់ផ្នែកស្មារតី ដែលជាលទ្ធផលនៃការរៀបការជាមួយអ្នកដែលមិនស្គាល់ ឬមិនស្រឡាញ់ ។

ដើម្បីឲ្យប្រាកដថា ការរួមដំណេកកើតមានឡើង យោធាបានតាមដានប្តីប្រពន្ធថ្មី និងរាយការណ៍ពីអ្វីដែលតាមដានដឹង ដូចជា ប្តីប្រពន្ធថ្មីនិយាយអំពីអង្គការ ការបដិសេធក្នុងការរួមដំណេក ហើយអ្នកដែលបដិសេធក្នុងការរួមដំណេកនេះនឹងត្រូវយកទៅរៀនសូត្រ និងសម្លាប់ ។

លោក ប៊ុនយាង បានអះអាងថា ការរួមដំណេក នៅពេលដែលម្នាក់ ឬអ្នកទាំងពីរមិនព្រមរួមដំណេក អ្នកទាំងពីរនោះ គឺជាគោលដៅនៃការរំលោភ ។ គូស្វាមីជាច្រើនបានរួមដំណេក ពីព្រោះបានដឹងថា ខ្លួនត្រូវបានតាមដាន និងដឹងថា បើមិនរួមដំណេក លទ្ធផល គឺស្លាប់ ។ នៅក្នុងកាលៈទេសៈខ្លះ បុរសបានគំរាមកំហែង និងរាយការណ៍ពីប្រពន្ធរបស់ខ្លួន ប្រសិនបើមិនបានរួមដំណេក និងបុរសខ្លះក៏បង្ខំប្រពន្ធឲ្យរួមដំណេកដែរ ។ នៅពេលដែលប្តីប្រពន្ធមិនបានរួមដំណេក អ្នកទាំងពីរនឹងត្រូវយកទៅរៀនសូត្រ គំរាមកំហែង ទទួលទណ្ឌកម្ម និងសម្លាប់ ។

ស្របពេលដែលក្រុមការពារក្តីបានដឹងថា គោលបំណងនេះគឺដោយបក្សកុម្មុយនីស្តកម្ពុជាចង់បង្កើនការរៀបការ ក្រុមការពារក្តីបានបង្ហាញថា គោលនយោបាយនៃការរៀបការ ដែលបក្សកុម្មុយនីស្តកម្ពុជាតម្រូវឲ្យមានការយល់ព្រមពីភាគីទាំងពីរ ។ ក្រុមការពារ

ក្តីផ្អែកទៅលើសម្អាងហេតុនៃគោលការណ៍សីលធម៌បដិវត្តន៍ ដែលលើកឡើងថា ភាគីទាំងពីរត្រូវតែឯកភាពរៀបការ និងបានអះអាងទៀតថា គោលការណ៍នេះ ឆ្លុះបញ្ចាំងពីតួនាទីរបស់បក្សកុម្មុយនីស្តកម្ពុជា ។ សហព្រះរាជអាជ្ញាបានធ្វើការឆ្លើយតបថា វាមិនមែនតែរឿងមួយដែលត្រូវបដិសេធដោយភ័ស្តុតាងនោះទេ ប៉ុន្តែ ក្រឡេកទៅមើលគោលការណ៍ដទៃទៀត នៅក្នុងកិច្ចពិភាក្សានេះ ក៏ត្រូវបានបដិសេធដែរ ។ ជាឧទាហរណ៍ គោលការណ៍មួយលើកឡើងថា មិនត្រូវធ្វើអ្វីប៉ះពាល់ដល់ប្រជាជនទេ សូម្បីតែម្ជុលមួយដែ ។ គោលការណ៍ទាំងអស់នេះ មិនបានឆ្លុះបញ្ចាំងពីការពិតនៃបក្សកុម្មុយនីស្តកម្ពុជា ដូចជាថា ប្រសិនបើជាការពិតថា ភាគីទាំងពីរតម្រូវឲ្យយល់ព្រមរៀបការ ដែលនេះបង្ហាញយ៉ាងច្បាស់ថា ត្រូវបានកើតឡើងដែលជាលទ្ធផលនៃការបង្ខិតបង្ខំ ។

នួន ជា បានអះអាងថា វាគ្មានឧទាហរណ៍ជាក់លាក់ ឬក៏មូលហេតុថា ហេតុអ្វីការយល់ព្រមមិនអាចធ្វើទៅបាន? លោក ប៊ុនយាង បាននិយាយថា ទាំងអស់វាគ្របដណ្តប់យ៉ាងទូលាយនៅក្នុងសេចក្តីសង្ខេប ប៉ុន្តែការគូសបញ្ជាក់ពីរបីគួរតែត្រូវផ្តល់ឲ្យនៅពេលនេះ ។ នៅក្នុងសក្ខីកម្មរបស់សាក្សីម្នាក់ នាងត្រូវបានរៀបការជាមួយទាហានពិការម្នាក់ ដែលបានពិការភ្នែកក្នុងពេលប្រយុទ្ធ ។ សាក្សីបាននិយាយថា នាងបានរៀបការជាក្រុម អ្នកខ្លះបានយំ និងពីរនាក់បានរត់គេច ។ នាងនិយាយថា នាងបានយំ និងអន់ចិត្តជាខ្លាំង ដោយនាងមិនដែលជួបប្តីមុនថ្ងៃរៀបការ ប៉ុន្តែ អ្នកទាំងពីរនឹងត្រូវយកទៅសម្លាប់ ហេតុនេះ នាងមានតែទ្រាំចំពោះស្ថានភាពនេះ ។ ប្តីរបស់នាងបានពិពណ៌នាពីការរៀបការ ពីអ្វីដែលគាត់ចាំបានទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេតថា គាត់នឹកឃើញថាពេលព្រឹកគាត់ត្រូវរៀបការ ហើយគ្មាននរណាម្នាក់ប្រាប់គាត់ថាគាត់ត្រូវរៀបការនោះទេ គាត់ត្រូវតែរៀបការ ព្រោះត្រូវគោរពតាមបញ្ជាអង្គការ ។ បុរសម្នាក់ទៀត បាននិយាយថា គាត់ត្រូវបានសួរដោយខ្មែរក្រហមអំពីការរៀបការរបស់គាត់ គាត់និយាយថាពួកគាត់ជាបងប្អូន ពីព្រោះនាងជាបងប្អូនជីដូនមួយរបស់គាត់ ប៉ុន្តែប្រសិនបើអ្នកទាំងពីរមិនមែនជាបងប្អូន អ្នកទាំងពីរត្រូវតែតម្រូវឲ្យរួមដំណេក ហើយយោធានឹងលួចស្តាប់ ។ ប្រសិនបើប្រពន្ធបដិសេធរួមដំណេក នាងនឹងត្រូវយកទៅសម្លាប់ ។

លើសពីនេះទៀត ក្រុមការពារក្តីបានអះអាងថា ក្នុងបរិបទវប្បធម៌ខ្មែរ គោលនយោបាយនេះ មិនបានធ្វើឲ្យមានទុក្ខទោសអ្វីឬក៏ចាកចេញពីភាពធម្មតានោះទេ ដូចដែលពួកគេពេញចិត្តនឹងការរៀបចំការរៀបការរបស់ឪពុកម្តាយចំពោះកូនៗ ។ ខៀវ សំផន បាននិយាយថា ការរៀបការរបស់ប្រជាជនកម្ពុជា មិនផ្តោតសំខាន់អំពីការស្រឡាញ់នោះទេ ។

លោក ប៊ុនយាង បាននិយាយថា ក្នុងការការពារបែបនេះ ដែលការការពារបទឧក្រិដ្ឋនៃការបង្ខំឲ្យរៀបការដោយមិនមែនជាលក្ខណៈត្រឹមត្រូវដូចជាការស្រឡាញ់តិចតួច ឬការជាប់ពាក់ព័ន្ធនឹងឪពុកម្តាយមិនបានបង្កើតឲ្យមានឧក្រិដ្ឋកម្មនៃការបង្ខំឲ្យរៀបការទេ ។ អ្វីដែលធ្វើឲ្យកើតមានឡើងនូវឧក្រិដ្ឋកម្មនៃការបង្ខំឲ្យរៀបការនោះគឺ រដ្ឋប្រើអំណាចក្នុងការជ្រើសរើសដៃគូឲ្យប្រជាជន ដាក់ទណ្ឌកម្មប្រជាជនចំពោះការជំទាស់ និងការមិនរួមដំណេក ។

ជាចុងក្រោយ នៅក្នុងសេចក្តីសង្ខេប នួន ជា បានប្រដូចការបង្ខំឲ្យរៀបការទូទាំងប្រទេស ទៅនឹងការជំរុញឲ្យមានកំណើនប្រជាជន ។ គាត់បានពិពណ៌នាថា ការបង្ខំឲ្យរៀបការ ដូចជា ការសម្រេចចិត្ត ប្រតិបត្តិ និងសន្ទុំសំចៃ ហើយនឹងឆ្លើយដោយមិនអាចទទួលយកបានថា យោធាដែលតាមដានប្តីប្រពន្ធឲ្យច្បាស់ថា អ្នកទាំងពីរបានរួមដំណេកឬអត់ យោធាទាំងនោះ គ្រាន់តែធ្វើសកម្មភាពដូចប៉ូលីសធម្មតាដែលការពារភូមិប៉ុណ្ណោះ ។

លោក ប៊ុនយាង បានអះអាងថា មានសាក្សីម្នាក់មិនមែនមានកាតព្វកិច្ចត្រឹមជាប៉ូលីសធម្មតានោះទេ គាត់ត្រូវបានប្រាប់ឲ្យរាយការណ៍ពីប្តីប្រពន្ធណាដែលបដិសេធមិនរួមដំណេកជាមួយគ្នា ។ ដូចគ្នាដែរ សាក្សីទីពីរ ត្រូវបានប្រាប់ឲ្យតាមដានសកម្មភាពប្តីប្រពន្ធដែលទើបរៀបការថ្មីៗ ។ លោក ប៊ុនយាង បានសរុបថា គិតទៅលើអនុសញ្ញាឆ្នាំ១៩៦៦ និងនិយមន័យនៃសិទ្ធិសេរីភាពរៀបការនោះ ចំពោះបក្សកុម្មុយនីស្តកម្ពុជា ការរៀបការគ្មានកន្លែងណាដូចគ្នាសោះ ។

ខៀវ សំផន បាននិយាយថា ការរៀបការរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានធ្វើឲ្យប្រសើរឡើងជាងការរៀបការបែបប្រពៃណី ហើយការរៀបការរបស់បក្សកុម្មុយនីស្តកម្ពុជា ជាការផ្លាស់ប្តូរយ៉ាងសំខាន់ពីការរៀបការតាមការរៀបចំរបស់ឪពុក

ម្តាយ ទៅជាការរៀបចំរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ប៉ុន្តែ លោក ប៉ិនយាង កត់សម្គាល់ឃើញថា សាក្សីយល់ផ្ទុយពីនេះ សាក្សីមានអារម្មណ៍ថា ខ្លួនត្រូវបានដកហូតនូវប្រពៃណីដ៏សំខាន់មួយ នៅក្នុងជីវិត អំពីការជ្រើសរើសដៃគូ និងប្រារព្ធពិធីប្រពៃណី ។

អ្នកឆ្លើយតបជាច្រើនបានសម្គាល់ឃើញថា ការរៀបការដោយបង្ខំគឺជាទិដ្ឋភាពដ៏សំខាន់មួយនៃការរំលោភបំពានក្នុងបក្សកុម្មុយនីស្តកម្ពុជាដែលប្រព្រឹត្តបទឧក្រិដ្ឋប្រឆាំងប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

សហព្រះរាជអាជ្ញាមិនបាននិយាយថា អ្នកទាំងអស់មិនត្រូវបានបង្ខំរៀបការ ប៉ុន្តែស្ថានភាពនៅទីនោះមានមនុស្សច្រើនណាស់ត្រូវបានបង្ខំ និងមានភ័ស្តុតាងដែលអ្នកទាំងនោះត្រូវបានបង្ខំឲ្យរៀបការ ។ ថ្នាក់លើទាំងអស់ដែលជាអ្នកត្រូវទទួលខុសត្រូវលើគោលការណ៍ ច្បាស់ជាបន្ទូរភាពតឹងរឹងនៃច្បាប់រៀបការទាំងបង្ខំ ឬអាចប្រែជាសេចក្តីថ្លែងការណ៍នៃការប្តេជ្ញា និងការពេញចិត្តដោយពិតប្រាកដដើម្បីបន្ធូរទោសឧក្រិដ្ឋរបស់ពួកគេ ។ តែផ្ទុយទៅវិញ សាក្សីផ្សេងទៀតដែលជាកម្មាភិបាល ដែលរៀបចំការរៀបការ និងយល់ស្របដែលថាដៃគូរៀបការទាំងនោះត្រូវបានបង្ខំ ។ ថែមពីនេះទៀត មានអ្នកខ្លះនិយាយថាស្ត្រីមួយចំនួនមិនបានបដិសេធថាមិនចូលចិត្តបុរសនោះទេ តែស្ត្រីមួយនោះបានលែងលះគ្នាបន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ ។ នួន ជា បានជំទាស់ការកើតឡើងនៃការរៀបការក្នុងភូមិភាគផ្សេងៗគ្នា ។ ប៉ុន្តែវាមិនមែនជាការពិតទេ ដោយមានសាក្សីក្នុងភូមិភាគនីមួយៗបានធ្វើសក្ខីកម្មដែលបានរៀបការទាំងបង្ខំក្នុងតំបន់ទាំងនោះ ។

លោក ប៉ិនយាង បានកត់សម្គាល់ថា នួន ជា ហាក់ដូចជាភ្លេចថាលោកបានស្នើសុំសាក្សីម្នាក់នៅក្នុងភូមិភាគពាយ័ព្យ ដែលជាអ្នកផ្តល់ព័ត៌មានពីការរៀបការទាំងបង្ខំក្នុងតំបន់នោះ ។ លោកបានផ្តល់សក្ខីកម្មអំពីខ្លួន និងប្រពន្ធរបស់ខ្លួនបានស្គាល់គ្នាមុនរៀបការ ហើយ លោកក៏បានស្នើសុំរៀបការជាមួយគ្នា ។ ប៉ុន្តែដៃគូផ្សេងទៀតមិនត្រូវបានគេធ្វើដូច្នោះទេ គឺពួកគេត្រូវបានរៀបការទាំងបង្ខំ ។ លោកក៏បានផ្តល់សក្ខីកម្មអំពីបុរសផ្សេងទៀត គឺរៀបការស្គាល់គ្នានៅថ្ងៃដែលពួកគេរៀបការតែម្តង ។ ពួកគេត្រូវបានសួរថាខាងបុរសស្រឡាញ់ខាងនារីទេ ហើយបើពួកគេយល់ព្រមនៅពេលល្ងាច ពួកគេនឹងរៀបការនៅពេលព្រឹកបន្ទាប់ ។

ចុងក្រោយ នួន ជា ជំទាស់ថា ការរៀបចំដៃគូរបស់កងឈ្លបមិនអាចនឹងកើតឡើងទេ ពីព្រោះវាជាការប្រឆាំងនូវទំនៀមទម្លាប់ ។ ប៉ុន្តែនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ជារឿងធម្មតា ។ ឧទាហរណ៍ បក្សកុម្មុយនីស្តកម្ពុជាបានប្រឆាំងនឹងទំនៀមទម្លាប់ដែលឲ្យព្រះសង្ឃធ្វើការ ហើយដាក់ស្ដែង គោលការណ៍នៃការបង្ខំរៀបការទាំងឡាយ បានប្រឆាំងនឹងទំនៀមទម្លាប់របស់កម្ពុជា ។

លោក ប៉ិនយាង បាននិយាយថា បញ្ហានៃការរៀបការទាំងបង្ខំ គឺមិនត្រូវប៉ះពាល់ក្នុងសេចក្តីសន្និដ្ឋានបកិច្ចពិភាក្សាដេញដោល ។ ភ័ស្តុតាងលើការបង្ខំរៀបការ និងការរំលោភ គឺមានច្រើន ការឈឺចាប់ និងមិនអាចប្រកែកបានក្នុងការស្វែររបស់តុលាការដើម្បីស្វែងរកការទទួលកំហុសរបស់ជនជាប់ចោទទៅលើបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ និងចំពោះបទឧក្រិដ្ឋនៃការបង្ខំរៀបការ និងការរំលោភ ។

## មន្ទីរសន្តិសុខ និងការឃុំឃាំង

លោក លីសាក់ នឹងពិភាក្សាអំពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅក្នុងមន្ទីរសន្តិសុខទាំងបួន ឬ មន្ទីរអប់រំ ដូចជា នៅស្រុកត្រាំកក់មានមន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង មន្ទីរសន្តិសុខភ្នំក្រោល និងមន្ទីរសន្តិសុខស-២១ ។ ទាំងនេះគឺជាមន្ទីរសន្តិសុខទាំងបួនក្នុងចំណោមមន្ទីរសន្តិសុខ ១៩៦ ដែលត្រូវបានទទួលស្គាល់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងប្រតិបត្តិការក្នុងរបបនោះ ។

លោក លីសាក់ បានថ្លែងថា ការអនុវត្តសាលក្រមនៅមន្ទីរសន្តិសុខ ស-២១ គឺគ្រាន់តែមួយមន្ទីរសន្តិសុខ តែទំហំនៃសម្លាប់គឺឃោរឃៅព្រៃផ្សៃដែលមិនអាចនឹកស្មានដល់ ។ ពេលនោះមិនមានតុលាការ មិនមានការប្តឹងតវ៉ា មិនមានមេធាវី មិនមានច្បាប់នៅពេលដែលសម្លាប់មនុស្ស ។ តុលាការបានព្យាពី ឌុច ដោយការអនុវត្តសាលក្រមគឺនៅក្រោមការបញ្ជាររបស់ នួន ជា ដែលជាបងធំទីពីរ ។

លោក លីសាក់ បានបង្ហាញរូបភាពរបស់ប្រជាជនមួយចំនួនដែលបានកាត់ទោសក្នុងមន្ទីរសន្តិសុខស-២១ មានស្ត្រីពីអាយុ២៨ឆ្នាំ អតីតឯកអគ្គរាជទូតសូវៀតប្រចាំកម្ពុជា និងក្មេង

ស្រីវៀតណាមដែលមានអាយុ១៣ឆ្នាំ ដែលមានប្អូនប្រុសអាយុ ៨ឆ្នាំ និងឪពុកក៏បានត្រូវបានសម្លាប់ ។

នោះជាយ៉ាងណា លោក លីសាក់ នឹងពិភាក្សាអំពីមន្ទីរសន្តិសុខតែប៉ុណ្ណោះ ។ លោកបាននិយាយអំពីការកើតឡើងក្នុងមន្ទីរសន្តិសុខទាំងបួននៅក្នុងសំណុំរឿងនេះ ដែលវាត្រូវបានធ្វើឡើងវិញនៅក្នុងមន្ទីរសន្តិសុខទូទាំងប្រទេស ។ លោក លីសាក់ បានលើកអំពីឯកសាររបាយការណ៍ដែលមានលេខសម្គាល់ *E31094* ដែលជារបាយការណ៍ប្រចាំខែពីភូមិភាគបស្ចិម ក្នុងខែកក្កដា ឆ្នាំ១៩៧៨ ។ លោកបានរៀបរាប់អំពីរបាយការណ៍ក្នុងការធ្វើឲ្យថ្លែងការណ៍ច្បាស់លាស់របស់គោលការណ៍បក្សនៅក្នុងតំបន់ ហើយត្រូវបានគេយកទៅអនុវត្តទៅលើសត្រូវ ។ របាយការណ៍នោះ រួមជាមួយនឹងប្រជាជនដែលហ៊ានប្រឆាំងនូវកង្វះខាតអាហារ ការធ្វើការហួសកម្លាំង ឬការបែកបាក់គ្រួសារ ។ ក្នុងនោះក៏មាននិយាយអំពីបុរសម្នាក់ដែលត្រូវបានបញ្ជូនទៅអប់រំ ពីព្រោះតែគាត់ជាជនជាតិបារាំងក្នុងសង្គមចាស់ ដោយគាត់ជាអ្នកលេងភ្លេងឲ្យជនបរទេស ។ គ្រប់ចំណុចរបស់របាយការណ៍ដូចដែលសហព្រះរាជអាជ្ញាបានឃើញគឺមានរបាយការណ៍មួយចំនួនទាក់ទងពីកងទ័ពបដិវត្តន៍កម្ពុជា ។

លោក លីសាក់ បាននិយាយថា ជាប់ចោទទាំងពីរបានដឹងច្បាស់ណាស់ពីការកើតឡើងនៅក្នុងប្រទេស ដូចនឹងសហព្រះរាជអាជ្ញាជាតិធ្លាប់បានពិភាក្សាពីថ្ងៃមុន ។ ការប្រជុំរបស់គណៈកម្មាធិការមជ្ឈិមបានចូលរួមដោយ នួន ជា និង ខៀវ សំផន ដោយ ខៀវ សំផន បានទទួលស្គាល់ជាមួយសហចៅក្រមស៊ើបអង្កេត ។ ចម្លល់ទាំងឡាយគឺត្រូវបានលុបបំបាត់ដោយជនជាប់ចោទទាំងពីរបានចូលប្រជុំនៅកន្លែងដែលអ្នកទាំងពីរទទួលបានរបាយការណ៍ពីប្រធានតំបន់ក្នុងទឹកដីរបស់ពួកគេ ។ ប្រធានភូមិភាគបានរាយការណ៍លើការចាប់ខ្លួនដែលធ្វើតាមបញ្ជារបស់អង្គការ និងរាយការណ៍ពីសត្រូវ ។

លោក លីសាក់ បាននិយាយថាឯកសារទាំងនេះត្រូវបានបោសសម្អាតអំពីចំណុចផ្សេងៗដែលក្នុងតំបន់នោះបានកំពុងអនុវត្តជាឯករាជ្យពីថ្នាក់ដឹកនាំកំពូលរបស់បក្ស ។ មន្ទីរសន្តិសុខពីរចុងក្រោយដែលបរាជ័យក្នុងការកម្ចាត់របាយការណ៍ទាំងអស់ គឺមន្ទីរសន្តិសុខស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ។ ដោយជាលទ្ធផលវាមិនមានជំទាស់ធ្ងន់នៃបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តនៅក្នុងមន្ទីរសន្តិសុខនោះទេ ជាមួយនឹងសក្ខីកម្មរបស់សាក្សី ។

នៅក្នុងសេចក្តីសន្និដ្ឋានរបស់លោក លីសាក់ នឹងត្រូវបន្តនៅថ្ងៃស្អែក ។ លោកនឹងលើកអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលលោកជឿថាជាអ្វីដែលទាក់ទងជិតស្និទ្ធជាមួយនឹងមន្ទីរសន្តិសុខ ដូចជា ការឃុំឃាំង ការសម្លាប់ ការធ្វើទុក្ខបុកម្នេញ ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗ ។ លោកនឹងស្នើសុំសេចក្តីសន្និដ្ឋានខ្លះទៅលើការទទួលខុសត្រូវលើជនជាប់ចោទនៅលើបទឧក្រិដ្ឋទាំងឡាយ ។

លោក លីសាក់ បានចាប់ផ្តើមពិភាក្សាពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការដាក់ពន្ធធានាគារដោយមិនមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងអាចឲ្យនិយមន័យដូចនឹងការដកហូតនូវសិទ្ធិសេរីភាពរបស់ប្រជាជនតាមអំពើចិត្ត ។ លោកបាននិយាយទៀតថា ជនរងគ្រោះរាប់ពាន់នាក់ត្រូវបានដកហូតសិទ្ធិសេរីភាព និងឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខទាំងបួន ។ ក្នុងចំណោមសាក្សីរាប់រយនាក់ដែលបានធ្វើសក្ខីកម្ម មិនមានអ្នកណានិយាយអំពីមានតុលាការ ចៅក្រម ឬក៏សវនាការសម្រេចឡើយ ។ មានតែប្រធានបក្សតែប៉ុណ្ណោះដែលជាអ្នកសម្រេចថាត្រូវចាប់ខ្លួន និងត្រូវកម្ទេចចោល ។ លោកបានកត់សម្គាល់ថា វាជានិយមន័យដ៏ត្រឹមត្រូវនៃការធ្វើតាមអំពើចិត្តក្នុងការដាក់ពន្ធនាគារ និងការដាក់ទោស ។

បន្ថែមពីការថ្លែងការណ៍របស់សាក្សី គឺមានសល់ឯកសារមួយចំនួនដែលទាក់ទងនឹងបទឧក្រិដ្ឋទាំងនោះ ។ ឧទាហរណ៍ ទូរលេខដែលបានបញ្ជូនដោយអនុលេខាធិការភូមិភាគឦសានទៅដល់ភ្នំពេញដោយត្រូវបានសម្រេចថា កម្មាភិបាល ធី គួរតែប្រើវិធីសម្ងាត់ដើម្បីទាញយកបណ្តេញរបស់អ្នកដែលត្រូវបានសម្គាល់ជាអំពើមិនសមរម្យ ។ លោក លីសាក់ បាននិយាយថាវាមិនសមហេតុផលស្របច្បាប់ក្នុងការចាប់ខ្លួន និងឃុំឃាំងនរណាម្នាក់ដោយផ្អែកលើបណ្តាញគ្រួសារ ឬអ្នកជាប់ទាក់ទងរបស់ពួកគេ ។ នេះមិនមែនជាដំណើរការត្រឹមត្រូវទេ ប៉ុន្តែជាការទទួលស្គាល់ដោយការជាប់ទាក់ទង ។

**វ៉ូនិត អាវី**

# សេចក្តីថ្លែងការណ៍របស់ការិយាល័យសហព្រះរាជអាជ្ញា ស្តីពីសំណុំរឿង០០៤/២

វិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថា ខណៈដែលដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ត្រូវបានដាក់ជាការសម្ងាត់ក៏ដោយ ក៏សហព្រះរាជអាជ្ញាអាចបញ្ចេញនូវសេចក្តីសង្ខេបអំពីគោលបំណងនៃសេចក្តីសន្និដ្ឋានរបស់ខ្លួនជូនសាធារណជនបានដែរ ។ ដើម្បីសាធារណៈបានជ្រាប សហព្រះរាជអាជ្ញាសូមផ្តល់ជូននូវសេចក្តីសង្ខេបព័ត៌មានដូចខាងក្រោម ដែលមាននៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ទាក់ទងនឹងកិច្ចស៊ើបសួរក្នុងសំណុំរឿង អោ អាន ។ អ្នកអានគួរយល់ថា សេចក្តីសង្ខេបខាងក្រោមនេះ មិនរាប់បញ្ចូលទស្សនរបស់មេធាវីការពារក្តី និងទោះក្នុងមធ្យោបាយណាក៏ដោយក៏មិនមែនមានចេតនាឆ្លុះបញ្ចាំងអំពីទស្សនរបស់សហចៅក្រមស៊ើបអង្កេត (“សចស”) ដែលនឹងធ្វើការកំណត់លើបញ្ហាទាំងអស់នេះដោយផ្ទាល់ទេ ។

ដីកាសន្និដ្ឋានស្ថាពរត្រូវបានចេញដោយសហព្រះរាជអាជ្ញា ដោយមានការយល់ឃើញដូចគ្នាជាមួយសហចៅក្រមស៊ើបអង្កេត(“សចស”) ដែរថាកិច្ចស៊ើបសួរត្រូវបានបញ្ចប់ និងសហព្រះរាជអាជ្ញាអាចស្នើឲ្យ សចស ធ្វើការចោទប្រកាន់ជនត្រូវចោទដើម្បីបញ្ជូនទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់ក្នុងសំណុំរឿងនេះ ។

នៅថ្ងៃទី១៨ និងថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពររៀងៗខ្លួនសម្រាប់សំណុំរឿង០០៤/២ ដែលជាការស៊ើបសួរនៅក្នុងរឿងក្តី អោ អាន ។ មេធាវីការពារក្តី អោ អាន អាចនឹងមានឱកាសឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរនេះជាមួយនឹងទស្សនរបស់ខ្លួនអំពីភ័ស្តុតាងទាំងឡាយ ។ បន្ទាប់មកវាអាស្រ័យលើសហចៅក្រមស៊ើបអង្កេត ដែលនឹងសម្រេចថាតើ អោ អាន ត្រូវស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណា និងថាតើការស៊ើបសួរនេះបានបង្ហាញឲ្យឃើញអំពីការទទួលខុសត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដល់បទដ្ឋាន ដែលតម្រូវដើម្បីចោទប្រកាន់គាត់ និងបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះឬយ៉ាងណា ។ ដូចគ្នាទៅនឹងជនត្រូវចោទ និងជនជាប់ចោទទាំងអស់នៅ អ.វ.ត.ក អោ អាន នៅតែសន្មត់ទុកជាមុន



ជនជាប់ចោទ នួន ជា និងមេធាវី នៅក្នុងសវនាការសំណុំរឿង ០០២/១ (របថតៈអ.វ.ត.ក)

ថាមិនទាន់មានទោសនៅឡើយ លើកលែងតែនៅពេលដែលពិរុទ្ធភាព ត្រូវបានបង្ហាញនៅពេលសវនាការ និងតាមរយៈបណ្តឹងសាទុក្ខតែប៉ុណ្ណោះ ។

សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានស្ថាពរដាច់ដោយឡែកពីគ្នានៅក្នុងសំណុំរឿងប្រឆាំងនឹង អោ អាន នេះ ដោយឆ្លុះបញ្ចាំងពីទស្សនៈផ្សេងៗគ្នារបស់ខ្លួនលើសំណុំរឿងនេះ ។

**សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាជាតិ**

សហព្រះរាជអាជ្ញាជាតិយល់ឃើញថា យោងតាមលទ្ធផលតាំងពីដំបូងនៃការស៊ើបអង្កេតបឋម និងរហូតមកដល់ការបិទកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញាជាតិបានពិនិត្យ និងមានជំហរយ៉ាងច្បាស់ថា មានតែជនជាប់ចោទដែលមានស្រាប់នៅ អ.វ.ត.ក ប៉ុណ្ណោះដែលជាមេដឹកនាំជាន់ខ្ពស់ និងជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ដូច្នេះគួរតែផ្តល់អាទិភាពទៅលើការវិនិច្ឆ័យទោសជនជាប់ចោទទាំងនេះ ដើម្បីបំពេញឲ្យបានគ្រប់គ្រាន់ ចំពោះអាណត្តិរបស់តុលាការនេះ ដោយហេតុថា ច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បានគិតទុកជាមុនអំពីការវិនិច្ឆ័យទោសចំពោះតែបុគ្គលមួយចំនួនតូចតែប៉ុណ្ណោះ ។ ជាពិសេស នៅក្នុងច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀងដែលអង្គការសហប្រជាជាតិបានទទួលស្គាល់ការព្រួយបារម្ភពេញច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា និងប្រជាជនកម្ពុជា ក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខនោះ បានតម្រូវឲ្យសហព្រះរាជអាជ្ញា ជ្រើសរើសយកបុគ្គលតែពីរប្រភេទប៉ុណ្ណោះមកធ្វើការវិនិច្ឆ័យសេចក្តីគឺមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ ១៩៧៩ ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាជាតិ ប្រកាន់ជំហរថាយោងតាមច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង គឺ អោ អាន ដែលមានឈ្មោះស្ថិតនៅក្នុងសំណុំរឿងលេខ ០០៤/២ មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែលត្រូវយកមកធ្វើការកាត់សេចក្តីឡើយ ។

**សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ-យុត្តាធិការបុគ្គល**

សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា អោ អាន គឺស្ថិតក្នុងយុត្តាធិការរបស់តុលាការ ដោយហេតុថា មានភស្តុតាងបញ្ជាក់តាមរយៈកិច្ចស៊ើបសួរដោយបានកំណត់រូបគាត់ថា គាត់គឺជា “មេដឹកនាំជាន់ខ្ពស់” ផង និងទាំងជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែល “ទទួលខុសត្រូវខ្ពស់បំផុត” ផង ដែលស្ថិតក្នុងខ្លឹមសារនៃច្បាប់ អ.វ.ត.ក ដែលបង្ហាញថាយុត្តាធិការបុគ្គលរបស់តុលាការមានក្នុងសំណុំរឿងនេះ ។ សហព្រះរាជអាជ្ញាអន្តរជាតិក៏ផ្តល់នូវការវិភាគរបស់ខ្លួនលើភស្តុតាងនានាដែលបានប្រមូលបាននៅក្នុងការស៊ើបអង្កេត និងការពន្យល់តាមទស្សនៈរបស់ខ្លួនអំពីមូលហេតុដែលបង្ហាញឲ្យឃើញអំពីការទទួលខុសត្រូវរបស់ អោ អាន ចំពោះឧក្រិដ្ឋកម្ម ធ្ងន់ធ្ងរស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ចំពោះបទដ្ឋានដែលចាំបាច់ត្រូវចោទប្រកាន់គាត់ និងបញ្ជូនគាត់ទៅជំនុំជម្រះ ។

ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិលើកទឡ្ហីករណ៍ថា អោ អាន មានមុខតំណែងទទួលខុសត្រូវ ដែលផ្តល់លទ្ធភាពឲ្យគាត់ធ្វើការចូលរួមចំណែកយ៉ាងសំខាន់ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មនានា នៅក្នុងតំបន់ដែលបានអនុវត្តសិទ្ធិអំណាចរបស់គាត់ ។ រឿងក្តីនេះផ្តោតទៅលើរយៈពេលចាប់ពីដើមឆ្នាំ ១៩៧៧ ដល់ ១៩៧៩ នៅពេលដែល អោ អាន គឺជាអនុលេខាភូមិភាគកណ្តាល (អនុលេខារបស់ កែ ពក) និងជាលេខា តំបន់ ៤១ ។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា មុខតំណែងសិទ្ធិអំណាចនេះបានដាក់ អោ អាន ស្ថិតនៅក្នុងក្រុមកម្មាភិបាលតូចមួយដែលមានអំណាច ឬជា “មេដឹកនាំជាន់ខ្ពស់” ដែលស្ថិតនៅក្នុងជួរកំពូលរបស់បក្សកុម្មុយនិស្តកម្ពុជា (“បកក”) ។ ក្នុងនាមជាអនុលេខារបស់ភូមិភាគមួយក្នុងចំណោមភូមិភាគតែប្រាំពីរប៉ុណ្ណោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អោ អាន មានអំណាច និងត្រួតត្រាលើផ្នែកសំខាន់មួយនៃដែនដី និងប្រជាជនទាំងមូល ។ លើសនេះទៀត ជាញឹកញាប់ រូបគាត់បានធ្វើជាលេខាស្តីទីនៃភូមិភាគ

កណ្តាល នៅពេលដែល កែ ពក អវត្តមាន ។ មុខតំណែងរបស់ អោ អាន ជាលេខាភូមិភាគ ក៏ធ្វើឲ្យគាត់ទទួលខុសត្រូវផងដែរចំពោះសន្តិសុខនៅក្នុងភូមិភាគ ជាតួនាទីសំខាន់មួយដែលឲ្យគាត់ត្រួតពិនិត្យមើល និងគ្រប់គ្រងមន្ទីរសន្តិសុខចំនួន ២៥ នៅក្នុងភូមិភាគកណ្តាលដែលជាផ្នែកមួយនៃរចនាសម្ព័ន្ធសន្តិសុខរបស់របបកម្ពុជាប្រជាធិបតេយ្យទាំងមូល ។ អោ អាន ក៏បានទទួលសេចក្តីណែនាំផ្ទាល់ពី កែ ពក និង តាម៉ុក ដែលការណ៍នេះបង្ហាញឲ្យឃើញអំពីចំណងទាក់ទងជិតស្និទ្ធរបស់គាត់ជាមួយនឹងថ្នាក់ខ្ពស់បំផុតរបស់បកក ក៏ដូចជាទំនុកចិត្តដែលមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម មានចំពោះគាត់ ដើម្បីអនុវត្តគោលនយោបាយរបស់បក្ស ។

ក្នុងនាមជាលេខាតំបន់ ៤១ អោ អាន បានអនុវត្តសិទ្ធិអំណាចពេញលេញលើស្រុកចំនួនប្រាំ នៅក្នុងខេត្តកំពង់ចាមៈ ស្រុកកំពង់សៀម ស្រុកព្រៃឈរ ស្រុកបាធាយ ស្រុកជើងព្រៃ និងស្រុកកងមាស ។ នៅក្នុងតំបន់ទាំងអស់នេះ អោ អាន ទទួលខុសត្រូវស្ទើរតែលើគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតរស់នៅរបស់ប្រជាជនរាប់ពាន់នាក់ ដែលរស់នៅទីនោះ ។ ពិសេសបំផុតនោះ និងដូចដែលបានពិភាក្សាពេញលេញជាងនេះនៅខាងក្រោម អោ អាន និងអ្នកក្រោមបង្គាប់គាត់ បានអនុវត្តអំណាចស្លាប់រស់លើអ្នកទាំងឡាយណា ដែលរស់នៅក្នុងភូមិ និងតាមឃុំនានាក្នុងតំបន់ ៤១ និងលើអ្នកដែលមិនមានសំណាងដើម្បីដាក់ពួកគេក្នុងមន្ទីរសន្តិសុខតំបន់ ។

សហព្រះរាជអាជ្ញាអន្តរជាតិក៏សន្និដ្ឋានផងដែរថា អោ អាន ត្រូវទៅនឹងលក្ខណៈវិនិច្ឆ័យទីពីរសម្រាប់ការដាក់បញ្ចូលទៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដោយសាររូបគាត់ស្ថិតក្នុងចំណោមជនទាំងឡាយដែល (ទទួលខុសត្រូវខ្ពស់បំផុត) ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិដោយរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងអំឡុងពេលដែល អោ អាន មានសិទ្ធិអំណាចនៅលើតំបន់ ៤១ តំបន់នេះគឺជាគោលដៅនៃការបោសសម្អាតខ្លាំងក្លា ដែលជាលទ្ធផលនាំឲ្យមានការសម្លាប់ក្រៅប្រព័ន្ធតុលាការនូវមនុស្សប្រុសស្រី និងក្មេងៗជាច្រើនពាន់នាក់ ។ ឧក្រិដ្ឋកម្មដែលរូបគាត់ត្រូវបានចោទប្រកាន់ មានស្ថានទម្ងន់ធ្ងន់ធ្ងរបំផុត រួមទាំងអំពើប្រល័យពូជសាសន៍ផង ។ កម្រិតនៃការទទួលខុសត្រូវរបស់ អោ អាន ចំពោះឧក្រិដ្ឋកម្មទាំងនោះគឺមានកម្រិតធ្ងន់ធ្ងរណាស់ ដែលក្នុងនោះរួមមានអំពើប្រល័យពូជសាសន៍ជាដើម ។ កម្រិតនៃការទទួលខុសត្រូវរបស់ អោ អាន ចំពោះឧក្រិដ្ឋកម្មទាំងនេះ គឺខ្ពស់ណាស់ ។ តាមទស្សនៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ភ័ស្តុតាងបង្ហាញឲ្យឃើញអំពីទំនាក់ទំនងផ្ទាល់រវាង អោ អាន និងឧក្រិដ្ឋកម្មទាំងនោះ ដោយរួមបញ្ចូលទាំងភ័ស្តុតាងដែលគាត់បានបញ្ជាដោយខ្លួនឯងផ្ទាល់ឲ្យសម្លាប់មនុស្សរាប់ពាន់នាក់ និយាយឲ្យចំ គឺចាម និងក្រុមផ្សេងទៀត ដែលត្រូវបានកំណត់គោលដៅដោយរបបកម្ពុជាប្រជាធិបតេយ្យ ។

## សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ - ការទទួលខុសត្រូវព្រហ្មទណ្ឌ

សហព្រះរាជអាជ្ញាអន្តរជាតិលើកទឡ្ហីករណ៍ថា អោ អាន គួរត្រូវបញ្ជូនខ្លួនទៅជំនុំជម្រះ និងកាត់សេចក្តីចំពោះបទប្រល័យពូជសាសន៍លើជនជាតិចាម និងចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញខាងសាសនា និងនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ជាពិសេស លក្ខខណ្ឌអមនុស្សធម៌នៃការ ឃុំឃាំង ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភសេពសន្ថវៈ នៅក្នុងបរិបទ នៃអាពាហ៍ពិពាហ៍ដោយបង្ខំ) ។ ភ័ស្តុតាងនៅក្នុងសំណុំរឿងនេះបង្ហាញថា ការបោសសម្អាតនៅក្នុងតំបន់ ៤១ មានមុខងារជាប្រព័ន្ធតែមួយគត់ ដែលតម្រូវឲ្យមានកិច្ចសម្របសម្រួលរៀបចំឡើងដោយថ្នាក់ដឹកនាំតំបន់ និងភូមិភាគ ។ នៅចំណុចសំខាន់បំផុតនៃប្រព័ន្ធនេះគឺ អោ អាន ដែលមានការិយាល័យនៅជួរប្រសព្វចំកណ្តាល នៃតំបន់នេះ ជាប់ទៅនឹងផ្សារព្រៃទទឹង ដែលជាកន្លែងអ្នកទោសរាប់ពាន់នាក់ត្រូវបានប្រមូលមកពីតាមតំបន់ ត្រូវបានបញ្ជូនតាមរថយន្តដែលបន្ទាប់មកបញ្ជូនទៅកាន់មន្ទីរសន្តិសុខ ឬកន្លែងសម្លាប់ ។ សំណុំរឿងប្រឆាំងនឹង អោ អាន ផ្តោតលើមន្ទីរសន្តិសុខចំនួនប្រាំមួយ ទីតាំងសម្លាប់ចំនួនពីរ និងការដ្ឋានការងារចំនួនមួយ នៅក្នុងតំបន់ ៤១ ដែលមានទំនាក់ទំនងផ្ទាល់ទៅនឹង អោ អានក្នុងអំឡុងពេលកាន់មុខតំណែងរបស់គាត់នៅក្នុងតំបន់នោះៈ

១) មន្ទីរសន្តិសុខវត្តតាម៉ាក់គឺជាគុកថ្នាក់តំបន់នៅក្នុងស្រុកព្រៃឈរ មានចំងាយមិនដល់មួយគីឡូម៉ែត្រពីមន្ទីរតំបន់របស់ អោ អាន ។ បរិវេណនោះត្រូវបានប្រើសម្រាប់វគ្គអប់រំនយោបាយ កន្លែងឃុំឃាំង ការធ្វើទារុណកម្ម និងសម្លាប់អ្នកទោស ។

២) មន្ទីរសន្តិសុខ គ (មិត្តសុប) គឺជាគុកថ្នាក់តំបន់ស្ថិតនៅក្នុងស្រុកព្រៃឈរ ជាទីដែលប្រជាជនត្រូវបានឃុំខ្លួន ត្រូវស្ថិតក្នុងលក្ខខណ្ឌអមនុស្សធម៌ រងទារុណកម្ម និងត្រូវសម្លាប់ ។ សាកសពប្រមាណជា២.០០០នាក់ ត្រូវបានរកឃើញនៅក្នុងបរិវេណនៃមន្ទីរសន្តិសុខនេះ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ និងមានភ័ស្តុតាងបញ្ជាក់ថា ចំនួនសាកសពជាច្រើនផ្សេងទៀតត្រូវបានដុតចោល ។

៣) ទីកន្លែងសម្លាប់ភ្នំប្រុស នៅស្រុកកំពង់សៀម គឺជាកន្លែងដែលអ្នកទោសជាច្រើនមកពីមន្ទីរសន្តិសុខនានា និងពីកន្លែងផ្សេងៗទៀតនៅទូទាំងភូមិភាគ ជាពិសេសតំបន់៤១ ត្រូវបានសម្លាប់ចោល ។ ការសម្លាប់បានចាប់ផ្តើមនៅទីកន្លែងនេះ បន្ទាប់ពី អោ អាន និងកម្មាភិបាលផ្សេងៗទៀតពីភូមិភាគនិរតីកាន់កាប់ទីកន្លែងនេះ ហើយរណ្តៅសាកសពរួមជាច្រើនត្រូវបានរកឃើញនៅទីកន្លែងនោះ នៅក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ រណ្តៅទាំងនេះមានអដ្ឋិធាតុជនរងគ្រោះប្រមាណជា៧.៣០០ នាក់ ឬច្រើនជាងនេះ ។

៤) មន្ទីរសន្តិសុខទួលបេង និងវត្តអន្លង់ដី ជាមន្ទីរសន្តិសុខកម្រិតស្រុក តាំងនៅក្នុងស្រុកកំពង់សៀម ដែលជនរងគ្រោះត្រូវបានធ្វើទុក្ខបុកម្នេញ ដាក់ក្នុងមន្ទីរឃុំឃាំង និងក្រោយមក ត្រូវបានសម្លាប់ចោល ។ គ្រួសារជនជាតិចាម ត្រូវបានផ្តោតគោលដៅជាពិសេសនៅទួលបេង រួមមាន ជាង ១០០ គ្រួសារ មកពីភូមិនានានៅម្តុំនោះ ។ ចំនួនជនរងគ្រោះដែលបានប៉ាន់ប្រមាណនៅទីកន្លែងទាំងនេះមានចំនួនរហូតដល់ទៅ ១.០០០នាក់ ។

៥) ទីកន្លែងសម្លាប់គោកព្រីង ជាវាលពិឃាតធំមួយ មានទីតាំងនៅមាត់ច្រាំងបឹងមួយ ក្បែរភូមិក្តីបឹង នៅស្រុកកំពង់សៀម ។ ប្រជាជនរាប់រយនាក់ត្រូវបានធ្វើឃាតនៅទីនោះ តាមបញ្ជាផ្ទាល់របស់ អោ អាន រួមមាន "ប្រជាជន១៧មេសា" ជនជាតិចាម និងប្រជាជនស៊ីវិលធម្មតា ដែលបានសង្ស័យថាមិនស្មោះត្រង់ទៅនឹងរបបនោះ ដូចជា កម្មាភិបាល និងជនដែលមានឋានន្តរសក្តិខ្ពស់មកពីរបបចាស់ ជាទូទៅត្រូវបានបញ្ជូនទៅកាន់មន្ទីរសន្តិសុខស្រុក ឬតំបន់ ។

៦) មន្ទីរសន្តិសុខវត្តបាធាយ នៅក្នុងស្រុកបាធាយត្រូវបានប្រើប្រាស់ជាមន្ទីរសន្តិសុខកម្រិតស្រុក ដែលជនជាតិចាម ប្រជាជនមកពីភូមិភាគបូព៌ា ប្រជាជនស៊ីវិលធម្មតាដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើស រួមទាំង អតីតកម្មាភិបាលដែលគេចោទថាជាខ្មាំង ត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំង ធ្វើទារុណកម្ម ធ្វើទុក្ខបុកម្នេញ និងសម្លាប់ចោល ។ ប្រជាជនប្រមាណពី ៨.០០០ ទៅ១០.០០០ នាក់ ត្រូវបានសម្លាប់ចោល និងកប់នៅក្នុងរណ្តៅពី ៤០០ ទៅ ៥០០ រណ្តៅសព ដែលបានរកឃើញនៅទីកន្លែងនេះ ។

៧) មន្ទីរសន្តិសុខវត្តអូរត្រកួន នៅក្នុងស្រុកកងមាស ជាគុកមួយក្នុងចំណោមគុកដែលមានអ្នកស្លាប់ច្រើនបំផុតនៅក្នុងកិច្ចប្រតិបត្តិការក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ ។ មនុស្សជាង ២០.០០០ នាក់ ត្រូវបានប៉ាន់ប្រមាណថាបានសម្លាប់នៅទីនោះ ដែលភាគច្រើនបន្ទាប់ពីត្រូវបានដាក់ឲ្យនៅក្រោមលក្ខខណ្ឌអមនុស្សធម៌ និងអំពើទារុណកម្ម ។ ទីកន្លែងនេះជាកន្លែងមួយសំខាន់ដែល ប.ក.ក បានបន្តតាមដាននូវគោលនយោបាយរបស់ខ្លួនក្នុងការសម្លាប់ "ប្រជាជន១៧មេសា" និងជនជាតិចាមមូស្លីម ។

៨) ទំនប់អន្ទង់ជ្រៃ នៅព្រំប្រទល់ស្រុកព្រៃឈរ និងស្រុកជើងព្រៃ ជាការដ្ឋានកម្រិតតំបន់ដែលមានប្រជាជនរាប់ម៉ឺននាក់មកពីតំបន់ ត្រូវបានបង្ខំឲ្យសាងសង់ទំនប់ ។ ទំនប់នេះ ត្រូវបានគ្រប់គ្រងដោយផ្ទាល់ និងត្រូវបានចុះពិនិត្យជាញឹកញាប់ដោយ អោ អាន និងអ្នកនៅក្រោមបង្គាប់របស់គាត់ ។ ប្រជាជនធ្វើការនៅទំនប់នេះធ្វើពលកម្មធ្ងន់ធ្ងរជាច្រើនម៉ោង នៅក្នុងលក្ខខណ្ឌគួរឲ្យអាណិត ។ ការចាប់ខ្លួន ការបាត់ខ្លួន និងការសម្លាប់ចោល ជាញឹកញាប់ គឺជាការដាក់ទណ្ឌកម្មចំពោះពួកជនដែលធ្វើមិនបានតាមកូតាចាត់ចែងដោយពួកមន្ត្រីកម្ពុជាប្រជាធិបតេយ្យ ។

សហព្រះរាជអាជ្ញាអន្តរជាតិក៏មានទស្សនៈថា បន្ថែមទៅនឹងឧក្រិដ្ឋកម្មនៅទីកន្លែងខាងលើនេះ ភ័ស្តុតាងបានគាំទ្រដល់ការបញ្ជូន អោ អាន ទៅជំនុំជម្រះចំពោះការធ្វើទុក្ខបុកម្នេញ និងអំពើប្រល័យពូជសាសន៍ជនជាតិចាមក្នុងដែនដីទាំងមូលក្រោមការគ្រប់គ្រង

របស់គាត់ ព្រមទាំងអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈនៅស្រុកកំពង់សៀម និងស្រុកព្រៃឈរ ។ ជាពិសេស ភស្តុតាងបង្ហាញថា ៖

**១) ការធ្វើទុក្ខបុកម្នេញ និងអំពើប្រល័យពូជសាសន៍លើជនជាតិចាម ៖** អោ អាន បានកោះប្រជុំលេខាស្រុកទាំងប្រាំនៅក្នុងតំបន់ ៤១ នៅមន្ទីររបស់គាត់ក្នុងស្រុកព្រៃឈរ ដោយគាត់បានណែនាំឲ្យពួកគេកំណត់អត្តសញ្ញាណចាមទាំងអស់នៅក្នុងស្រុករបស់ពួកគេរៀងៗខ្លួន និង "កម្ទេច" ពួកគេចោល ។ អ្នកក្រោមបង្គាប់របស់គាត់បានបង្កើតបញ្ជីជនជាតិចាម ហើយបន្ទាប់មក ពួកគេត្រូវបានចាប់ខ្លួន និងសម្លាប់ជាប្រព័ន្ធ ហើយធ្វើរបាយការណ៍ត្រឡប់ទៅអោ អាន វិញថា បញ្ជាត្រូវបានអនុវត្តហើយ ។ មិនដូចមនុស្សដែលត្រូវបានគេចាប់ខ្លួនផ្សេងទៀតទេ ចាមត្រូវបានឃុំខ្លួនតែមួយរយៈពេលខ្លីដោយគ្មានការសួរចម្លើយ ឬត្រូវបានសម្លាប់ចោលភ្លាមៗតែម្តង ដែលនេះសរបញ្ជាក់ឲ្យឃើញថា ពួកគេត្រូវបានសម្លាប់មិនមែនដោយសារពួកគេបានប្រព្រឹត្ត "កំហុស" ឬ ជាផ្នែកនៃ "បណ្តាញក្បត់" នោះទេ ប៉ុន្តែដោយគ្រាន់តែពួកគេជាចាមប៉ុណ្ណោះ ។ ជនជាតិចាមរាប់ពាន់នាក់ត្រូវបានគេសម្លាប់នៅតំបន់ ៤១ ដោយសារតែភាពហ្មត់ចត់និងភាពក្លៀវក្លាដែល អោ អាន និងអ្នកក្រោមបង្គាប់របស់គាត់ បានប្តេជ្ញាចិត្តអនុវត្តក្នុងគោលបំណងលុបបំបាត់ក្រុមនេះទាំងមូល ។

**២) អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ ៖** ក្នុងស្រុកព្រៃឈរ និងកំពង់សៀម អោ អាន និងអ្នកក្រោមបង្គាប់របស់គាត់បានអនុវត្តគោលនយោបាយ បកក ស្តីពីអាពាហ៍ពិពាហ៍ និងការរួមសង្វាស ។ អោ អាន បានចាត់ចែង អនុម័តិ និងចូលរួមជាអធិបតីដោយផ្ទាល់នៅក្នុងអាពាហ៍ពិពាហ៍នៅតាមតំបន់នានាដែលស្ថិតក្រោមការត្រួតត្រារបស់គាត់ ។ គាត់ក៏បានណែនាំផងដែរដល់អ្នកក្រោមបង្គាប់របស់គាត់ អំពីការចាប់គូដោយផ្អែកលើប្រវត្តិរូបរបស់ពួកគេ ហើយគាត់បានដាក់វិធានចំពោះគូស្រករថ្មីថ្មោងត្រូវតែឲ្យរួមដំណេកជាមួយគ្នាដើម្បីបង្កើតកូន ។ ក្នុងបរិយាកាសដោយការបង្ខិតបង្ខំគ្រប់ទីកន្លែងដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការណែនាំទាំងនេះជាលទ្ធផលបង្កើតឲ្យមានការរៀបការដោយបង្ខំរាប់ពាន់ករណី ។ គូស្រករដែលទើបរៀបការថ្មីថ្មោងទាំងនេះត្រូវបានអ្នកក្រោមបង្គាប់របស់អោ អាន ឈ្លបតាមដានដូចៗគ្នា ដើម្បីឲ្យប្រាកដថា ពួកគេពិតជាបានរួមដំណេកជាមួយគ្នា ធ្វើឲ្យទាំងបុរស និងស្ត្រីរួមភេទនឹងគ្នាដោយគ្មានការយល់ព្រមដោយសេរីរបស់ដៃគូម្នាក់ ឬទាំងពីរ ។ ការបង្ខំឲ្យមនុស្សពាក់ព័ន្ធក្នុងទំនាក់ទំនងផ្លូវភេទដោយគ្មានការយល់ព្រមដោយសេរី ក្នុងលក្ខខណ្ឌបែបនេះ ដែលការព្រមព្រៀងមិនអាចធ្វើបាន គឺចាត់ទុកថាជាអំពើរំលោភសេពសន្ថវៈ ។ គោលជំហររបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថាតាមរយៈការបង្ខំឲ្យគូស្រករទាំងនោះរួមសង្វាសជាមួយគ្នាដោយគ្មានការយល់ព្រមពិតប្រាកដពីស្ត្រី ឬបុរសដែលពាក់ព័ន្ធនោះ អោ អាន និងជនក្រោមបង្គាប់របស់គាត់បានប្រព្រឹត្តឧក្រិដ្ឋកម្មរំលោភសេពសន្ថវៈ ។

ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិមានចំនួន ១៨៨ ទំព័រ ដែលជាការវិភាគសំខាន់ អមដោយកំណត់សម្គាល់ចុងអត្ថបទចំនួន ២.៣២២ ដែលលើកយោងភស្តុតាងដែលប្រមូលបាននៅក្នុងអំឡុងនៃកិច្ចស៊ើបសួរ ។ ភស្តុតាងនេះរួមមាន ឯកសារចំនួន ១០.១០០ ដោយរួមបញ្ចូលទាំងកំណត់ហេតុនៃការស្តាប់ចម្លើយចំនួន ១.៦០០ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២.០០០ និងឯកសារសហកាលសម័យបកក និងកំណត់ហេតុកម្ពុជាប្រជាធិបតេយ្យជាច្រើន បញ្ជីអ្នកទោសស-២១ បទសម្ភាសន៍ និងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រតិចារឹកសវនាការពីសំណុំរឿង០០១, ០០២/០១ និង ០០២/០២ រូបថត ផែនទី សៀវភៅ និងអត្ថបទសិក្សាស្រាវជ្រាវជាន់ខ្ពស់ ។ សហព្រះរាជអាជ្ញាអន្តរជាតិមានចេតនាស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតដាក់ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា និងចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសារណាទាំងនោះជាសាធារណៈ ក្រោយមានការកោសលុបសមស្របដើម្បីការពារសន្តិសុខ និងសិទ្ធិជាឯកជនរបស់សាក្សី និងជនរងគ្រោះ ។

សូមរំឭកចំពោះអ្នកអានថា គ្រប់ជនសង្ស័យ និងជនត្រូវចោទ ឬបុគ្គលដែលបានបញ្ជូនទៅជំនុំជម្រះទាំងអស់ គឺត្រូវបានសន្មត់ថាគ្មានទោស លើកលែងតែ និងរហូតទាល់តែពិរុទ្ធភាពរបស់ពួកគាត់ត្រូវបានបង្ហាញឲ្យហួសពីវិមតិសង្ស័យនៅក្នុងសវនាការ ។

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

# ទស្សនវិស័យរបស់គម្រោងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

ស្រុកអន្លង់វែង ជាតំបន់ដាច់ស្រយាលមួយនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា និងជាតំបន់កាន់កាប់ចុងក្រោយរបស់ខ្មែរក្រហម ។ បច្ចុប្បន្ននេះ នៅក្នុងស្រុកអន្លង់វែង មានគម្រោងមួយដែលកំពុងមមាញឹកក្នុងការជំរុញឲ្យមានសន្តិភាព និងព្យាបាលរបួសនៃអតីតកាលដ៏ឃោរឃៅរបស់កម្ពុជាតាមរយៈការពិភាក្សានិងការអប់រំ ។ លោកស្រី ម៉ារីសា ការូថើស (Marissa Carruthers) និពន្ធនាយកនៃទស្សនាវដ្ដីអាស៊ីឡាយហ្វ (Asialife) បានសន្ទនាជាមួយ បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដើម្បីស្វែងយល់បន្ថែមពីគម្រោងមួយនេះនៅស្រុកអន្លង់វែង ។

***តើគម្រោងអន្លង់វែងមានគោលដៅអ្វី?***

អន្លង់វែង គឺជាទីស្នាក់អាស្រ័យដ៏ធំរបស់អតីតកម្មាភិបាលខ្មែរក្រហម ហើយស្រុកនេះក៏មានតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រដែលទាក់ទងនឹងខ្មែរក្រហមចំនួន ១៤ទីតាំងដែរ ។ ទីតាំងដែលលេចធ្លោជាងគេនៅក្នុងស្រុកអន្លង់វែង មានដូចជាសារមន្ទីរ តាម៉ុក (ដែលមានរហស្សនាមថាបងទី៥ ឬ តាម៉ុក មេពេជ្ឈឃាត) ទីតាំងបូជាសព ប៉ុល ពត និងផ្ទះ តាម៉ុក ដែលធ្លាប់ជាកន្លែងជួបប្រជុំរបស់ខ្មែរក្រហមនៅលើភ្នំដងរែក តែក្រោយមកផ្ទះនេះបានប្រើប្រាស់ជាមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។ អន្លង់វែង គឺជាតំបន់ប្រវត្តិសាស្ត្រមួយ ក៏ដូចជាចំណុចផ្ដើមដ៏ល្អមួយសម្រាប់អ្នកដែលចង់សិក្សាបន្ថែមអំពីខ្មែរក្រហម ។ ស្រុកអន្លង់វែងជាកន្លែងមួយដើម្បីសិក្សាអំពីរបៀបរស់នៅរបស់កម្មាភិបាលខ្មែរក្រហមនៅសម័យកម្ពុជាប្រជាធិបតេយ្យ និងមូលហេតុដែលបុគ្គលមួយចំនួននៅតែ



បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង (រូបថត ៖ អេនរីក ខាថាឡា)

ជឿជាក់ និងគាំទ្រមេដឹកនាំខ្មែរក្រហមក្នុងអំឡុងសម័យកាលនោះ បើទោះបីជាខ្លួនដឹងថារបបខ្មែរក្រហម ជារបបប្រល័យពូជសាសន៍ក៏ដោយ ។ គោលដៅដែលយើងចង់សម្រេចឲ្យបានគឺជាការផ្សព្វផ្សាយឲ្យមនុស្សទាំងឡាយយល់ដឹងអំពីប្រវត្តិសាស្ត្រដ៏ស្មុគស្មាញនេះ ។

## តើគម្រោងអន្លង់វែងចាប់ផ្តើមដោយរបៀបណា?

នៅឆ្នាំ ២០០១ រដ្ឋាភិបាលបានចេញអនុក្រិត្យមួយ ដែលលើកឡើងពីតម្រូវការនៃការថែរក្សាទុកធាតុរបស់ជនរងគ្រោះដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម និងការអភិរក្សស្រុកអន្លង់វែងជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលបានភារកិច្ចក្នុងការស្រាវជ្រាវ និងប្រមែប្រមូលឯកសារនៅក្នុងស្រុកអន្លង់វែង ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតក្រុមការងារមួយក្រុមតូចដែលមានសមាជិកតិចជាង១០នាក់ ហើយបានចាប់ផ្តើមសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហមអ្នករស់រានមានជីវិត ព្រមទាំងកម្មាភិបាលខ្មែរក្រហមដែលនៅក្នុងស្រុកជិតខាង ដើម្បីស្វែងយល់អំពីរឿងរ៉ាវដែលកើតឡើងក្នុងអំឡុងសង្គ្រាម ។ បន្ទាប់ពីពេលនោះមក ខ្ញុំបានធ្វើការជាមួយនិស្សិតស្ថាបត្យកម្ម មកពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈចំនួនប្រមាណជាង១០នាក់ ដើម្បីប្រែក្លាយផ្ទះកណ្តាលលើភ្នំដងរែករបស់ តាម៉ុក ឲ្យទៅជាមជ្ឈមណ្ឌលសន្តិភាព ។ យើងបានធ្វើការជួសជុលផ្ទះនេះសាជាថ្មី ព្រមទាំងបានអភិវឌ្ឍផ្នូររបស់ ប៉ុល ពត ដោយដំឡើងផ្ទាំងព័ត៌មានដែលរៀបរាប់អំពីកាលបរិច្ឆេទទាក់ទងនឹងចលនាខ្មែរក្រហម និងប្រវត្តិសាស្ត្ររបស់សហគមន៍អន្លង់វែង ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងក៏មានផែនទីផ្លូវដើរទៅកាន់ទីតាំងប្រវត្តិសាស្ត្រដទៃនៅក្នុងស្រុកអន្លង់វែង ដែលគូរដោយនិស្សិតស្ម័គ្រចិត្តដែរ ។

## ហេតុអ្វីបានជាគម្រោងអន្លង់វែងមានសារសំខាន់?

ប្រវត្តិសាស្ត្រមានសារសំខាន់យ៉ាងខ្លាំង ដូច្នេះហើយគោលដៅចម្បងរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងគឺជាការជំរុញឲ្យមានការចងចាំ យុត្តិធម៌ និងការផ្សះផ្សា ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងមិនមានបំណងផ្លាស់ប្តូរការយល់ឃើញរបស់បុគ្គលណាមួយទេ ផ្ទុយទៅវិញការងាររបស់មជ្ឈមណ្ឌលគឺជាការផ្សព្វផ្សាយឲ្យមនុស្សទាំងឡាយដឹងអំពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា តាមរយៈការបកស្រាយរបស់ភាគីជម្លោះទាំងសងខាង ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងព្យាយាមនាំមនុស្សមកពីតំបន់ផ្សេងៗមកទស្សនាតំបន់អន្លង់វែង ដើម្បីឲ្យភាគីនីមួយៗអាចរៀបរាប់អំពីបទពិសោធន៍របស់ខ្លួន ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងផ្តល់ឱកាស និងសិទ្ធិបញ្ចេញមតិស្មើៗគ្នាដល់ភាគីទាំងសងខាង ។ ដើម្បីស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហមជាទូទៅ យើងអាចនិយាយជាមួយនរណាម្នាក់នៅក្នុងប្រទេសកម្ពុជាក៏បាន ពីព្រោះប្រជាជនកម្ពុជាគ្រប់រូបសុទ្ធតែធ្លាប់បានឆ្លងកាត់របបនេះ ។ នៅពេលយើងពិភាក្សាជាមួយត្រឹមតែជនរងគ្រោះ មានន័យថា យើងអាចមើលឃើញត្រឹមតែជ្រុងម្ខាងប៉ុណ្ណោះ ។ ប៉ុន្តែនៅពេលដែលយើងនិយាយជាមួយអតីតកម្មាភិបាលខ្មែរក្រហម នេះមានន័យថាយើងកំពុងតែព្យាយាមស្វែងយល់ពីជ្រុងម្ខាងទៀតនៃជម្លោះ ។ នេះគឺជាលក្ខណៈពិសេសមួយរបស់អន្លង់វែង ។ តាមរយៈការពិភាក្សា និងការអប់រំយើងសង្ឃឹមថាភាគីទាំងពីរអាចឈានដល់ការទទួលស្គាល់អតីតកាល និងធ្វើការផ្សះផ្សាគ្នាទៅវិញទៅមក ។

## តើការងារអ្វីខ្លះដែលកំពុងដំណើរការនាពេលបច្ចុប្បន្ន?

និស្សិតស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងកំពុងតែធ្វើកិច្ចការរចនាទៅលើទីតាំងប្រវត្តិសាស្ត្របីផ្សេងទៀត ដែលក្នុងនោះរួមមាន ផ្ទះឃុំឃាំងបណ្តោះអាសន្នរបស់ ប៉ុល ពត និងទីតាំងបូជាសព សុន សេន ។ នៅក្នុងខែសីហា មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនឹងចាប់ធ្វើការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ចំនួនពីរក្រុមសម្រាប់សហគមន៍អន្លង់វែង ដែលនឹងបញ្ចប់នៅចុងឆ្នាំ ២០១៧ ។ បន្ទាប់មកមជ្ឈមណ្ឌលនឹងបន្តធ្វើការបណ្តុះបណ្តាលបន្ថែមសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ ដើម្បីធានាឲ្យបានថាភ្ញៀវទេសចរអាចមានចំណេះដឹងប្រវត្តិសាស្ត្រដែលមានលក្ខណៈសុក្រឹត ។ បច្ចុប្បន្ននេះ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងកំពុងចងក្រងសៀវភៅប្រវត្តិសាស្ត្រ ដែលសៀវភៅនេះមានឥទ្ធិពលខ្លាំងនៅពេលប្រើប្រាស់គួបផ្សំជាមួយនឹងការពិភាក្សា ។ ការសរសេរប្រវត្តិសាស្ត្រ និងការពិភាក្សាជាមួយប្រជាជនអន្លង់វែង មានលក្ខណៈខុសៗពីគ្នា ។ ការពិភាក្សាជាមួយប្រជាជនអន្លង់វែងតែ

មួយមុខនឹងផ្តល់ព័ត៌មានដែលមានភាពលម្អៀង ពីព្រោះថាកម្មាភិបាលជាច្រើននៅតែគាំទ្ររបៀបនៃការគ្រប់គ្រងរបស់ តាម៉ុក ។ អ្នកទាំងនោះយល់ថា តាម៉ុក ជាមនុស្សល្អ ដោយ តាម៉ុក បានកសាងផ្លូវ និងសាលារៀន នៅក្នុងស្រុកអន្លង់វែង ។ អ្នកទាំងនោះមិនបានក្រឡេកមើលទៅរបបខ្មែរក្រហម និងវិធីសាស្ត្រខ្មែរក្រហមប្រើប្រាស់ដើម្បីកាន់កាប់ប្រទេសកម្ពុជាឡើយ ដូច្នេះហើយទើបមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងខិតខំព្យាយាមផ្តល់ព័ត៌មានអំពីប្រវត្តិសាស្ត្រដែលមានសុក្រឹតដល់សាធារណជន ។

**តើនរណាកំពុងធ្វើទស្សនកិច្ចនៅទីតាំងប្រវត្តិសាស្ត្រក្នុងស្រុកអន្លង់វែង?**

ដំណើរទស្សនកិច្ចនៅតាមទីតាំងប្រវត្តិសាស្ត្រក្នុងស្រុកអន្លង់វែង ផ្តោតសំខាន់ទៅលើការអប់រំ ហើយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានដឹកនាំនិស្សិតពីក្នុង និងក្រៅប្រទេសជាច្រើននាក់មកធ្វើទស្សនកិច្ចនៅក្នុងតំបន់នេះ ។ និស្សិតទាំងនេះតែងតែចូលរួមក្នុងការពិភាក្សា ហើយនាំយកព័ត៌មានត្រឡប់មកវិញដើម្បីសរសេរជាសំណេរ ដែលបានបោះពុម្ពផ្សាយនៅលើកាសែតក្នុងស្រុក ឬទស្សនាវដ្តីស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងមានគោលបំណង ផ្សារភ្ជាប់ភាពមិនចុះសម្រុងគ្នានៅក្នុងស្រុកអន្លង់វែង ពីព្រោះតែអន្លង់វែងគឺជាសហគមន៍ដែលមានភាពដាច់ស្រយាលមួយ ។ ដោយមានការសម្របសម្រួលការពិភាក្សាពីក្រុមការងាររបស់មជ្ឈមណ្ឌលយុវជនដែលបានចូលរួមដំណើរទស្សនកិច្ចនៅស្រុកអន្លង់វែងបានផ្លាស់ប្តូរអាកប្បកិរិយារបស់ខ្លួនចំពោះអតីតកម្មាភិបាលខ្មែរក្រហម ។ នៅមុនទស្សនកិច្ច យុវជនទាំងនេះបាននិយាយថា កម្មាភិបាលខ្មែរក្រហមសុទ្ធតែជាមនុស្សអាក្រក់ និងកាចសាហាវឃោរឃៅ ប៉ុន្តែនៅក្រោយពេលបានចូលរួមដំណើរទស្សនកិច្ច ក៏ដូចជាពិភាក្សាជាមួយអតីតកម្មាភិបាលខ្មែរក្រហមមួយចំនួន យុវជនទាំងនេះចាប់ផ្តើមយល់ថា ខ្មែរក្រហមក៏ជាមនុស្សដែរ ។ យើងក៏បានរកឃើញថា ក្រោយការពិភាក្សាអតីតកម្មាភិបាលខ្មែរក្រហមតែងតែមានអារម្មណ៍ថា បទពិសោធរបស់ខ្លួនត្រូវបានគេដឹងឮ និងទទួលស្គាល់ ហើយសកម្មភាពនេះផ្តល់ផលវិជ្ជមានដល់សុខភាពផ្លូវចិត្តរបស់អតីតកម្មាភិបាលខ្មែរក្រហមទាំងនេះ ។

**តើគម្រោងអន្លង់វែងមានក្តីរំពឹងអ្វីខ្លះសម្រាប់ថ្ងៃអនាគត?**

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងក៏ដើរតួជាភ្នែក និងត្រចៀករបស់ប្រជាជនស្រុកអន្លង់វែងដែរ ។ មានភាពអយុត្តិធម៌ជាច្រើនដែលបានកើតឡើងនៅក្នុងស្រុកនេះ ហើយអន្លង់វែងនៅតែប្រឈមមុខជាមួយនឹងបញ្ហាប្រឈមនានា ដែលទាក់ទងនឹងការកាប់បំផ្លាញព្រៃឈើ និងការរំលោភយកដីធ្លី ។ សហគមន៍នេះក៏មានបញ្ហាជាច្រើន ដែលយើងត្រូវយកចិត្តទុកដាក់ និងចាត់វិធានការការពារ ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងក៏កំពុងសម្លឹងមើលការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់ ព្រមបង្កើត «ប្លង់គោលសម្រាប់អភិវឌ្ឍស្រុកអន្លង់វែង» ដែរ ។

មជ្ឈមណ្ឌលកំពុងតែសហការជាមួយរដ្ឋាភិបាល និងក្រុមហ៊ុនរចនាប្លង់ដែលមានមូលដ្ឋាននៅទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស ទាក់ទងនឹងគម្រោងនេះ ។ គម្រោងព្រាងដំបូង នឹងត្រូវបង្ហាញជូនលោកនាយករដ្ឋមន្ត្រីនាពេលឆាប់ៗនេះ ។ អន្លង់វែង គឺជាចំណុចកណ្តាលសម្រាប់ការសិក្សាពីប្រវត្តិសាស្ត្រ និងការអប់រំដ៏សំខាន់មួយ ដែលយើងត្រូវជំរុញឲ្យឆ្ពោះទៅមុខ ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងមានបំណងអភិវឌ្ឍតំបន់នេះ ដើម្បីទាក់ទាញភ្ញៀវទេសចរឲ្យបានកាន់តែច្រើន ។ សាធារណជនអាចធ្វើដំណើរបានយ៉ាងងាយស្រួលពីខេត្តសៀមរាបទៅកាន់ស្រុកអន្លង់វែង ក្នុងមួយថ្ងៃដែលនេះជាកត្តាដែលផ្តល់ផលប្រយោជន៍ដល់ស្រុកអន្លង់វែងទាំងមូល ។

**ម៉ារីសា ការូថើស និង លី សុខឃាង**

**អានទស្សនាវដ្តីតាមគេហទំព័រ**

ទស្សនាវដ្តីស្វែងរកការពិតត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* ។ ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០ ១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# ព្រាត់ឪពុកដោយសារគ្មានថ្នាំព្យាបាល

ម្តាយខ្ញុំឈ្មោះ ស៊ីវសី សៅភ៉ាវី (ហៅ ពៅ) ជាពុទ្ធសាសនិកមួយរូប កើតនៅឆ្នាំ១៩៦០ នៅ ភូមិត្រាំងស្វាយ ឃុំស្រែរនោង ស្រុកត្រាំកក់ ខេត្តតាកែវ ។ ម្តាយខ្ញុំជាកូនស្រីក្នុងគ្រួសារកសិករ ដែលមានបងប្អូនប្រុសស្រី៦នាក់ និងមានឪពុកឈ្មោះ ឈិត សី និងម្តាយឈ្មោះ ស៊ីវ ប៉ាន ។

ម្តាយខ្ញុំបានរៀនសូត្រត្រឹមថ្នាក់ទី៧ (សម័យសង្គមរាស្ត្រនិយម) ។ នៅឆ្នាំ១៩៧១ ដោយមានការប្រយុទ្ធប្រទាញប្រទង់គ្នារវាងកងទ័ពបដិវត្តន៍ខ្មែរក្រហម និងកងទ័ព លន់ នល់ សាលាដែលម្តាយខ្ញុំរៀនបានបិទទ្វារ ។ ប៉ុន្តែបងៗរបស់គាត់បីនាក់ បាននាំគ្នាទៅបន្តការសិក្សានៅតំបន់ដែលកងទ័ព លន់ នល់ គ្រប់គ្រងវិញ ។ ហេតុនេះ នៅផ្ទះមានតែម្តាយខ្ញុំប៉ុណ្ណោះ នៅមើលថែប្អូនៗ និងឪពុកម្តាយ ។ ក្រោយមក កងទ័ពបដិវត្តន៍ខ្មែរក្រហមបានចូលមកគ្រប់គ្រងភូមិស្រុកដែលគ្រួសារម្តាយខ្ញុំរស់នៅ ។ ខ្មែរក្រហមបានរៀបចំភូមិ និងផ្លាស់ប្តូររបៀបរបបរស់នៅរបស់អ្នកភូមិ ។ ខ្មែរក្រហមបានបែងចែកការងារឲ្យអ្នកភូមិធ្វើគ្រប់ៗគ្នា ។ អំឡុងពេលនោះ ម្តាយខ្ញុំមានវ័យ១២ឆ្នាំ មានកាតព្វកិច្ចនៅជួយមើលថែគ្រួសារ ក្រៅពីការងារដែលខ្មែរក្រហមដាក់ឲ្យគាត់ធ្វើប្រចាំថ្ងៃ ។ ម្តាយខ្ញុំត្រូវបានមេភូមិចាត់ឲ្យធ្វើការដូចមនុស្សដែលពេញវ័យដែរ ។


ម្តាយរបស់ គង្គា ឈ្មោះ សៅភ៉ាវី ធ្វើបុណ្យឧទ្ទិសកុសល្យជូនដល់បងប្អូនដែលបានស្លាប់ នៅវត្តមួយ ក្នុងខេត្តបាត់ដំបង ។

ម្តាយខ្ញុំខិតខំធ្វើការយ៉ាងខ្លាំង មិនឲ្យខ្មែរក្រហមទើសចិត្តឡើយ ។ ការខិតខំរបស់គាត់នោះ ក៏ព្រោះតែខ្មែរក្រហមចោទគ្រួសារគាត់ថា “មានវណ្ណៈភាពជាកសិករថ្នាក់លើ” ។ ហេតុនេះ គ្រួសារគាត់ត្រូវតែធ្វើការឲ្យខ្លាំងបន្តិច បើមិនអ៊ីចឹងទេ នឹងយកទៅលត់ដំមិនខាន ។ ដើម្បីសុវត្ថិភាពគ្រួសារ ម្តាយខ្ញុំខិតខំតស៊ូធ្វើការងារ ទោះបីជាគាត់ឈឺយ៉ាងណាក៏ដោយ ។ ម្តាយខ្ញុំរែកដីរហូតឈឺស្មា និងឈឺដៃលើកមិនរួច តែគាត់ទ្រាំនឹងស្ថានភាពនេះដោយឈឺចាប់ ហើយក៏មិនហ៊ានឈប់សម្រាកដែរ ។

នៅថ្ងៃ១៥ មេសា ១៩៧៥ បន្ទាប់ពីកងទ័ពបដិវត្តន៍ខ្មែរក្រហមទទួលបានជ័យជម្នះទូទាំងប្រទេស ខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនចេញពីភូមិ ។ ខ្មែរក្រហមបានជម្លៀសគ្រួសារម្តាយខ្ញុំទៅកាន់តំបន់មួយ ដែលគាត់ធ្លាប់បានឮថា ជាតំបន់សម្រាប់ដាក់ពួកឈ្លើយសឹកសង្គ្រាម និងជាតំបន់មានជំងឺគ្រុនចាញ់ ដែលមានទីតាំងនៅអង្គតាសោម ក្នុងព្រៃជើងភ្នំ ឬហៅថា មន្ទីរ២០៨ ។ ពេលទៅដល់ក្នុងព្រៃដំបូង អង្គការបានឲ្យម្តាយខ្ញុំទៅរស់នៅខ្ទមនិងបែងចែកដីឲ្យដាំដំណាំហូបតាមគ្រួសាររៀងៗខ្លួន ។ ម្តាយខ្ញុំបានរម្លឹកប្រាប់ខ្ញុំថា ពេលដែលគាត់កាប់ដីដាំដំណាំបានប្រទះឃើញឆ្អឹងខ្មោចជាច្រើនកប់ក្នុងដី ។ ម្តាយខ្ញុំ ក៏ដូចជាសមាជិកគ្រួសារអស់សង្ឃឹមថានឹងមានឱកាសនឹងរស់ ប៉ុន្តែទោះជាយ៉ាងណា គាត់ប្តេជ្ញាថា

ទោះបីជាត្រូវស្លាប់ក៏ត្រូវតែមានអាហារហូបគ្រប់គ្រាន់ដែរ ។ មិនយូរប៉ុន្មាន ផ្ទៃដីព្រៃដែលពោរពេញដោយឆ្អឹងខ្មោច បានក្លាយជាច្បារដំណាំយ៉ាងខៀវស្រងាត់ ។

នៅខែមិថុនា ឆ្នាំ១៩៧៦ អង្គការបានអនុវត្តច្បាប់ថ្មី ដោយលុបបំបាត់កម្មសិទ្ធិឯកជនទាំងអស់ មិនថា ផលដំណាំ ឬទ្រព្យសម្បត្តិ គឺយកមកដាក់ជាសម្បត្តិរបស់សមូហភាព ។ លើសពីនេះ អង្គការបានបញ្ជាឲ្យអ្នកភូមិរើទៅកន្លែងថ្មី ដោយប្រាប់ថា មិនចាំបាច់យកអ្វីទៅទាំងអស់ ក្រៅតែពីសម្លៀកបំពាក់មួយស្បោងម្នាក់ប៉ុណ្ណោះ ។ មកដល់បច្ចុប្បន្ននេះ ម្តាយខ្ញុំនៅតែចង ចាំពាក្យស្លោកដែលអង្គការបានលើកឡើងថា "កម្មសិទ្ធិសមរម្យ មានតែស្បោងតូចមួយប៉ុណ្ណោះ" ។

ដំបូង អង្គការឲ្យគ្រួសារម្តាយខ្ញុំស្នាក់នៅសាលារៀនក្នុងវត្តអង្គសិរិទ្ធ បន្ទាប់មក អង្គការបានបំបែកសមាជិកគ្រួសារចេញពីគ្នា និងចាត់ឲ្យទៅរស់នៅតាមកងរៀងៗខ្លួន ។ ម្តាយខ្ញុំ ត្រូវបានអង្គការចាត់ចូលកងចល័តនារី និងប្អូនតូចៗនៅកងកុមារ ។ ចំណែកជីតាខ្ញុំ ត្រូវបានអង្គការចាត់ឲ្យទៅធ្វើការនៅកន្លែងឆ្ងាយ និងមិនដែលបានមកជួបគ្រួសារទេ ។

នៅឆ្នាំ១៩៧៧ ជីតារបស់ខ្ញុំមានជំងឺធ្ងន់ ពេលនោះគាត់ក៏មិនមានថ្នាំសម្រាប់លេបដែរ ។ បើនិយាយអំពីពេទ្យរបស់អង្គការវិញ មានតែថ្នាំចម្រាញ់ដាក់ដបម៉្សាងដែលគ្មានប្រសិទ្ធភាពទេ ។ ដោយចាក់តែថ្នាំចម្រាញ់នេះ ជីតារបស់ខ្ញុំមិនបានធូរស្បើយទេ គឺកាន់តែធ្វើឲ្យជំងឺរបស់គាត់កាន់តែធ្ងន់ទៅៗ ។ ម្តាយរបស់ខ្ញុំបន្តប្រាប់ខ្ញុំដោយហួសចិត្តថា អង្គការមិនត្រឹមតែមិនខ្វាយខ្វល់ពីជំងឺរបស់ជីតាខ្ញុំទេ ថែមទាំងចោទជីតាខ្ញុំថា គាត់ឈឺសតិអារម្មណ៍ទៀតផង ។ ម្តាយខ្ញុំពេលនោះ ធ្វើការនៅការដ្ឋានកំពង់យោល ដែលមានទីតាំងក្បែរកន្លែងជីតាខ្ញុំសម្រាកដែរ ប៉ុន្តែគាត់មិនមានសិទ្ធិទៅមើលថែឪពុកទេ ។

មានពេលមួយ ម្តាយខ្ញុំបានការអនុញ្ញាតទៅមើលឪពុក ប៉ុន្តែ ពេលដែលគាត់ទៅដល់ជីតាខ្ញុំឈឺធ្ងន់ទៅហើយ គាត់បានត្រឹមតែនិយាយខ្សាវៗ ។ ម្តាយខ្ញុំបានស្នើសុំអង្គការឲ្យជួយដឹកជីតាខ្ញុំទៅភូមិវិញ ដើម្បីឲ្យបានឃើញមុខយាយខ្ញុំជាលើកចុងក្រោយ ។ អង្គការក៏អនុញ្ញាត រួចហើយក៏ដឹកជីតាខ្ញុំទៅភូមិវិញ ។ អ្វីដែលគួរឲ្យសោកស្តាយបំផុតនោះគឺ ពេលទៅដល់ភូមិ ជីតាខ្ញុំវង្វេងលែងស្គាល់លោកយាយ និងកូនចៅទៅហើយ ។ យាយរបស់ខ្ញុំបានស្នើអង្គការនៅមើលថែប្តីនៅផ្ទះ ប៉ុន្តែអង្គការមិនយល់ព្រមទេ ដោយប្រាប់ថា បើឈឺត្រូវតែទៅព្យាបាលនៅមន្ទីរពេទ្យ ។ អង្គការបានយកជីតាខ្ញុំទៅដាក់នៅមន្ទីរពេទ្យវត្តស្រែរនោង និងទុកគាត់នៅទីនោះតែម្នាក់ឯងរហូតដល់គាត់ស្លាប់តែម្តង ។ ម្តាយខ្ញុំមានការឈឺចាប់ និងស្រណោះឪពុកយ៉ាងខ្លាំង បន្ទាប់ពីបានទទួលដំណឹងដ៏ក្រៀមក្រំនេះ ។ ទោះបីជា មានការឈឺចាប់នឹងមរណភាពរបស់ជីតាខ្ញុំយ៉ាងណាក្តី ក៏គាត់នៅតែខិតខំពុះពារធ្វើការយ៉ាងស្វាហាប់ ហើយសម្លឹងទៅមុខដោយសុទិដ្ឋិនិយម ដោយគិតដល់ម្តាយ និងប្អូនៗដែលនៅមានជីវិត ។

ថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៨ អង្គការបានរៀបការម្តាយខ្ញុំជាមួយនឹងឪពុកខ្ញុំឈ្មោះ សាំង ប៊ុនម៉ៅ ដែលអ្នកទាំងពីរមិនធ្លាប់ស្គាល់មុខគ្នាពីមុនមកទេ ។ ក្រោយរបបខ្មែរក្រហមដួលរលំ ឪពុកម្តាយខ្ញុំបានធ្វើដំណើរត្រឡប់ទៅភូមិកំណើតវិញ ហើយមួយរយៈក្រោយមក លោកទាំងពីរបានផ្លាស់ទៅរស់នៅ និងសាងជីវិតថ្មីនៅខេត្តបាត់ដំបង ដែលជាស្រុកកំណើតខាងបងប្អូនឪពុកខ្ញុំរហូតមកដល់បច្ចុប្បន្ន ។

ជាចុងក្រោយ ម្តាយរបស់ខ្ញុំក្រើនរម្លឹកដល់ខ្ញុំថា "គាត់មិនមែនជាជនរងគ្រោះតែម្នាក់នៃរបបខ្មែរក្រហមទេ គឺមានប្រជាជនខ្មែររាប់លាននាក់ ដែលជាជនរងគ្រោះនៃការសម្លាប់យ៉ាងអយុត្តិធម៌ដ៏ព្រៃផ្សៃ ការបាត់បង់ព្រាត់ប្រាស់គ្រួសារ ការបង្ខំឲ្យធ្វើការហួសកម្លាំង របួសផ្លូវចិត្ត និងកង្វះអាហារូបតម្ភ និងកង្វះថ្នាំព្យាបាលជំងឺបណ្តាលឲ្យឪពុកគាត់ស្លាប់ ។ គាត់សង្ឃឹមយ៉ាងមោះមុតថា មេដឹកនាំខ្មែរក្រហមដែលសេសសល់ទាំងប៉ុន្មាននឹងទទួលការកាត់ទោសយ៉ាងធ្ងន់ ចំពោះឧក្រិដ្ឋកម្មអមនុស្សធម៌ដែលខ្លួនបានប្រព្រឹត្តកន្លងមក ហើយសូមឲ្យកូនខ្មែរជំនាន់ក្រោយ ទាំងឡាយជៀសឲ្យឆ្ងាយពីការគុំគួនធ្វើទុក្ខបុកម្នេញជាតិសាសន៍ឯង និងងាកមកផ្តោតលើ ស្មារតីសាមគ្គីភាព ការចេះយល់យោគអត់ឱនគ្នា និងរួមគ្នាដើម្បីអភិវឌ្ឍប្រទេសជាតិឲ្យកាន់តែរីកចម្រើនទៅអនាគត ។

**អ៊ុច គន្ធា**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ វ៉ាន់ថាន់ ពៅដារ៉ា ទូរសព្ទលេខ ០១២ ៨៤៦ ៥២៦ ឬ អ៊ីម៉ែល ៖ *truthpdara@dccam.org* ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាសយដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ










ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 213, 2017 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.